# មកុដពន្ធនចេតិយ

## (ស្ថានទីបូជាព្រះបរមសពនៃព្រះសម្មាសម្ពុទ្ធ)











[illegible] elibrary of Cambodia
តុលា ២០១៥

# ប្រវត្តិព្រះបរមសារីរិកធាតុ ព្រះចេតិយ និង ពិធីពុទ្ធាភិសេក

រៀបរៀងដោយ
លោក វ៉ាន់ ចាន់សារ៉េន
ក្រុមជំនុំព្រះត្រៃបិដកប្រចាំវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ព.ស.២៥៤៧
គ.ស.២០០៣

www.elibraryofcambodia.org

# ព្រះបរមសារីរិកធាតុ















www.elibraryofcambodia.org

## សេចក្ដីបញ្ជាក់
## ចំពោះការបោះពុម្ព

ពុទ្ធសាសនបណ្ឌិត្យនឹងខិតខំស្វែងរកឯកសារចាស់ ៗ និងឯកសារថ្មី ៗ ដែលអ្នកប្រាជ្ញបានរៀបរៀងឡើង ហើយនឹងបោះពុម្ពជាប្រយោជន៍ដល់សាធារណជនជាទូទៅ ហើយក៏ដើម្បីថែរក្សាវប្បធម៌ អក្សរសាស្ត្រឱ្យមានការរីកចំរើនជាភិយ្យោភាពតទៅខាងមុខ ។ នៅក្នុងពេលនេះ ពុទ្ធសាសនបណ្ឌិត្យយើងបានចេញបោះពុម្ពសៀវភៅប្រវត្តិព្រះបរមសារីរិកធាតុ ព្រះចេតិយ និងពិធីពុទ្ធាភិសេក ដែលរៀបរៀងដោយ លោក **ម៉ាន់ ចាន់សារឹន** ជាសមាជិកក្រុមជំនុំព្រះត្រៃបិដក ដើម្បីជាហិតប្រយោជន៍ដល់ពុទ្ធបរិស័ទសិក្សាស្វែងយល់ពីព្រះពុទ្ធសាសនាឱ្យកាន់តែច្បាស់លាស់ ពីរឿងព្រះធាតុរបស់ព្រះសម្មាសម្ពុទ្ធ និង អានិសង្សបូជាព្រះចេតិយ ព្រមទាំងរបៀបពិធីពុទ្ធាភិសេកដែលត្រឹមត្រូវតាមគម្ពីរព្រះត្រៃបិដក អដ្ឋកថា ដីកា ជាដើម ។

ពុទ្ធសាសនបណ្ឌិត្យសូមបោះពុម្ពផ្សាយសៀវភៅនេះ ជាសម្បត្តិរបស់ពុទ្ធសាសនបណ្ឌិត្យនិងសូមកោតសរសើរនូវស្នាដៃដ៏ល្អឯករបស់លោក **ម៉ាន់ ចាន់សារឹន** ដែលខិតខំស្រាវជ្រាវក្នុងគម្ពីរព្រះត្រៃបិដក អដ្ឋកថា ដីកា និងបករណវិសេសដទៃ ៗ ទៀត ឱ្យកើតជារូបរៀងសៀវភៅនេះឡើង ។

www.elibraryofcambodia.org

សូមជនានុជនក្នុងកម្ពុជរដ្ឋបានចំរើនលូតលាស់ដុះដាលដោយវិជ្ជា និង វិបុលសុខគ្រប់ប្រការ ហើយរួបរួមគ្នាកសាងប្រទេសជាតិ និង លើកស្ទួយអក្សរសាស្ត្រនិងព្រះពុទ្ធសាសនាឱ្យបានរីកចំរើនជាភិយ្យោភាពតរៀងទៅ ។

ភ្នំពេញ

ថ្ងៃ ៨ រោច ខែ ស្រាពណ៍ ព.ស. ២៥៤៧

ត្រូវនឹងថ្ងៃ ពុធ ទី ២០ ខែ សីហា ឆ្នាំ ២០០៣

ពុទ្ធសាសនបណ្ឌិត្យ

www.elibraryofcambodia.org

| លេខរៀង | មាតិកាអត្ថបទ | ទំព័រ |
| --- | --- | --- |
| ១ | អារម្ភកថា.......................................................... | ក |
| ២ | បទនមស្សការ.................................................... | |
| ៣ | ពុទ្ធកិច្ចព្រះអរហន្តសម្មាសម្ពុទ្ធ.................................. | ១ |
| ៤ | កិច្ចក្នុងបុរេភត្ត.................................................. | ២ |
| ៥ | កិច្ចក្នុងបច្ឆាភត្ត.................................................. | ៤១ |
| ៦ | កិច្ចក្នុងបឋមយាម................................................ | ៥ |
| ៧ | កិច្ចក្នុងមជ្ឈិមយាម- បច្ឆិមយាម.................................. | ៦ |
| ៨ | ការចែកព្រះបរមសារីរិកធាតុ...................................... | ៩ |
| ៩ | សរុបព្រះធាតុ..................................................... | ២៣ |
| ១០ | ខ្នាត-ពណ៌ និង បរិមាណរបស់សម្ពិន្នធាតុ............... | ២៦ |
| ១១ | ព្រះមហាកស្សបៈធ្វើធាតុនិធាន គឺកប់ ព្រះបរមសារីរិកធាតុក្នុងដី........................................ | ២៩ |
| ១២ | សម័យព្រះបាទធម្មាសោកទ្រង់ជ្រះថ្លានឹងព្រះពុទ្ធសាសនា.. | ៣៤ |
| ១៣ | ព្រះបរមសារីរិកធាតុមកកោះសិរីលង្កា....................... | ៣៩ |
| ១៤ | ពោលពីព្រះវាមទន្តធាតុគឺចង្កូមកែវខាងឆ្វេងមកសិរីលង្កា | ៥០ |
| ១៥ | ព្រះឧណ្ហិសធាតុ( ថ្ងាស) ឬ នលាដធាតុមកកាន់លង្កាទ្វីប | ៧៣ |
| ១៦ | រឿងមហិយង្គចេតិយ................................................ | ៨១ |

www.elibraryofcambodia.org

| | | |
|---|---|---|
| ១៧ | រឿងបរិច្ចចេតិយ.................................................... | ៨៦ |
| ១៨ | រឿងលោហប្រាសាទ.......................................... | ៨៧ |
| ១៩ | រឿងសុវណ្ណមាលិកចេតិយ........................................ | ៨៨ |
| ២០ | រឿងព្រះបរមសារីរិកធាតុក្នុងប្រទេសកម្ពុជា........... | ៩៣ |
| ២១ | ព្រះបរមសារីរិកធាតុនិងព្រះអរហន្តធាតុនៃព្រះសារីបុត្រនិង ព្រះមោគ្គល្លានមកស្ថិតនៅក្នុងប្រទេសកម្ពុជាអស់៧ថ្ងៃ | ៩៨ |
| ២២ | របៀបដង្ហែព្រះធាតុប្រទក្សិណក្រុងភ្នំពេញ.................... | ១១១ |
| ២៣ | របៀបដង្ហែព្រះធាតុត្រឡប់ទៅឥណ្ឌាវិញ..................... | ១១៦ |
| ២៤ | បុណ្យពាក់កណ្ដាលសាសនា.................................... | ១៣៧ |
| ២៥ | ធាតុបូជនីយកថា.......................................................... | ១៤៤ |
| ២៦ | ពុទ្ធសារីរិកធាតុវិភាគកថា............................................ | ១៥០ |
| ២៧ | ពហើនាពីព្រះចេតិយ.................................... | ១៥៣ |
| ២៨ | បុគ្គលទំលាយចេតិយមានទោសស្មើអនន្តរិយកម្ម........... | ១៦៤ |
| ២៩ | ពិធីពុទ្ធាភិសេក.......................................................... | ១៧១ |
| ៣០ | រតនមាលា.................................................................. | ១៧៦ |
| ៣១ | ជយឧត្សោសនស័ព្ទ......................................................... | ១៩២ |
| ៣២ | សព្វពុទ្ធានាវិជហិតឧទាន.................................................. | ១៩៣ |


www.elibraryofcambodia.org

| | | |
|---|---|---|
| ៣៣ | បដិច្ចសមុប្បាទានុលោម............................ | ១៩៤ |
| ៣៤ | បដិច្ចសមុប្បាទបដិលោម............................ | ១៩៥ |
| ៣៥ | បដិច្ចសមុប្បាទានុលោមបដិលោម........................ | ១៩៦ |
| ៣៦ | ពុទ្ធជយមង្គលគាថា............................ | ២០០ |
| ៣៧ | គាថាជិនបញ្ជរ............................ | ២០៣ |
| ៣៨ | ពុទ្ធនវមបូជា............................ | ២០៧ |
| ៣៩ | អភយបរិត្ត............................ | ២០៨ |
| ៤០ | ជយបរិត្ត............................ | ២០៩ |
| ៤១ | សព្វមង្គលគាថា............................ | ២១០ |
| ៤២ | ជំនុំទេវតា............................ | ២១១ |
| ៤៣ | ធាតុចេតិយនមស្សការគាថា............................ | ២១៤ |
| ៤៤ | ការនមស្សការព្រះបរមសារីរិកធាតុ........................ | ២១៦ |
| ៤៥ | បូជាព្រះបរមសារីរិកធាតុ............................ | ២១៩ |
| ៤៦ | អានិសង្សបូជាព្រះពុទ្ធឬសាវ័កព្រះពុទ្ធ...................... | ២២០ |
| ៤៧ | និគមនគាថារបស់អ្នករៀបរៀង............................ | ២២១ |
| | នាមសប្បុរសជនចូលរួមធម្មទាន............................ | ២២៣ -២៣៤ |


www.elibraryofcambodia.org

## អារម្ភកថា

ប្រវត្តិព្រះសារីរិកធាតុ ជាប្រវត្តិរឿងរ៉ាវនៃធាតុរបស់ព្រះសម្មាសម្ពុទ្ធ ដែលព្រះអង្គទ្រង់ត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណ ហើយទ្រង់ប្រកាសសំដែងនូវសច្ចធម៌ ប្រោសសត្វលោកឱ្យជួបនូវអមតធម៌ គឺព្រះនិព្វានគណនារាប់ត្រាប្រមាណមិនបាន ។ ព្រះសម្មាសម្ពុទ្ធព្រះអង្គមិនមែនមានព្រះមហាករុណាសំដែងធម៌ប្រោសសត្វលោកឱ្យបានសម្រេចនូវព្រះនិព្វាន ដែលជាបរមសុខជាទីបំផុតនោះទេ ។ តែព្រះអង្គក៏ទ្រង់ត្រាស់សំដែងធម៌ដែលនាំមកនូវសេចក្តីសុខដល់សត្វលោកទាំងពួង និង បរលោកផងដែរ ។ ក្នុងរវាង ៤៥ វស្សា ដែលព្រះអង្គទ្រង់ត្រាស់ដឹង ព្រះអង្គបានបំភ្លឺនូវសច្ចធម៌ដល់សត្វដែលពោរពេញដោយអវិជ្ជា ទោះបីបុគ្គលនោះ មិនបានចាក់ធ្លុះបដិវេធធម៌ក៏ដោយ តែកាលណាបានស្តាប់ បានសិក្សានូវព្រះធម៌ដែលព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់ត្រាស់សំដែងក៏មានបញ្ញាភ្លឺថ្លា ឬអាចមានឧបនិស្ស័យតទៅខាងមុខទៀត ។ ក្រោយពីព្រះសម្មាសម្ពុទ្ធទ្រង់បំពេញពុទ្ធកិច្ច ៥ ប្រការអស់ ៤៥ វស្សាហើយ ព្រះអង្គក៏ទ្រង់បរិនិព្វានក្រោមដើមសាលព្រឹក្សទាំងគូ នាក្រុងកុសិនារា ។ ព្រះអរហន្តសម្មាសម្ពុទ្ធ ទោះបីព្រះអង្គទ្រង់បរិនិព្វានបាត់ព្រះរូបព្រះកាយទៅហើយក៏ដោយ ចំពោះព្រះធាតុព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់អធិដ្ឋានឱ្យ

www.elibraryofcambodia.org

តាំងនៅរហូត ៥០០០ វស្សា ដើម្បីប្រយោជន៍ដល់ មនុស្ស ទេវតា នាគ ព្រហ្មជាដើម ។

រឿងរ៉ាវនៃព្រះធាតុ ព្រះសម្មាសម្ពុទ្ធនេះហើយ ឈ្មោះថាប្រវត្តិព្រះបរមសារីរិកធាតុ ដែលខ្ញុំបានដកស្រង់ចេញពីព្រះត្រៃបិដក អដ្ឋកថា ដីកា និង បករណវិសេសជាដើម យកមកពោលពីការមកនៃព្រះធាតុ របស់ព្រះសម្មាសម្ពុទ្ធឱ្យប្រាកដច្បាស់ក្នុងសៀវភៅនេះ ។ម្យ៉ាងទៀត កាលខ្ញុំនៅបព្វជិតនៅឡើយ ខ្ញុំធ្លាប់បានសំដែងនូវព្រះធាតុរបស់ព្រះសម្មាសម្ពុទ្ធ ដែលមានខ្នាត ពណ៌ ប្រមាណពិតប្រាកដត្រឹមត្រូវក្នុងព្រះត្រៃបិដក អដ្ឋកថា ដីកា ជាមួយព្រះសង្ឃ ៤ រូបទៀត ព្រមជាមួយលោកអគ្គបណ្ឌិត ម៉ុត សាខឡូ ក្នុងកម្មវិធីបុណ្យបញ្ចុះបឋមសិលាក្នុងវត្តនិគ្រោធវ័ន (គល់-ទទឹង) ហើយខ្ញុំក៏មានថេរដីកាថា ប្រវត្តិព្រះបរមសារីរិកធាតុនេះ ខ្ញុំបានសរសេរជាសំណៅរួចហើយ នឹងមានបំណងចេញបោះផ្សាយក្នុងពេលខាងមុខនេះ ។ ខាងក្រោយមក ខ្ញុំក៏បានលាចាកសិក្ខា ពីព្រះភិក្ខុសង្ឃមកជាគ្រហស្ថដោយមានរោគាពាធ តែទោះបីខ្ញុំសឹកពីព្រះសង្ឃហើយក៏ដោយ ចំពោះឆន្ទៈរបស់ខ្ញុំថា នឹងធ្វើសៀវភៅព្រះបរមសារីរិកធាតុនេះឱ្យបាននោះ ក៏ដក់នៅក្នុងចិត្តរបស់ខ្ញុំជានិច្ច ។ ឥឡូវនេះ ឆន្ទៈរបស់ខ្ញុំក៏បានសម្រេចដូចបំណងមែនព្រោះខ្ញុំបានមកធ្វើការ ជាសមាជិកក្រុមជំនុំព្រះត្រៃបិដកប្រចាំវិទ្យាស្ថាន-

www.elibraryofcambodia.org

ពុទ្ធសាសនបណ្ឌិត្យ ហើយក៏មានឱកាសរៀបចំអត្ថបទ ប្រវត្តិព្រះបរមសា-
រីរិកធាតុធ្វើរួចហើយនោះ វាយឱ្យទៅជាអក្សរកុំព្យូទ័រយ៉ាងស្អាតល្អហើយក៏
បានបោះពុម្ពផ្សាយជាធម្មទាន ។

ចំពោះនៅក្នុងអត្ថបទនេះ លោកអ្នកអានប្រាកដជាពេញចិត្តមិនខាន
ព្រោះធាតុរបស់ព្រះសម្មាសម្ពុទ្ធ នៅប្រទេសកម្ពុជាយើងមានការពោលផ្សេង
គ្នាខ្លះ ដូចពាក្យថា ព្រះធាតុខ្នាតកណ្តាលមានពណ៌ដូចកែវផលិក, ព្រោះធាតុ
ខ្នាតតូចមានពណ៌ដូចផ្កាថ្កុល តែខ្ញុំរៀបចំព្រះធាតុនេះ ឱ្យត្រឹមត្រូវតាមគម្ពីរ
ព្រះត្រៃបិដក អដ្ឋកថា ដីកា និង បករណវិសេស ដូចថា "ព្រះធាតុខ្នាត
កណ្តាលមានពណ៌ដូចកែវមុក្តា, ព្រះធាតុខ្នាតតូចមានពណ៌ដូចផ្កាម្លិះជាដើម
តែពោលសាធកៈរបស់ខ្ញុំគឺមានក្នុងព្រះត្រៃបិដក អដ្ឋកថា ដីកា និង បករ-
ណវិសេស ភាគណា ទំព័រណា ខ្ញុំក៏លើកភាគនោះ ទំព័រនោះ មកជាសាធកៈ
គ្រឿងអាង (Reference) ។ ខ្ញុំសរសេរប្រវត្តិព្រះបរមសារីរិកធាតុនេះ
មិនមែនដោយអត្តនោម័តិរបស់ខ្ញុំទេ សរសេរដោយមានគម្ពីរជាគោលអាង
ពិតប្រាកដត្រឹមត្រូវ ។

ហើយនៅក្នុងអត្ថបទនេះទៀត ខ្ញុំក៏បានដាក់អត្ថបទឈ្មោះថា **ព្រះ
ចេតិយ** ដែលជាចេតិយតម្កល់ព្រះធាតុព្រះសម្មាសម្ពុទ្ធជាដើម ដើម្បីឱ្យ

www.elibraryofcambodia.org

អ្នកអានចាប់អារម្មណ៍ទៅលើព្រះធាតុហើយនោះ នឹងមានសេចក្តីជ្រះថ្លាក្នុងព្រះចេតិយ ។ ចំពោះរឿងរ៉ាវនៃព្រះចេតិយយ៉ាងណា ៗ នោះមានខាងក្នុងអត្ថបទនេះស្រាប់ហើយ ខ្ញុំមិនបាច់ពណ៌នានាំឱ្យវែងឆ្ងាយនោះទេ ។

ម្យ៉ាងទៀតនៅក្នុងអត្ថបទនេះ ក៏មានឈ្មោះពិធីពុទ្ធាភិសេក ដែលទំនៀមទំលាប់ប្រពៃណីរបស់យើងដែលខ្ញុំរៀបរៀងអត្ថបទនេះឡើង បំណងចង់ឱ្យពុទ្ធបរិស័ទ ចេះធ្វើពិធីពុទ្ធាភិសេកឱ្យបានត្រឹមត្រូវតាមបោរាណាចារ្យដែលធ្លាប់បានធ្វើរាប់រយឆ្នាំមកហើយ កុំឱ្យលាយឡំនឹងរឿងផ្សេង ដែលមិនសមគួរក្នុងព្រះពុទ្ធសាសនា ។

នៅក្នុងអត្ថបទនេះ ខ្ញុំខិតខំអស់ពីកម្លាំងកាយកម្លាំងចិត្តដើម្បីកុំឱ្យមានការភ្លាំងភ្លាត់ តែទោះជាយ៉ាងណាក៏ដោយ ក៏នៅតែមានភ្លាំងភ្លាត់ខ្លះមិនខានទេ ។ ព្រោះហេតុនោះ ខ្ញុំសូមអធ្យាស្រ័យអភ័យទោសពីវិញ្ញូជនទាំងឡាយ ដែលជាអ្នកឈ្លាសក្នុងគម្ពីរទាំងឡាយផង ។

ដោយបុណ្យកុសលធ្វើសៀវភៅនេះមុនដំបូង កូនសូមលុតជង្គង់លើកហត្ថប្រណម្យជូនចំពោះ លោកឪពុក **ឈុន ឈាវ** អ្នកម្តាយ **ហ៊ីន់ ណាអ៊ី** ដែលកំពុងមានជន្មាយុរស់នៅឡើយ ដែលជាអ្នកបង្កើតខ្ញុំក្នុងអត្តភាពនេះ ហើយបានឱ្យសិក្សារៀនសូត្រនូវព្រះពុទ្ធវចនៈរបស់ព្រះសម្មាសម្ពុទ្ធ សូមឱ្យលោកឪពុកអ្នកម្តាយ ទទួលនូវធម្មបណ្ណាការនេះទុកដូចលោកឪពុលអ្នកម្តាយ

www.elibraryofcambodia.org

ធ្វើដោយផ្ទាល់ខ្លួនឯងចុះ ។

ខ្ញុំសូមលើកបុណ្យកុសលនេះប្រគេន ដល់លោកម្ចាស់គ្រូរបស់ខ្ញុំគឺលោកម្ចាស់ (មេត្តាបាលោ) **នឹម សឿត** ប្រធានដឹកនាំវត្តនិគ្រោធវ័ន និងព្រះសង្ឃគ្រប់ព្រះអង្គទាំងអស់ ។

ហើយលើកបុញ្ញរាសីនេះ ជូនលោកគ្រូ **អគ្គបណ្ឌិត ប៊ុត សាវង្ស** លោកគ្រូ **រស់ សុផាត** លោកគ្រូ **សួន និសថ** លោកគ្រូ **តាំ អ៊ីច** ព្រមទាំងពុទ្ធបរិស័ទដែលស្គាល់ខ្ញុំនិងពុទ្ធបរិស័ទទូទាំងសកលលោក សូមអនុមោទនាយកមហាកុសលនេះផង ហើយសូមបានជាបច្ច័យរួចចាកវដ្តសង្សារគ្រប់ព្រះអង្គគ្រប់គ្នាក្នុងពេលអនាគតឆាប់ ៗ កុំបីខានឡើយ ។

**ពិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ**

ថ្ងៃ ៧ រោច ខែស្រាពណ៍ ព.ស. ២៥៤៧

ត្រូវនឹងថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៣

**លោក ម៉ាន់ ចាន់សារីន**

ក្រុមជំនុំព្រះត្រៃបិដកប្រចាំវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

www.elibraryofcambodia.org

## បទនមស្សការ

បារមីតិទុក្ករំ ប្ឫរិយាន សេដ្ឋពោធី
បាបុណិត្វា យោ អនន្ត- ធម្មសារទំ នមាមិ ។
ភគវតោ សារីរិកំ សេដ្ឋំ ធាតុំ វរំ លោកេ
វរុត្តមំ ចេតិយញ្ច ពុទ្ធាភិសេកំ វន្ទាមិ ។

ព្រះដ៏មានព្រះភាគអង្គណាទ្រង់បំពេញនូវបារមីដែលសត្វលោកធ្វើបានដោយកម្រ ហើយទ្រង់បានសម្រេចនូវព្រះសព្វញ្ញុតញ្ញាណ បង្កឲ្យកើតនូវសារធម៌រកទីបំផុតមិនមាន ខ្ញុំព្រះករុណា (វ៉ាន់ ចាន់សារ៉ឺន) សូមក្រាបថ្វាយបង្គំចំពោះព្រះដ៏មានព្រះភាគអង្គនោះ ដោយគោរព ។

ខ្ញុំព្រះករុណា នឹងពោលនូវព្រះសារីរិកធាតុដ៏ប្រសើរខ្ពង់ខ្ពស់នៃព្រះដ៏មានព្រះភាគដែលទ្រង់ត្រាស់ដឹងក្នុងលោក និង ព្រះចេតិយដ៏ប្រសើរបំផុតនិងពុទ្ធាភិសេកដែលបោរាណាចារ្យធ្វើៗមក ។

www.elibraryofcambodia.org

# ប្រវត្តិព្រះបរមសារីរិកធាតុ

## ពុទ្ធកិច្ចរបស់ព្រះអរហន្តសម្មាសម្ពុទ្ធ

ព្រះពុទ្ធកិច្ចគឺ កិច្ចដែលព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយទ្រង់ប្រតិបត្តិជានិច្ចក្រោយអំពីត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណ ដោយបញ្ញាដ៏កំពូលរបស់ព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់បំពេញពុទ្ធចរិយាដែលជាប្រយោជន៍ដល់សត្វលោក ទ្រង់ត្រាស់សំដែងធម៌ប្រោសវេនេយ្យសត្វដោយព្រះមហាករុណារបស់ព្រះអង្គ ទ្រង់ដឹកនាំសត្វលោកឱ្យប្រកបដោយសេចក្ដីសុខ ឱ្យតាំងនៅក្នុងសរណៈឱ្យរួចផុតចាកទុក្ខឱ្យបន្ទុះអមតធម៌ មិនថាព្រះអង្គគង់ក្នុងទីណាទេ ព្រះអង្គទ្រង់មិនលះនូវកិច្ច៥យ៉ាង គឺកិច្ចក្នុងបុរេភត្ត កិច្ចក្នុងបច្ឆាភត្ត កិច្ចក្នុងបឋមយាម កិច្ចក្នុងមជ្ឈិមយាម និងកិច្ចក្នុងបច្ឆិមយាម ដូចបោរាណាចារ្យប្រព័ន្ធជាគាថាទុកថា ៖

**បុព្វណ្ហេ បិណ្ឌបាតញ្ច　　　សាយណ្ហេ ធម្មទេសនំ**

www.elibraryofcambodia.org

**បគេ សោសេ ភិក្ខុឱវាទំ អឌ្ឍរត្តេ ទេវបញ្ហនំ**
**បច្ចូសេវ គតេ កាលេ ភព្វាភព្វេ វិលោកនំ**
**ឯតេ បញ្ចវិធេ កិច្ចេ វិសោធេតិ មុនិបុង្គវោ ។**

ព្រះសម្មាសម្ពុទ្ធជាចម្បងជាងអស់អ្នកប្រាជ្ញ ទ្រង់ជម្រះនូវពុទ្ធកិច្ចទាំងឡាយ៥ប្រការនេះគឺក្នុងពេលព្រឹកទ្រង់ត្រាច់ទៅបិណ្ឌ-បាត១ក្នុងពេលល្ងាចទ្រង់សំដែងធម៌ទេសនា១ ក្នុងពេលព្រលប់ទ្រង់ប្រទានឱវាទដល់ពួកភិក្ខុ ១ ក្នុងពេលអាធ្រាតទ្រង់ដោះប្រស្នានៃទេវតា១ក្នុងពេលជិតភ្លឺ ទ្រង់ប្រមើលមើលនូវសត្វលោកដែលគួរត្រាស់ដឹងនិងមិនគួរត្រាស់ដឹង១ ។

### កិច្ចក្នុងបុរេភត្ត

ព្រះដ៏មានព្រះភាគទ្រង់ក្រោកពីបន្ទំ ទ្រង់បដិបត្តិសរីរៈហើយទ្រង់ប្រថាប់លើពុទ្ធាសនៈ ដើម្បីរង់ចាំវេលាត្រាច់ទៅបិណ្ឌបាតទ្រង់គ្រងចីវរ កាន់បាត្រ ទ្រង់និមន្តទៅបិណ្ឌបាត្រក្នុងស្រុកឬនិគម ។ ជួនកាលព្រះអង្គទ្រង់ទៅតែមួយអង្គឯង ជួនកាលទ្រង់និមន្តទៅជាមួយសាវ័ក។ មនុស្សទាំងឡាយនាំគ្នាបូជាផ្កាឈើ និងគ្រឿងក្រអូបជាដើមចំពោះ

www.elibraryofcambodia.org

ព្រះអង្គ ហើយក្រាបទូលអារាធនាថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គ ប្រោសប្រទានភិក្ខុ ឱ្យខ្ញុំព្រះអង្គ១០អង្គខ្លះ ២០ អង្គខ្លះ ៣០ អង្គខ្លះជាដើម ដើម្បីទទួលអាហារបិណ្ឌបាតក្នុងផ្ទះរបស់ខ្ញុំព្រះអង្គ។ ហើយទទួលបាត្រព្រះដ៏មានព្រះភាគ ក្រាលអាសនៈ បង្អោនអាហារបិណ្ឌបាតថ្វាយដោយគោរព ។ កាលភត្តកិច្ចសម្រេចហើយទ្រង់សំដែងធម្មទេសនាប្រោសជនទាំងនោះ អ្នកខ្លះតាំងនៅក្នុងសរណគមន៍ សោតាបត្តិផល សកទាគាមិផល អនាគាមិផល ។ ព្រះដ៏មានព្រះភាគទ្រង់អនុគ្រោះមហាជន ដូច្នេះហើយ ទ្រង់និមន្តត្រឡប់ទៅវត្តវិញ រង់ចាំភិក្ខុទាំងឡាយត្រឡប់ពីបិណ្ឌបាត្រ ។គ្រាភិក្ខុទាំងឡាយធ្វើភត្តកិច្ចស្រេចហើយ ភិក្ខុជាឧបដ្ឋាកទើបក្រាបទូលឱ្យទ្រង់ជ្រាប ។ ព្រះពុទ្ធអង្គស្តេចទ្រង់យាងទៅគង់ក្នុងសាលាហើយឱ្យឱវាទដល់ព្រះភិក្ខុសង្ឃថា ៖

**ការកើតជាមនុស្សរកបានដោយកម្រ**

**ការត្រាស់ដឹងជាព្រះពុទ្ធ ក៏រកបាន**

**ដោយកម្រ ព្រះសទ្ធម្មរកបានដោយ**

**កម្រក្រៃលែង ការដល់ព្រមដោយ**

www.elibraryofcambodia.org

**សទ្ធារកបានដោយកម្រ ការបាន**
**បញ្ញារកបានដោយកម្រ ការស្តាប់ព្រះសទ្ធម្ម**
**រកបានដោយកម្រក្រៃលែង ។**

ក្នុងទីនោះ ភិក្ខុទូលសួរកម្មដ្ឋាន ព្រះដ៏មានព្រះភាគក៏ទ្រង់ប្រទានកម្មដ្ឋានសមគួរដល់ចរិតរបស់ភិក្ខុទាំងនោះ បន្ទាប់ពីនោះមក ភិក្ខុទាំងនោះថ្វាយបង្គំលាព្រះដ៏មានព្រះភាគ ហើយទៅកាន់ទីសម្រាក់កណ្តាលថ្ងៃរៀង១ខ្លួន គឺក្នុងព្រៃខ្លះ ទៀបគល់ឈើខ្លះ តាមភ្នំនិងគុហាខ្លះ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់យាងចូលទៅកាន់គន្ធកុដិ បើសិនទ្រង់មានបំណងនឹងសឹងក៏ទ្រង់សឹងមួយភ្លែត ហើយក៏ទ្រង់ក្រោកឡើងរមិលមើលឧបនិស្ស័យរបស់សត្វក្នុងស្រុកឬតំបន់ ដែលព្រះអង្គទ្រង់និមន្តទៅគង់នោះ **នេះជាកិច្ចក្នុងបុរេភត្ត** ។

**កិច្ចក្នុងបច្ឆាភត្ត**

**ក្នុងពេលល្ងាចទ្រង់សំដែងធម្មទេសនា**

ក្នុងពេលល្ងាច កាលបានវេលាសមគួរហើយ មហាជននាំគ្នា

www.elibraryofcambodia.org

កាន់យកផ្កាឈើ និងគ្រឿងក្រអូបជាដើម ចូលទៅទីប្រជុំក្នុងព្រះវិហារ កាលបរិស័ទជួបជុំគ្នាហើយ ព្រះដ៏មានព្រះភាគទ្រង់និមន្តមកគង់លើ ពុទ្ធាសានៈដ៏ប្រសើរ ហើយទ្រង់សំដែងនូវព្រះធម៌ សមគួរតាមពេល វេលា និងចរិតរបស់ជនទាំងនោះ កាលចប់ធម្មទេសនាហើយមហាជន ទាំងនោះ ក៏ថ្វាយបង្គំលាព្រះដ៏មានព្រះភាគចៀសចេញទៅ **នេះជាកិច្ច ក្នុងបច្ឆាភត្ត** ។

## កិច្ចក្នុងបឋមយាម
## ក្នុងពេលព្រលប់ទ្រង់ប្រទានឱវាទដល់ភិក្ខុ

ក្រោយពីទ្រង់សម្រេចកិច្ចក្នុងបច្ឆាភត្តហើយ បើទ្រង់មានប្រាថ្នា ស្រង់ទឹក ក៏ទ្រង់ចូលទៅកាន់បន្ទប់ទឹកស្រោចស្រង់ព្រះវរកាយ ស្រេច ហើយទ្រង់គ្រងចីវរឆៀងស្មាម្ខាងទ្រង់និមន្តទៅគង់លើពុទ្ធាសនៈ ដែល ភិក្ខុជាឧបដ្ឋាកចាត់ចែងទុក ហើយទ្រង់គង់នៅមួយភ្លែតតែមួយអង្គ ឯង ។ កាលភិក្ខុទាំងឡាយនាំគ្នាមកគល់ ភិក្ខុខ្លះទូលសួរបញ្ហា ភិក្ខុខ្លះទូលសូមស្តាប់ធម៌ ព្រះដ៏មានព្រះភាគទ្រង់អនុគ្រោះភិក្ខុទាំង នោះ ទ្រង់កែបញ្ហា ទ្រង់សំដែងព្រះធម៌ហើយប្រទានឱវាទ ព្រះអង្គ

www.elibraryofcambodia.org

ទ្រង់គង់នៅរហូតដល់យាមដើមដោយកិច្ចនេះ ដល់វេលាសមគួរហើយ ភិក្ខុទាំងឡាយថ្វាយបង្គំលាហើយចៀសចេញទៅ **នេះជាកិច្ចក្នុងបឋម-មយាម ។**

## កិច្ចក្នុងមជ្ឈិមយាម

## ក្នុងវេលាអាធ្រាតទ្រង់ដោះប្រស្នានៃទេវតា

កាលព្រះពុទ្ធទ្រង់បញ្ចប់កិច្ចក្នុងបឋមយាមហើយ ទេវតាក្នុងមួយម៉ឺនលោកធាតុ បានឱកាសនាំគ្នាចូលគល់ព្រះដ៏មានព្រះភាគ ទេវតាទាំងនោះនាំគ្នាសួរបញ្ហារៀង១ខ្លួន តាមដែលខ្លួនត្រៀមទុកមក ដោយហោចទៅ សូម្បីបញ្ហាត្រឹមអក្ខរៈ៤តួ ព្រះដ៏មានព្រះភាគក៏ទ្រង់កែបញ្ហាដល់ទេវតាទាំងនោះ ទ្រង់ញ៉ាំងមជ្ឈិមយាមឱ្យកន្លងទៅដោយអនុគ្រោះទេវតាទាំងឡាយយ៉ាងនេះ **នេះជាកិច្ចក្នុងមជ្ឈិមយាម ។**

## កិច្ចក្នុងបច្ឆិមយាម

## ក្នុងពេលជិតភ្លឺទ្រង់ប្រមើលមើលសត្វលោក

កិច្ចក្នុងបច្ឆិមយាម ព្រះដ៏មានព្រះភាគទ្រង់បែងចេញជា ៣ រយៈគឺ

រយៈទី១ ព្រះអង្គទ្រង់ចង្ក្រម

www.elibraryofcambodia.org

រយៈទី២ ព្រះអង្គសម្រេចសីហសេយ្យា

រយៈទី ៣ ព្រះអង្គតើនឡើងរមិលមើលសត្វលោក ។ ក្នុងគម្ពីរសុមង្គលវិលាសិនី អដ្ឋកថា ព្រហ្មជាលសូត្រ និង អដ្ឋកថាធម្មបទ ពោលថា ព្រះសម្មាសម្ពុទ្ធគ្រប់ៗព្រះអង្គទ្រង់ផ្សាយសំណាញ់ញាណប្រមើលមើលសត្វលោកក្នុងមួយថ្ងៃពីរដងគឺ ក្នុងវេលាជិតភ្លឺនិងក្នុងវេលាល្ងាច ទ្រង់ពិចារណាចំពោះបុគ្គលមានបុញ្ញាធិការសន្សំមកហើយដោយអំណាចទាននិងសីល ក្នុងសំណាក់ព្រះពុទ្ធអង្គមុន ៗ ដើម្បីទ្រង់និមន្តទៅប្រោសជនទាំងនោះឱ្យបានសម្បត្តិមនុស្ស ទេវតា ឬព្រះនិព្វានតាមបុញ្ញបារមីរបស់មនុស្សម្នាក់ ៗ ដោយទ្រង់មិនគិតថាផ្លូវនោះជិតឬឆ្ងាយទេ **នេះជាកិច្ចក្នុងបច្ឆិមយាម** ។

លោកពោលថាគ្រាពុទ្ធកាលក្នុងស្ថានទីមានភិក្ខុសូម្បីត្រឹមតែមួយអង្គលោកក៏ចាត់ចែងពុទ្ធាសនៈទុកដើម្បីទទួលព្រះសម្មាសម្ពុទ្ធ ព្រោះកាលព្រះសាស្តាទ្រង់មនសិការៈ ដល់ភិក្ខុអ្នកទទួលកម្មដ្ឋានពីព្រះអង្គទៅហើយ ក៏នឹងរមិលមើលថាភិក្ខុនោះនឹងអាចញ៉ាំងគុណវិសេសឱ្យកើតឡើងបានឬទេ គ្រាទ្រង់ជ្រាបថា ភិក្ខុណាលះកម្មដ្ឋានចោល ត្រិះ

www.elibraryofcambodia.org

រិះអកុសលវិតក្កៈជាដើមដើម្បីព្រះអង្គទ្រង់និមន្តទៅទីនោះដោយពុទ្ធា-នុភាព គង់លើពុទ្ធាសនៈដែលភិក្ខុចាត់ចែងទុកប្រទានឱ្យឱវាទអនុគ្រោះភិក្ខុនោះឱ្យសម្រេចប្រយោជន៍ ហើយព្រះអង្គនិមន្តត្រឡប់ទៅកាន់ទីគង់ព្រះអង្គវិញ ។

ព្រះអរហន្តសម្មាសម្ពុទ្ធព្រះអង្គទ្រង់បំពេញពុទ្ធកិច្ចទាំង ៥ នេះ អស់ ៤៥ វស្សា ដើម្បីប្រយោជន៍ដល់សត្វលោកតែម្យ៉ាង មិនមានបំណងប៉ងប្រាថ្នាអ្វីបន្តិចបន្តួចពីសត្វលោកឡើយ ព្រះអង្គទ្រង់បំពេញពុទ្ធចរិយា មិនគិតពីការនឿយហត់លំបាកកាយឡើយ ឱ្យតែសត្វលោកបានរួចផុតចាកទុក្ខ បានត្រាស់ដឹងនូវអរិយសច្ចធម៌ ។ ព្រះអង្គទ្រង់បំពេញពុទ្ធកិច្ចអស់ ៤៥ ឆ្នាំហើយ ក្នុងថ្ងៃអង្គារ ១៥ កើត ខែ ពិសាខ មុនពុទ្ធសករាជ ១ ថ្ងៃ ព្រះអង្គទ្រង់ចូលបរិនិព្វានក្រោមសាលព្រឹក្សទាំងគូ ដោយអនុបាទិសេសនិព្វាន ។ ព្រះបរមសពនៃព្រះអរហន្ត-សម្មាសម្ពុទ្ធ ត្រូវពួកមនុស្ស ទេវតា ព្រហ្ម ជាដើមនាំគ្នាបូជាយ៉ាងសន្ធឹកសន្ធាប់ជាទីបំផុត ហើយបានដង្ហែយកទៅបូជាត្រង់មកុដពន្ធនចេតិយ ។ ក្នុងថ្ងៃទី ៧ បន្ទាប់ពីព្រះអង្គទ្រង់បរិនិព្វានព្រះបរមសព ដែលតម្កល់លើ

www.elibraryofcambodia.org

ចិតកាធាន ត្រូវភ្លើងឆេះឡើងដោយអំណាចនៃទេវតាបណ្តាលឱ្យឆេះ ព្រះបរមសពនៃព្រះដ៏មានព្រះភាគអស់រូបរាងកាយ ធារទឹកបានធ្លាក់ហូរចុះពីលើអាកាសបានពន្លត់ចិតកាធានរបស់ព្រះសាស្តា នៅសល់តែព្រះបរមធាតុនៃព្រះដ៏មានព្រះភាគប៉ុណ្ណោះ ។ ពួកមល្លក្សត្របានអារាធនាព្រះបរមសារីរិកធាតុទាំងអស់ ទៅដាក់ទុកក្នុងសុវណ្ណទោណ ប្រោសព្រំដោយទឹកក្រអូបគ្រប់ប្រភេទ រោយរាយគន្ធជាតិក្នុងសុវណ្ណទោណ ហើយបាននាំសុវណ្ណទោណទៅប្រតិស្ឋានលើដីរីដែលប្រដាប់តាក់តែងហើយ និងបូជាដោយវត្ថុទាំងឡាយដោយមានកម្រងផ្កានិងគ្រឿងក្រអូបជាដើម ហើយក៏នាំយកព្រះបរមសារីរិកធាតុចូលទៅកាន់ក្នុងនគរ តម្កល់ទុកលើសត្តរតនមយបល្ល័ង្ក គឺបល្ល័ង្កដែលធ្វើដោយរតន ៧ ប្រការ ក្នុងសណ្ឋាគារបាំងស្វេតឆ័ត្រពីខាងលើ ហើយនាំគ្នារៀបចំធ្វើសក្ការបូជាចំពោះព្រះបរមសារីរិកធាតុនៃព្រះដ៏មានព្រះភាគ រហូតអស់ ៧ ថ្ងៃទៀត ។

## ការចែកព្រះបរមសារីរិកធាតុ

ក្នុងកាលនោះព្រះរាជាក្នុងដែនផ្សេងៗ មានព្រះបាទមាគធ-

www.elibraryofcambodia.org

អជាសត្តុជាដើមទ្រង់បានឮដំណើងថា ព្រះដ៏មានព្រះមានព្រះភាគទ្រង់បរនិព្វានហើយក្នុងក្រុងកុសិនារា ហើយបញ្ជូនរាជទូតទៅកាន់សំណាក់នៃពួកមល្លក្សត្រអ្នកក្រុងកុសិនារាថា ព្រះដ៏មានព្រះភាគជាក្សត្រយើងក៏ជាក្សត្រ យើងគួរបានចំណែកនៃព្រះសារីរិកធាតុ របស់ព្រះដ៏មានព្រះដែរ យើងធ្វើស្តូបផង ការបូជាផងចំពោះព្រះសារីរិកធាតនៃព្រះដ៏មានព្រះភាគ ។ តែពួកមល្លក្សត្រគិតថា ធម្មតាពុទ្ធរតនៈជាវត្ថុដ៏ប្រសើរបំផុតក្នុងលោក ព្រមទាំងទេវលោក ក៏រតនៈនេះកើតក្នុងតាមក្ខេត្តរបស់យើង យើងមិនព្រមឱ្យដល់អ្នកណាទេ ។

កាលបើពួកមល្លក្សត្រមិនព្រមចែកព្រះសារីរិកធាតុយ៉ាងនេះ ព្រះរាជានិងព្រាហ្មណ៍ទាំងអស់នោះ ចាប់ផ្តើមនាំគ្នាធ្វើការចម្បាំងដើម្បីដណ្តើមយកព្រះសារីរិកធាតុ ។ ក៏រៀបចំកងទ័ពរៀង៧ខ្លួនដើម្បីឡោមព័ទ្ធក្រុងកុសិនារា ។ ឯពួកមល្លក្សត្រអ្នកក្រុងកុសិនារាវិញ ក៏បានរៀបចំកងទ័ពតតាំងច្បាំងវិញដែរ ។ ក្នុងកាលណោះទោណព្រាហ្មណ៍គាត់ជាអាចារ្យរបស់ក្សត្រនិងព្រាហ្មណ៍ទាំងនោះ ឃើញការវិវាទទាស់ទែងគ្នា ដោយសារព្រះសារីរិកធាតុជារឿងមិនសមគួរទាល់តែសោះ ទើប

www.elibraryofcambodia.org

ឡើងទៅឈរលើកំពែងទីខ្ពស់ស្រែកឡើងថា ៖

លោកទាំងឡាយដ៏ចំរើន សូមស្តាប់ពាក្យខ្ញុំមួយម៉ាត់សិន ព្រះពុទ្ធជាម្ចាស់នៃយើង ព្រះអង្គជាខន្តិវាទ ( អ្នកពោលសរសើរនូវខន្តិមែនពិត ) ការប្រហារគ្នា ច្បាំងគ្នា ព្រោះចំណែកនៃព្រះសារីរិកធាតុរបស់ឧត្តមបុរសនេះ មិនប្រពៃឡើយ ។ បពិត្រលោកដ៏ចំរើនទាំងឡាយ យើងទាំងអស់គ្នា គួរតែស្រុះស្រួលគ្នា ព្រមព្រៀងគ្នា រីករាយរកគ្នា ចែកព្រះសារីរិកធាតុឱ្យជា៨ចំណែក ព្រះស្តូបទាំងឡាយ សូមផ្សាយទៅក្នុងទិសទាំងឡាយចុះ ពួកជនច្រើនជ្រះថ្លាចំពោះព្រះសម្ពុទ្ធមានចក្ខុមិនលែង[១] ។

កាលទោណព្រាហ្មណ៍ពោលពាក្យនេះ លើកទី ១ គ្មានអ្នកណាយកចិត្តទុកដាក់ស្តាប់ឡើយ ព្រោះម្នាក់ៗគិតតែថា ត្រូវច្បាំង ៗ។ តែអាស្រ័យទោណព្រាហ្មណ៍គាត់ជាអាចារ្យរបស់ក្សត្រ និង ព្រាហ្មណ៍ទូទាំងជម្ពូទ្វីប មិនមានក្សត្រនិងព្រាហ្មណ៍ណាមួយថា មិនស្គាល់ឡើយ ។

---

(១)សុត្ត. ទី. មហាវគ្គ. ១៦ / ៣៨៦

www.elibraryofcambodia.org

ទើបទោណព្រាហ្មណ៍ស្រែកប្រកាសយ៉ាងខ្លាំងជាពីរដងថា៖ ពួកលោកចាំសំឡេងអាចារ្យរបស់ខ្លួនមិនបានទេឬ ? ប្រសិនបើចាំបាន សូមស្ងាត់ស្ងៀមគ្រប់ ៗ គ្នា ហើយស្ដាប់វាចាដែលខ្ញុំពោល ។ ពួកក្សត្រទាំងនោះ បានឮសំឡេងស្រែកឡើងនោះ ក៏ចាំបានថា នេះជាសំឡេងរបស់ទោណព្រាហ្មណ៍ ជាអាចារ្យរបស់ខ្លួន ហើយក៏នាំគ្នាស្ងៀមស្ងាត់ទៅ ។ ទោណព្រាហ្មណ៍គាត់ ក៏ប្រកាសឡើង ដូចពាក្យមុននោះឯង ដើម្បីបបួលគ្នាចែកព្រះបរមសារីរិកធាតុឱ្យជា ៨ ចំណែកសម្រាប់ក្សត្រនិង ព្រាហ្មណ៍ ៨ នគរ ដែលមកជួបជុំគ្នានៅពេលនោះ ។ ក្សត្រនិងព្រាហ្មណ៍ព្រមតាមទោណព្រាហ្មណ៍ មានឆន្ទៈតែមួយថា នឹងចែកឱ្យបានស្មើៗគ្នា ។ ទោណព្រាហ្មណ៍បានដឹងពីការព្រមព្រៀងគ្នារបស់ក្សត្រនិងព្រាហ្មណ៍ទាំងនោះហើយ ក៏បានបញ្ជាឱ្យគេបើកតុម្ពមាសឡើង ដើម្បីចែកព្រះបរមសារីរិកធាតុ ។ ពេលនោះ ព្រះរាជាទាំងឡាយបានឈរនៅជិតឯតុម្ពមាសនោះ ឃើញនូវព្រះធាតុមានពណ៌ដូចមាស ក៏ខ្សឹកខ្សួលកន្ទក់កន្ទេញថា ព្រះដ៏មានព្រះភាគជាសព្វញ្ញូ ក្នុងកាលមុន យើងបានឃើញសរីរៈរបស់ព្រះអង្គមានពណ៌ដូចមាស ដែលប្រដាប់

www.elibraryofcambodia.org

តាក់តែងហើយ ដោយបុរិសលក្ខណៈ ៣២ ប្រការ ដែលមានឆព្វណ្ណ-រង្សី ៦ ប្រការនិងលម្អរុងរឿងទៅដោយអនុព្យញ្ជនៈ ៨០ ឥឡូវនេះនៅសល់តែព្រះធាតុមានពណ៌ដូចមាសប៉ុណ្ណោះ ។ ឯទោណព្រាហ្មណ៍ដឹងនូវសេចក្តីប្រមាទរបស់ក្សត្រនិងព្រាហ្មណ៍ទាំងនោះ ក៏ចាប់យកទក្ខិណ-ទាឋៈ គឺចង្កូមកែវខាងស្តាំ ដាក់ក្នុងចន្លោះឈ្នួតក្បាល ។ កាលបើក្សត្រនិងព្រាហ្មណ៍ទាំងនោះ បន្ទោបង់សេចក្តីសោកខ្សឹកខ្សួលហើយ ក៏បាននាំគ្នាចែកនូវព្រះធាតុនោះ ៨ ចំណែក គឺ ÷

១.ព្រះបាទមាគធអជាសត្តុវេទេហីបុត្របានទទួលព្រះធាតុមួយចំណែកគឺ ២ នាឡិ យកទៅបញ្ចុះក្នុងស្តូប ( ព្រះចេតិយ ) ក្នុងក្រុងរាជគ្រឹះ ។

២. ពួកក្សត្រលិច្ឆវី បានទទួលមួយចំណែកគឺ ២ នាឡិ យកទៅបញ្ចុះក្នុងស្តូប ក្រុងវេសាលី ។

៣. ពួកក្សត្រអ្នកក្រុងកបិលវត្ថុ បានទទួលមួយចំណែកគឺ ២ នាឡិ យកទៅបញ្ចុះក្នុងស្តូប ក្រុងកបិលវត្ថុ

www.elibraryofcambodia.org

៤. ពួកក្សត្រថូលិ អ្នកក្រុងអល្លកប្បៈ បានទទួលមួយចំណែកគឺ ២ នាឡិ យកទៅបញ្ចុះក្នុងស្តូប ក្រុងអល្លកប្បៈ ។

៥. ពួកក្សត្រកោឡិយៈ អ្នករាមគ្រាម បានទទួលមួយចំណែកគឺ ២ នាឡិ យកទៅបញ្ចុះក្នុងស្តូប ក្នុងរាមគ្រាម ។

៦. ព្រាហ្មណ៍អ្នកវេដ្ឋទីបកៈ បានទទួលមួយចំណែកគឺ ២ នាឡិ យកទៅបញ្ចុះក្នុងស្តូប ក្នុងដែនវេដ្ឋទីបកៈ ។

៧. ពួកមល្លក្សត្រក្រុងបាវ៉ា បានទទួលមួយចំណែកគឺ ២ នាឡិ យកទៅបញ្ចុះក្នុងស្តូប ក្នុងក្រុងបាវ៉ា ។

៨. ពួកមល្លក្សត្រអ្នកក្រុងកុសិនារា បានទទួលមួយចំណែកគឺ ២ នាឡិ យកទៅ បញ្ចុះក្នុងស្តូប ក្នុងក្រុងកុសិនារា ។

ក្នុងកាលណោះ ស្តេចសក្កទេវរាជទ្រង់រមិលមើលថា អ្នកណាយកចង្កូមកែវខាងស្តាំទៅ ? ក៏បានដឹងថា ទោណព្រាហ្មណ៍ជាអ្នកយកទុកក្នុងចន្លោះឈ្នួតក្បាល ក៏បានគិតថា ទោណព្រាហ្មណ៍នេះមិនអាចធ្វើសក្ការៈគោរពបូជាចំពោះចង្កូមកែវនេះបានទេ ហើយក៏យកចង្កូមកែវពីទោណព្រាហ្មណ៍នោះទៅ ។ ឯទោណព្រាហ្មណ៍កាលចែកព្រះ

www.elibraryofcambodia.org

ធាតុអស់ហើយ ក៏យកដៃចាប់មើលចង្កូមកែវត្រង់ឈ្នួតក្បាល មិនឃើញ តែមិនអាចសួរថា អ្នកណាយកចង្កូមកែវទៅ ? ព្រោះខ្លួនជាម្ចាស់ចំណែកហើយ ។ ទោណព្រាហ្មណ៍គិតថា បើដូច្នោះអាត្មាអញនឹងសូមតុម្ពនេះ ជំនួសចង្កូមកែវវិញ ។ ទើបពោលឡើងថា បពិត្រលោកដ៏ចំរើន ខ្ញុំសូមតុម្ពនេះទៅបញ្ចុះក្នុងស្តូប គ្រាន់បានធ្វើសក្ការៈគោរពបូជា ។ ព្រះរាជាទាំងឡាយក៏ព្រមអនុញ្ញាតឱ្យដល់ទោណព្រាហ្មណ៍នោះ ។ ចំណែកពួកក្សត្រមោរិយៈអ្នកក្រុងបិប្ផលិវ័ន មកសូមព្រះធាតុក្រោយគេ មិនបាន ក៏សូមយកព្រះអង្គារៈតធ្យូងយកទៅធ្វើស្តូប ធ្វើការបូជាក្នុងក្រុងរបស់ខ្លួន ។

នៅក្នុងគម្ពីរពុទ្ធវិសរបស់ប្រទេសភូមា ( ច្បាប់ឆដ្ឋសង្គាយនា ) និងគម្ពីរពុទ្ធវិស ( ច្បាប់មហាចុឡាតិបិដក ភាគ ៣៣ ទំព័រ ៩៧៩ ប្រទេសថៃ ) មានបាលីប្រាកដពណ៌នាពីរឿងព្រះធាតុនេះ តែក្នុងគម្ពីរពុទ្ធវិស បិដកខ្មែរយើងលេខ ៧៧ គ្រាន់តែលើកយកបាលីពីបិដកភូមាមកដាក់ជាលេខយោង ត្រង់ទំព័រ ២៣៧ បន្ទាត់ទី ១០ប៉ុណ្ណោះ ។

ឯបាលីនោះថា ៖

www.elibraryofcambodia.org

**ឧណ្ហីសំ ចតស្សោ ទាឋា អក្ខកា ទ្វេ ច ធាតុយោ**
**អសម្ភិន្នា ឥមា សត្ត សេសា ភិន្នា វ ធាតុយោ**

ព្រះសារីរិកធាតុទាំងឡាយនោះ ដែលមិនបែកចេញមាន ៧ អង្គគឺ ព្រះឧណ្ហីសធាតុ (ឆ្អឹងថ្ងាស) ១ ព្រះទាឋធាតុ (ចង្កូមកែវ)៤ ព្រះអក្ខកធាតុ (ឆ្អឹងដងកាំបិត)២ ព្រះសារីរិកធាតុដ៏សេសក្រៅពីនោះ សុទ្ធតែបែកចេញ (ជាចំណែកតូចៗ) ។

**មហន្តា មុគ្គមត្តា ច មជ្ឈិមា ភិន្នតណ្ឌុលា**
**ខុទ្ទកា សាសបមត្តា ច នានាវណ្ណា ច ធាតុយោ**

ព្រះបរមធាតុទាំងឡាយមានខ្នាតផ្សេងៗគ្នាយ៉ាងនេះគឺ ព្រះធាតុខ្នាតធំ មានទំហំប៉ុនគ្រាប់សណ្តែកបាយ ព្រះធាតុខ្នាតកណ្តាល មានទំហំប៉ុន កំណាត់គ្រាប់អង្ករបាក់ ព្រះធាតុខ្នាតតូច មានទំហំប៉ុនគ្រាប់ស្ពៃ ។

**មហន្តា សុវណ្ណវណ្ណា ច មុត្តាវណ្ណា ច មជ្ឈិមា**
**ខុទ្ទកា មកុលវណ្ណា ច សោឡស ទោណមត្តិកា**

ព្រះបរមធាតុទាំងឡាយ មានពណ៌ផ្សេងៗគ្នាយ៉ាងនេះគឺ ព្រះធាតុខ្នាតធំមានពណ៌ដូចមាស ព្រះធាតុខ្នាតកណ្តាលមានពណ៌ដូចកែវមុក្តា

www.elibraryofcambodia.org

ព្រះធាតុខ្នាតតូចមានពណ៌ដូចផ្កាម្លិះ រួមទាំងអស់ប្រមាណ ១៦ នាឡិ ស្មើ ១ ទោណ ។

**មហន្តា បញ្ច នាឡិយោ  នាឡិយោ បញ្ច មជ្ឈិមា**

**ខុទ្ទកា ឆ នាឡិ ចេវ  ឯតា សព្វាបិ ធាតុយោ។**

ព្រះបរមធាតុសូម្បីទាំងអស់នុ៎ះគឺ  ព្រះធាតុខ្នាតធំវាល់បាន ៥ នាឡិ ព្រះធាតុខ្នាតកណ្ដាលវាល់បាន ៥ នាឡិ ព្រះធាតុខ្នាតតូចវាល់បាន ៦ នាឡិ ។

នៅក្នុងគម្ពីរសុមង្គលវិលាសិនី  អដ្ឋកថា មហាបរិនិព្វានសូត្រ ៥/៣៤៧ បានសំដែងថា ÷

កតិ បនស្ស ធាតុយោ វិប្បកិណ្ណា កតិ ន វិប្បកិណ្ណាតិ ។ ចតស្សោ ទាឋា ទ្វេ អក្ខកា ឧណ្ហីសន្តិ ឥមា សត្ត ធាតុយោ ន វិប្បកិរឹសុ សេសា វិប្បកិរឹសូតិ ។ តត្ថ សព្វខុទ្ទកា ធាតុ សាសបពីជមត្តា អហោសិ មហាធាតុ មជ្ឈេ ភិន្នតណ្ឌុលមត្តា អតិមហតី មជ្ឈេ ភិន្នមុគ្គមត្តា ។

ចុះព្រះធាតុរបស់ព្រះសម្មាសម្ពុទ្ធបរមសាស្ដា  បែកជាចំណែកប៉ុន្មាន ?មិនបែកប៉ុន្មានដែរ? ។ ព្រះបរមធាតុព្រះសម្មាសម្ពុទ្ធនៃយើង

www.elibraryofcambodia.org

មិនបែកជាចំណែកតូចមាន ៧ នេះគឺ ព្រះចង្កូមកែវ ៤ ដងកាំបិត ២ ថ្ងាស ១ ឯព្រះធាតុដ៏សេសក្រៅពីនោះសុទ្ធតែបែកជាចំណែកតូច ៗ ។ បណ្ដាព្រះធាតុទាំងនោះ ព្រះធាតុតូចបំផុតប៉ុនគ្រាប់ស្ពៃ .ព្រះធាតុខ្នាតកណ្ដាលប៉ុនគ្រាប់អង្ករបាក់ពាក់កណ្ដាល .ព្រះធាតុខ្នាតធំបំផុតប៉ុនគ្រាប់សណ្ដែកបាយបាក់ពាក់កណ្ដាល ។

## សេចក្ដីបញ្ជាក់

នៅក្នុងបទនមស្សការត្រង់ធាតុចេតិយនមស្សការគាថា ដែលរៀបរៀងដោយ បណ្ឌិត សែម សួរ ក្នុងសៀវភៅប្រជុំភាណវារបាលីប្រែពិស្ដារ ត្រង់ទំព័រ ៣០៣ បន្ទាត់ទី ១៣ មានគាថាថា ÷

**ឧណ្ហីសំ ចតស្សោ ទាឋា អក្ខកា ទ្វេ ច សត្ថមា**
**អសម្ភិន្នា វ ៣ សត្ត សេសា ភិន្នា វ ធាតុយោ**

គាថានេះបានដកចេញពីគម្ពីរបឋមសម្ពោធិត្រង់ទំព័រ ២៦០ តែមិនត្រឹមត្រូវតាមគម្ពីរព្រះត្រៃបិដក ដែលមានក្នុងគម្ពីរពុទ្ធវិសបិដកលេខ ៧៧ ទំព័រ ២៣៧ បន្ទាត់ទី ១១ នោះទេ ។ ចំណែកខ្ញុំអ្នករៀបរៀងអត្ថបទនេះក៏មិនបដិសេធគាថាដែលយើងធ្លាប់សូត្រមកនោះដែរ ។ តែ

www.elibraryofcambodia.org

គម្ពីរបឋមសម្ពោធិនេះទើបរៀបរៀងក្នុងសម័យខាងក្រោយទេ បើសិនមានបាលីមិនត្រឹមត្រូវតាមបិដក អដ្ឋកថា ដីកា យើងមិនអាចកាន់យកបានឡើយ ។

ដូចគាថាក្នុងព្រះត្រៃបិដកថា **មុត្តាវណ្ណា ច មជ្ឈិមា** ព្រះធាតុខ្នាតកណ្ដាលមានពណ៌ដូចកែវមុក្ដា តែក្នុងបឋមសម្ពោធិនិងយើងធ្លាប់សូត្រមកថា **មជ្ឈិមា ផលិកប្បភា** ព្រះធាតុខ្នាតកណ្ដាលមានពណ៌ដូចកែវផលិកដូច្នេះគាថានេះប្រាកដជាមិនត្រឹមត្រូវតាមព្រះត្រៃបិដកទេ។ ដូចគាថាក្នុងព្រះត្រៃបិដកមួយបាទទៀតថា **ខុទ្ទកា មកុលវណ្ណា ច** ព្រះធាតុខ្នាតតូចមានពណ៌ដូចផ្កាម្លិះ ស្រាប់តែក្នុងបឋមសម្ពោធិនិងយើងធ្លាប់សូត្រមកថា **ខុទ្ទកា ពកុលវណ្ណា** ព្រះធាតុខ្នាតតូចមានពណ៌ដូចផ្កាផ្កុល បាទគាថានេះក៏មិនត្រឹមត្រូវតាមព្រះត្រៃបិដកនិងអដ្ឋកថា ព្រោះហេតុនោះ មិនអាចកាន់យកបានឡើយ ។ តាមពិត **មកុល** ស័ព្ទមិនមែនប្រែថា ផ្កាម្លិះតែម្ដងទេ តែក្នុងគាថានេះ អាស្រ័យច្បាប់ឆន្ទទើបកាត់ពាក្យ **សុមនះ** ចេញដែលប្រែថា ផ្កាម្លិះនោះ ។ ពាក្យថា **មកុល** ក្នុងគម្ពីរ អភិធានប្បទីបិកា និង អភិធានប្បទីបិកាដីកាត្រង់

www.elibraryofcambodia.org

សូត្រ ៥៤៤ថា **មកុល (មុច មោចនេ + ឧល)** ប្រែថា ផ្កាឈើក្ដោប ឬផ្កាឈើក្រពុំ វិ. **មុចតីតិ មកុលោ** ផ្កាឈើដែលលាស់ចេញ ឈ្មោះថា **មកុល** (អាទេស គឺផ្លាស់ ឧ ជា អ, ច ជា ក) ។ មានក្នុង អដ្ឋកថា មជ្ឈិមនិកាយថា **កមលុប្បលាទីនិ ឯកស្មឹ កាលេ វិកសន្តិ ឯកស្មឹ មកុលានិ ហោន្តិ**[១] ។ ផ្កាឈូកក្រហមនិងឧប្បលជាដើម តែងរីកក្នុងវេលាមួយ តែងក្ដោបទៅក្នុងវេលាមួយ ។ ចុះពាក្យថា **មកុល** ប្រែថា ក្ដោប ឬក្រពុំ ហេតុអ្វីបានជាហ៊ានប្រែថា ផ្កាម្លិះនោះទៅវិញ ? បានជាហ៊ានប្រែថាផ្កាម្លិះនោះ ព្រោះអាងគម្ពីរ សុមង្គល-វិលាសិនី អដ្ឋកថា មហាបរិនិព្វានសូត្រ ៥/៣៤៧ថា ៖

**សុមនមកុលសទិសា ច ធោតមុត្តាសទិសា ច សុវណ្ណ-ចុណ្ណសទិសា ច ធាតុយោ អវសិស្សិំសុ ។ ព្រះធាតុទាំងឡាយដែលនៅសេសសល់ប្រាកដ ដូចផ្កាម្លិះក្រពុំខ្លះ ដូចកែវមុក្តាដ៏ស្អាតខ្លះ ដូចលំអិតមាសខ្លះ ។** ដូច្នេះក្នុងអដ្ឋកថាបានបញ្ជាក់ហើយថា **សុមនមកុលសទិសា** ប្រាកដដូចផ្កាម្លិះក្រពុំជាក់ច្បាស់ទៅហើយ និងគម្ពីរជិនកាលមាលីបករណ៍ (១/៣៩) បានសំដែងថា ៖

---

១.បបញ្ចសូទនី អដ្ឋកថា មជ្ឈិមនិកាយ ៨/៣៨៧/២០០

www.elibraryofcambodia.org

**ឥត្ថ ខុទ្ទកា សាសបពីជមត្តា មជ្ឈិមា មជ្ឈេ ភិន្នតណ្ឌុលមត្តា ។ មហន្តា មជ្ឈេ ភិន្នមុគ្គមត្តា ។ ឥត្ថ ខុទ្ទកា សុមន-មកុលសទិសា ។ មជ្ឈិមា ធោតមុត្តសទិសា ។ មហន្តា សុវណ្ណសទិសា ។** បណ្ដាព្រះបរមសារីរិកធាតុនោះ ព្រះធាតុខ្នាតតូចប៉ុនគ្រាប់ស្ពៃ ។ ព្រះធាតុកណ្ដាលប៉ុនគ្រាប់អង្ករបាក់ពាក់កណ្ដាល។ ព្រះធាតុខ្នាតធំប៉ុនគ្រាប់សណ្ដែកបាក់ពាក់កណ្ដាល ។ បណ្ដាព្រះបរ-មសារីរិកធាតុនោះ ព្រះធាតុខ្នាតតូចមានពណ៌ប្រាកដដូចផ្កាម្លិះក្រពុំ ។ ព្រះធាតុខ្នាតកណ្ដាលមានពណ៌ប្រាកដដូចកែវមុក្ដាដ៏ស្អាត ។ ព្រះធាតុខ្នាតធំមានពណ៌ប្រាកដដូចជាមាស ។ ព្រមទាំងក្នុងគម្ពីរបបញ្ចសូទនីអដ្ឋកថា មជ្ឈិមនិកាយ ពាកុលសូត្រត្រង់សុញ្ញតវគ្គបានបញ្ជាក់ធាតុព្រះពាកុលៈមាន **មកុល** ស័ព្ទដែរថា ៖

**សុមនមកុលសទិសា ធាតុយោ អវសេសិសុ ។ ព្រះធាតុទាំងឡាយនោះឯងនៅសេសសល់ប្រាកដដូចជាផ្កាម្លិះក្រពុំ។**

តើយើងនៅនាំគ្នាថា ដូចផ្កាថ្កុល ដូចម្ដេចកើត ! បើពាក្យថា **ពកុល** មិនមានក្នុងបិដកនិងអដ្ឋកថា ដែលជាច្បាប់ដើមទេនោះ ។

www.elibraryofcambodia.org

ដូច្នេះយើងទាំងអស់គ្នាគប្បីកែបទទមស្សការនេះឱ្យត្រឹមត្រូវតាមព្រះត្រៃបិដកនិងអដ្ឋកថាវិញ ។

នៅក្នុងសុមង្គលវិលាសិនី អដ្ឋកថា មហាបរិនិព្វានសូត្រប្រាប់ថា៖

**សព្វាបិ ធាតុយោ បាកតិកនាឡិយោ សោឡស នាឡិយោ អហេសុំ** ។ ព្រះបរមធាតុរួមទាំងអស់ ១៦ នាឡិដោយនាឡិតាមប្រក្រតី ( អដ្ឋកថា ទីឃនិកាយ ៥/៣៥៦ )។

នៅក្នុងសុត្តន្តបិដក ទីឃនិកាយ មហាវគ្គ ( ១៦/ ៣៤៥ /១០)ថា៖

**អដ្ឋទោណំ ចក្ខុមតោ សរីរំ ...**

**ព្រះបរមធាតុរបស់ព្រះសម្ពុទ្ធមានចក្ខុ មានចំនួន ៨ ទោណ ។**

យើងត្រូវគិតពីមាគធនាឡិ ( បាកតិនាឡិ ) និងទោណនេះ ឱ្យបានច្បាស់លាស់ដើម្បីដឹងពីប្រមាណនៃព្រះធាតុនេះ ។ តាមគម្ពីរអភិធានប្បទិបិកា គាថាទី ៤៨២-៣ តទៅ ៖

**ឯកោ បសតោ កុឌុវោ** ១ បសតៈ ជា ១ កុឌុវៈ

**តេ ចតុរោ បត្ថោ** ៤ កុឌុវៈ ជា ១ បត្ថៈ

**ចតុរោ បត្ថា អាឡ្ហកោ** ៤ បត្ថ ជា ១ អាឡ្ហក

www.elibraryofcambodia.org

**ចតុរាឡ្ហកំ ទោណំ** ៤ អាឡ្ហក ជា ១ ទោណ ។

តាមមាត្រាវាស់នេះសឱ្យឃើញថា បួនកំបង់ដៃស្មើ ១ បត្ថៈ គឺ ១នាឡិ តាមប្រក្រតី ។ ដូចពាក្យក្នុងវិសុទ្ធិមគ្គ មហាដីកា (២/ ១៦៧) ថា

**ចតុកុឌវំ នាឡិ** ៤ កុឌុវៈ ជា ១ នាឡិ ។

ក្នុងសុមង្គលវិលាសិនី អដ្ឋកថា ទីឃនិកាយ ( ២/២១៨)និងក្នុង សមន្តប្បាសាទិកា វេរញ្ជកណ្ឌវណ្ណនា (១/៣៤០-៣៤១) ថា

**បត្ថោ នាម នាឡិមត្តំ ហោតិ ឯកស្ស បុរិសស្ស អលំ យាបនាយ** ។ ឈ្មោះថា **បត្ថៈ**គឺមានប្រមាណប៉ុននាឡិត្រឹម ល្មមដើម្បីចិញ្ចឹមបុរសម្នាក់ ។ ឱ្យប្រព្រឹត្តទៅបាន ។

<u>សរុបព្រះធាតុ</u>

៤ កុឌុវៈ ជាមួយនាឡិតាមប្រក្រតី ៤ នាឡិតាមប្រក្រតី ជាមួយ អាឡ្ហក ៤ អាឡ្ហក ជា១ទោណ ។ ដូច្នេះ ៤ × ៤ = ១៦ គឺ ១៦ នាឡិតូចស្មើ ១ ទោណ ។

ព្រះបរមសារីរិកធាតុសរុបទាំងអស់មាន ១៦ នាឡិ ស្មើ ១ ទោណប៉ុណ្ណោះ តាមន័យក្នុងអដ្ឋកថា ។ តែព្យញ្ជនៈក្នុងសុត្តន្តបិដក

www.elibraryofcambodia.org

ទីឃនិកាយ មហាវគ្គ (១៦/៣៤៩/១០)ថា **អដ្ឋទោណំ ចក្ខុមតោ សរីរំ...**ព្រះបរមសារីរិកធាតុរបស់សម្ពុទ្ធមានចក្ខុមានចំនួន ៨ ទោណ។ បើមានចំនួន ៨ ទោណមែននោះ គឺ ១៦ × ៨ =១២៨ នាឡិទៅហើយ តែអដ្ឋកថាបញ្ជាក់ថា មានតែ ១៦ នាឡិធម្មតាប៉ុណ្ណោះ ។ ហើយគួរឱ្យសង្ស័យដល់អ្នកសិក្សាទៀតនោះគឺក្នុងសារត្ថទីបនីដីកា (១/២២៣) ព្រះសារីបុត្រជាគន្ថរចនាចារ្យបានខែពន្យល់ពីព្រះធាតុដែលបានតមកពីរាមគ្រាមចំនួន ១ ទោណថា ៖

**ទោណមត្តាតិ មគធនាឡិយា សោឡសនាឡិប្បមាណា ។**

ពាក្យថា ត្រឹម ១ ទោណគឺស្មើប្រមាណ ១៦ នាឡិដោយនាឡិមគធ។ តាមក្នុងដីកាខែពន្យល់ព្រះបរមធាតុមានចំនួន ១២៨ នាឡិ តែតាមពិត ព្រះបរមធាតុមានតែ ១៦ នាឡិស្មើនឹង ១ ទោណទេ ។ ចុះពាក្យថា ព្រះបរមធាតុមាន ៨ ទោណ ដែលមានក្នុងសុត្តន្តបិដក ទីឃនិកាយ មហាវគ្គ ភាគ ១៦ ទំព័រ ៣៤៩ បន្ទាត់ទី ១០ នោះយ៉ាងណាទៅវិញ ? ពាក្យនេះអដ្ឋកថាប្រាប់ថា ៖

**អដ្ឋទោណំ ចក្ខុមតោ សរីរន្តិអាទិគាថាយោ បន តម្ពៈ.**

www.elibraryofcambodia.org

**បណ្ណិទីបត្ថេរេហិ វុត្តា** ។ ក៏គាថាទាំងឡាយ មានពាក្យជាដើមថា ព្រះបរមធាតុរបស់ព្រះសម្ពុទ្ធមានចក្ខុ មានចំនួន ៨ ទោណ ដូច្នេះជាដើម គឺព្រះថេរៈទាំងឡាយ អ្នកនៅក្នុងកោះតាម្ពបណ្ណិទីប ( ប្រទេសសិរីលង្កាសព្វថ្ងៃ ) ពោលទុកហើយ ។ តាមគាថាពន្យល់ក្នុងគម្ពីរបឋមសម្ពោធិត្រង់ទំព័រ២៦១បានចង្អុលបង្ហាញប្រាប់ថា ( **ទោណោកេកំ នាឡី ទ្វេ ច សោឡស នាឡិយោ មិតា** ) ព្រះថេរៈក្នុងកោះតាម្ព-បណ្ណិទីបនោះមិនបានគិតពីមាត្រាវាស់ទេ លោកចងគាថា ឱ្យគិតយ៉ាងនេះថា ១ ទោណ ស្មើ ២ នាឡិ ដូច្នេះ ៨ × ២ = ១៦ នាឡិ សូម្បីគម្ពីរដទៃមានគម្ពីរជិនកាលមាលីបករណ៍(១/៣៩) ក៏បានពន្យល់យ៉ាងជាក់ច្បាស់ដែរថា **អដ្ឋាកំ បន ភគវតោ ធាតុយោ សោឡស-នាឡិមត្តា ។ ក៏ព្រះធាតុទាំងឡាយរបស់ព្រះដ៏មានព្រះភាគនៃយើងមានត្រឹម ១៦ នាឡិ ។**

ហើយធ្វើឱ្យយើងលែងសង្ស័យត្រាន់ពាក្យថា ៨ ទោណ ដែលមានក្នុងបិដកទៀតនោះ ព្រោះក្នុងអដ្ឋកថា (៥/៣៥៦ ) បានបញ្ជាក់ពីព្រះធាតុចែកឱ្យទៅទាំង ៨ នគរនោះថា ៖

www.elibraryofcambodia.org

**ឯកេកនគរវាសិនោ ទ្វេ ទ្វេ នាឡិយោ លភិំសុ ។ ព្រះរាជានិងព្រាហ្មណ៍អ្នកនៅក្នុងនគរនីមួយ ៗ បានទទួលចំណែកព្រះធាតុពីរនាឡិ ៗ ( ក្នុងមួយនគរ ១ ) ។**

ចំណែកព្រះធាតុ ដែលប្រទេសសិរីលង្កាបានតមកពីរាមគ្រាមនោះក៏បានចំណែកតែពីរនាឡិដែរ មិនមែន ១៦ នាឡិដូចដីកាពោលនោះទេ ។

**ដូច្នេះសរុបគ្រប់គម្ពីរមតព្រះបរមធាតុមាន ១៦ នាឡិស្មើ ២ ទោណៈ ។**

## ខ្នាត ពណ៌ និង បរិមាណ របស់សម្ពិន្នធាតុ

### ព្រះធាតុខ្នាតធំ

១. ខ្នាត គ្រាប់សណ្ដែកបាយ

២. ពណ៌ ពណ៌មាស

៣. បរិមាណ ៥ នាឡិ

### ព្រះធាតុខ្នាតកណ្ដាល

១. ខ្នាត ប៉ុនគ្រាប់អង្ករបាក់

www.elibraryofcambodia.org

២.ពណ៌　　កែវមុក្តា

៣-.បរិមាណ　　៥ នាឡិ

ព្រះធាតុខ្នាតតូច

១.ខ្នាត　　ប៉ុនគ្រាប់ស្ពៃ

២.ពណ៌　　ដូចផ្កាម្លិះក្រពុំ

៣.បរិមាណ　　៦ នាឡិ ។

មានអ្នកសាកសួរថា ហេតុអ្វីទើបព្រះធាតុរបស់ព្រះអរហន្តសម្មាសម្ពុទ្ធ មានបំណែកបែកជាចំណែកតូចៗយ៉ាងនេះ ? ប្រស្នានេះលុះណាតែ យើងសិក្សាពីព្រះគុណរបស់ព្រះសម្ពុទ្ធ ដែលព្រះអង្គទ្រង់មានសព្វ-ញ្ញុតញ្ញាណ ទ្រង់មានព្រះទ័យករុណាចំពោះសត្វលោកយ៉ាងណា ដូច ព្រះអង្គទ្រង់សឹងលើគ្រែបរិនិព្វានទ្រង់បានអធិដ្ឋានឱ្យព្រះធាតុបែកជាចំណែកតូចៗ(ជិនកាលមាលីបករណ៍ ១/៣៥)ថា ៖ **អហំ ន ចិរំ ឋត្វា បរិនិព្វាយិស្សាមិ មយ្ហំ សាសនំ ន តាវ សព្វត្ថ វិត្ថារិកំ តស្មា បរិនិព្វុតស្សាបិ សាសបមត្តម្បិ ធាតុំ គហេត្វា អត្តនោ អត្តនោ វសនដ្ឋានេ ចេតិយំ កត្វា បរិចរន្តោ មហាជនោ សគ្គបរាយនោ**

**ហោតូតិ ធាតុវិកិរណំ អធិដ្ឋាសិ ។ តស្មា វិប្បកិណ្ណា ច ន វិប្បកិណ្ណា ច ។ តថាគតមិនស្ថិតនៅយូរអង្វែងទេ នឹងបរិនិព្វាន ទៅ សាសនាតថាគតនៅមិនទាន់ផ្សាយទៅគ្រប់ទីកន្លែងនៅឡើយ ព្រោះហេតុនោះ កាលបើតថាគតបរិនិព្វានទៅហើយ មហាជនទទួល យកនូវព្រះធាតុសូម្បីប៉ុនគ្រាប់ស្ពៃ ហើយធ្វើចេតិយក្នុងទីនៅរបស់ខ្លួនៗ ហើយគោរពបូជា កាលគ្រាច់ទៅនឹងមានសួគ៌ក្នុងខាងមុខ ។ ព្រោះ ហេតុនោះ ព្រះធាតុបែកចេញជាចំណែកតូចៗខ្លះ មិនបែកចេញខ្លះ ។**

( អដ្ឋកថា ទីឃនិកាយ មហាវគ្គ ៥/៣៤៧ )

ព្រះអរហន្តសម្មាសម្ពុទ្ធព្រះអង្គទ្រង់បំពេញពុទ្ធចរិយា អស់ ៤៥ វស្សា ដើម្បីប្រយោជន៍ដល់សត្វលោក សូម្បីព្រះអង្គទ្រង់បរិនិព្វានទៅហើយ ក៏ព្រះអង្គនៅតែបំពេញប្រយោជន៍ដល់សត្វលោកទៀត ដូចព្រះអង្គ ទ្រង់អធិដ្ឋានឱ្យព្រះធាតុបែកជាចំណែកតូចៗ ដើម្បីផ្សាយទៅគ្រប់ទី កន្លែងសម្រាប់ជាគ្រឿងសក្ការៈគោរពបូជារបស់ពុទ្ធបរិស័ទ នឹងបាន សម្រេចនូវស្ថានសួគ៌និងព្រះនិព្វានក្នុងកាលខាងមុខ ។

**ខ្វាត ពណ៌ ប្រមាណព្រះបរមសារីរិកធាតុចប់ដោយសង្ខេប**

www.elibraryofcambodia.org

## ព្រះមហាកស្សបៈធ្វើធាតុនិធានគឺកប់ព្រះបរមសារីរិកធាតុក្នុងដី

(សុមង្គលវិលាសិនី និង បឋមសម្ពោធិកថា)

ព្រះមហាកស្សបត្ថេរៈបានពិចារណាឃើញអន្តរាយ នឹងមានដល់ព្រះបរមសារីរិកធាតុទាំងឡាយ ទើបចូលទៅរកព្រះបាទអជាសត្តុទូលថា បពិត្រមហារាជព្រះបរមសារីរិកធាតុគួរនឹងដាក់ទុកដោយធ្វើ ធាតុ-និធាន គឺកប់ទុកក្នុងដីទើបគួរ ។ ព្រះបាទអជាសត្តុត្រាស់ថា បពិត្រលោកម្ចាស់ និធានកម្មទុកឱ្យខ្ញុំព្រះករុណា តែខ្ញុំព្រះករុណានឹងនាំមកនូវព្រះធាតុដ៏សេសដូចម្ដេចកើត ? ។ ព្រះថេរៈឆ្លើយតបថា បពិត្រមហារាជ ការនាំព្រះធាតុមិនមែនជាភារៈរបស់ព្រះអង្គទេ ជាភារៈរបស់អាត្មា ។ ព្រះបាទអជាសត្តុពោលថា សាធុ លោកម្ចាស់ សូមលោកម្ចាស់នាំព្រះធាតុមកចុះ ខ្ញុំព្រះករុណា នឹងធ្វើនូវការកប់ទុក ។ ព្រះកស្សបត្ថេរៈបាននាំយកព្រះធាតុដ៏សេស វៀរតែព្រះធាតុដែលរាជត្រកូលចាត់ចែងទុក ។ ចំណែកព្រះធាតុក្នុងរាមគ្រាម ( ដែលជាក្រុងរបស់ក្សត្រកោឡិយៈ ឥឡូវនៅក្នុងប្រទេសនេប៉ាល់ ) ព្រះថេរៈវៀរទុក ដោយពិចារណាឃើញថា ព្រះធាតុទាំងនេះ តទៅខាងមុខស្ដេច

www.elibraryofcambodia.org

នាគ នឹងអារាធនាទៅកាន់នាគពិភព នឹងធ្វើឱ្យផុតចាកពីអន្តរាយនោះក្នុងកាលអនាគត ព្រះថេរៈទាំងឡាយនឹងអារាធនាព្រះធាតុទាំងនេះទៅបញ្ចុះក្នុងមហាចេតិយ មហាវិហារ លង្កាទ្វីប គឺប្រទេសសិរីលង្កាសព្វថ្ងៃនេះ ( អនាគតេ កាលេ លង្កាទីបេ មហាវិហារេ មហាចេតិយម្ហិ និទហិស្សន្តិ ) ។ ព្រោះហេតុនោះ បានជាព្រះថេរៈមិនអារាធនាព្រះធាតុក្នុងរាមគ្រាម អារាធនាតែព្រះធាតុនៅក្នុងក្រុង ទាំង ៧ ទៅប្រតិស្ឋានក្នុងទិសអាគ្នេយ៍នៃក្រុងរាជគ្រឹះ ដោយបានតាំងចិត្តអធិដ្ឋានថា សិលាដែលមាននៅក្នុងទីនេះ ចូរអន្តរធានវិនាសទៅឱ្យសល់នៅតែដីដ៏បរិសុទ្ធប៉ុណ្ណោះ នឹងទឹកកុំផុសឡើងក្នុងភូមិភាគនេះឡើយ ។

ចំណែកព្រះបាទអជាសត្តុត្រាស់បញ្ជាឱ្យជីកដីចុះ ត្រង់ស្ថានទីនោះដែលព្រះមហាកស្សបត្ថេរៈអធិដ្ឋានរួចហើយ និងព្រះអង្គទ្រង់បញ្ជាឱ្យនាំដីដែលជីកឡើងមកធ្វើជាឥដ្ឋ និង ប្រោសឱ្យសាងព្រះចេតិយថ្វាយអសីតិមហាសាវ័ក ។ ម្យ៉ាងទៀត អាចារ្យពួកខ្លះពោលថា ប្រសិនបើមានអ្នកណាសួរថា ព្រះរាជាឱ្យសាងអ្វីក្នុងទីនេះ តបថា ព្រះរាជា

www.elibraryofcambodia.org

ឱ្យសាងព្រះចេតិយថ្វាយមហាសាវ័កទាំងឡាយ កាលពោលយ៉ាងនេះ អ្នកណាមួយក៏មិនដឹងថា ទីនេះកប់នូវព្រះធាតុ ។

ការជីកធ្វើធាតុនិធានបានជម្រៅ ៨០ ហត្ថ ព្រះរាជាទ្រង់បញ្ជាឱ្យក្រាលផ្ទៃក្រោមដោយផែនលោហៈ ។ ព្រះបាទអជាសត្តុទ្រង់បញ្ជាឱ្យធ្វើកូនគោដ្ឋ និងស្តូបបញ្ចុះព្រះបរមសារីរិកធាតុ ដោយវត្ថុផ្សេង ៗ បានដល់ ១ ខ្លឹមចន្ទន៍លឿង ២ ខ្លឹមចន្ទន៍ក្រហម ៣ ភ្លុក ៤ កែវ ៥ មាស ៦ ប្រាក់ ៧ កែវមណី ៨ កែវទទឹម ៩ កែវផ្លេក ១០ កែវផលិក ដោយទ្រង់បញ្ជាឱ្យធ្វើវត្ថុនីមួយៗ ធ្វើជាប្រអប់ ៨ ជាន់ និងស្តូប ៨ ជាន់ចាប់តាំងពីតូចរហូតដល់ជាន់ធំ បំពាក់ត្រួតលើគ្នាជាជាន់ ១ បាន ៨ ជាន់ ដូចប្រើខ្លឹមចន្ទន៍លឿងធ្វើប្រអប់ ៨ ជាន់ និង ស្តូប ៨ ជាន់ ។ ល ។ ប្រើកែវផលិកធ្វើជាប្រអប់ ៨ ជាន់ និងធ្វើស្តូប ៨ ជាន់ ដែលមានកែវផលិកនៅជាន់ក្រៅបំផុត ព្រះស្តូបធំប៉ុនចេតិយក្នុង ថូបារាម ។ បន្ទាប់មកព្រះរាជាទ្រង់បញ្ជាឱ្យសាងផ្ទះកែវ ដោយកែវ ៧ ប្រការ គ្របស្តូបកែវផលិក ឱ្យសាងផ្ទះមាសគ្របផ្ទះកែវ ឱ្យសាងផ្ទះប្រាក់ គ្របផ្ទះមាស ឱ្យសាងផ្ទះស្ពាន់គ្របផ្ទះប្រាក់ ខាងលើផ្ទះស្ពាន់ជា

www.elibraryofcambodia.org

ជាន់ខាងក្រៅបំផុត ទ្រង់បញ្ជាឱ្យរោយគ្រាប់ខ្សាច់កែវ ដែលធ្វើដោយកែវ ៧ ប្រការនិងរោយនូវផ្កាឈើដែលកើតលើគោកនិងក្នុងទឹក ទាំងទ្រង់បញ្ជាឱ្យធ្វើរូបព្រះពោធិសត្វ ៥៥០ ជាតិ រូបអសីតិមហាសាវ័ក រូបព្រះបាទសុទ្ធោទនមហារាជ រូបព្រះនាងមហាមាយាទេវី និងរូប-សហជាតិវត្ថុទាំង ៧ នឹងទ្រង់ឱ្យតាំងឆ្នាំងមាស ដែលមានទឹកពេញ ៥០០ ឆ្នាំង នឹងទ្រង់ឱ្យតាំងឆ្នាំងប្រាក់ ដែលមានទឹកពេញ ៥០០ ឆ្នាំង ទ្រង់ឱ្យដោតទង់មាស ៥០០ ទង់ ឱ្យដុតប្រទីប ៥០០ ដើម ដោយប្រើទឹកក្រអូបជាប្រេង ប្រើសំពត់ទុកុលពស្ត្រជាប្រឆេះ ភ្លើងបូជាព្រះ បរ-មសារីរិកធាតុរបស់ព្រះដ៏មានព្រះភាគ ។

គ្រានោះព្រះមហាកស្សបៈអធិដ្ឋានថា សូមសព្វបូជនីយភណ្ឌ (វត្ថុរបស់គួរបូជាទាំងអស់ ) ដូចផ្កាឈើទាំងនេះ កុំស្វិតស្រពោន ក្លិនក្រអូបកុំវិនាសបាត់ ដួងប្រទីបទាំងនេះកុំរលត់ឡើយ ដូច្នេះជាដើម ហើយឱ្យចារឹកអក្សរ ចុះក្នុងផែនមាសប្រតិស្ឋានក្នុងទីនោះថា **អនា-គតេ យទា អសោកោ នាម កុមារោ ឆត្តំ ឧស្សាបេត្វា អសោកោ ធម្មរាជា ភវិស្សតិ សោ ឥមា ធាតុយោ វិត្ថារិកា ភវិស្សតិ ។**

www.elibraryofcambodia.org

អនាគតកាល ព្រាអសោកកុមារញុំាងគេឱ្យលើកស្វេតឆត្រឡើងហើយ នឹងបានជាអសោកធម្មរាជា ព្រះរាជាអង្គនោះ នឹងទ្រង់ធ្វើព្រះបរមសារីរិកធាតុទាំងនេះ ឱ្យផ្សព្វផ្សាយទៅ ។

ចំណែកព្រះបាទអជាសត្តុទ្រង់នាំប្រដាប់ទាំងអស់ចេញមកបូជា និងវេលាដែលស្ដេចទ្រង់ឡើងចេញអំពីស្ថានបញ្ចុះព្រះបរមសារីរិកធាតុ បញ្ជាឱ្យបិទទ្វារផ្ទះព្រះបរមសារីរិកធាតុ និងឱ្យដាក់សោប្រថាប់ត្រាគ្រប់ៗ ជាន់ រៀងលំដាប់រហូតមកដល់ទ្វារផ្ទះស្ពាន់ ដែលជាជាន់ក្រៅបំផុត ហើយទ្រង់ឱ្យដាក់កែវមណីធំក្នុងទីនោះ និងឱ្យចារឹកអក្សរថា ក្នុងអនាគតកាលព្រះរាជាក្រខ្សត់ ចូរកាន់យកកែវមណីនេះចុះហើយធ្វើសក្ការៈបូជាព្រះបរមសារីរិកធាតុទាំងឡាយនេះចុះ ។

ក្នុងកាលណោះ សក្កទេវរាជទ្រង់ហៅវិស្សកម្មទេវបុត្រមក ហើយត្រាស់បញ្ជាថា ម្នាលអ្នកដ៏ចំរើន ព្រះមហាកស្សបៈនិងព្រះបាទអជាសត្តុ បានធ្វើធាតុនិធានគឺការកប់ព្រះបរមសារីរិកធាតុទុកហើយ អ្នកចូរនិមិត្តកងរក្សាទុកក្នុងទីនោះ ។ វិស្សកម្មទេវបុត្រមកហើយ ក៏ប្រកបនូវវាឡសង្ឃាដយន្តគឺមនុស្សយន្តមានរូបដូចសត្វសាហាវ រូបយន្ត

www.elibraryofcambodia.org

ឈើនេះកាន់ព្រះខ័នពណិកែវផលិក មានលក្ខណៈគួរឱ្យខ្លាច វិលជុំវិញបន្ទប់បញ្ចុះព្រះបរមសារីរិកធាតុយ៉ាងលឿនរហ័សដូចជាខ្យល់ព្យុះ ។ កាលវិស្សុកម្មទេវបុត្រប្រកបគ្រឿងយន្តរួចហើយ ចងគន្លឹះទុកជាមួយគ្នា និងនាំផែនសិលាមកបង្កុជាកំផែងឡោមព័ទ្ធ ដូចផ្ទះសាងដោយឥដ្ឋថែមទាំងបាននាំសិលាធំមកបិទទុកពីលើ លុបដីពីខាងលើនិងធ្វើឱ្យរាបស្មើល្អ ។ កាលបើធាតុនិធានសម្រេចហើយយ៉ាងនេះ ព្រះថេរៈនៅតាមអាយុកាលក៏បរិនិព្វានទៅ ព្រះរាជាទៅតាមយថាកម្ម ឯមនុស្សទាំងនោះក៏ធ្វើកិរិយាទៅ ។

## ចប់ការធ្វើធាតុនិធាន

## សម័យព្រះបាទធម្មាសោកទ្រង់ជ្រះថ្លានឹងព្រះពុទ្ធសាសនា

ស្តេចអសោកមុនដំបូងជាព្រាហ្មណិកជាអ្នកកាន់សាសនាព្រាហ្មណ៍តាមរាជត្រកូលតមក តែដោយអំណាចឧបនិស្ស័យបុណ្យវាសនាដែលធ្លាប់សន្សំធ្វើមកជាមួយនឹងនិគ្រោធសាមណេរ ធ្វើឱ្យទ្រង់មានសេចក្តីជ្រះថ្លាចំពោះព្រះពុទ្ធសាសនា ក្រោយមកព្រះអង្គមិនគិតពីការធ្វើសង្គ្រាមវាយយកទឹកដីទៀតទេ គឺព្រះអង្គទ្រង់ធ្វើសង្គ្រាម

www.elibraryofcambodia.org

## .៣៥. ព្រះបាទអសោកទ្រង់ឱ្យបុត្របួសដើម្បីជាទាយាទសាសនា

ក្នុងផ្លូវព្រះធម៌ដោយការបដិបត្តិតាមព្រះពុទ្ធសាសនា ។ មានថ្ងៃមួយ ព្រះធម្មាសោករាជ បានសាកសួរព្រះភិក្ខុសង្ឃថា តើខ្ញុំព្រះករុណាធ្វើបុណ្យដ៏ធំធេងមានការថ្វាយទានជាដើមយ៉ាងនេះ តើបានឈ្មោះថាទាយាទគឺញាតិរបស់ព្រះសាសនាដែរឬទេ ? ព្រះមោគ្គលិបុត្តតិស្សត្ថេរតបថា បពិត្រមហារាជ ទ្រង់មិនទាន់ជាញាតិរបស់ព្រះពុទ្ធសាសនានៅឡើយទេ លុះត្រាបុគ្គលណាមួយឱ្យកូនប្រុសក្តី កូនស្រីក្តីបួសក្នុងព្រះពុទ្ធសាសនា ទើបឈ្មោះថា **ជាទាយាទគឺញាតិព្រះសាសនា** ។ ដោយសេចក្តីជ្រះថ្លាដ៏ខ្លាំងក្លាពេក ព្រះរាជាក៏ដាច់ចិត្តឱ្យព្រះរាជបុត្រ **មហិន្ទ-កុមារ** និងព្រះរាជបុត្រីព្រះនាង **សង្ឃមិត្តា** បួសក្នុងព្រះពុទ្ធសាសនាគ្រាន់នឹងបានជាព្រះញាតិរបស់ព្រះពុទ្ធសាសនា ។ នៅក្នុងសម័យរបស់ព្រះរាជាអង្គនេះ ព្រះពុទ្ធសាសនាបានរុងរឿងខ្លាំងណាស់រហូតទ្រង់អាចជម្រះនូវរឿងមន្ទិលក្នុងព្រះពុទ្ធសាសនា ដោយពួកអន្យតិរ្ថិយមកបួមក្នុងព្រះពុទ្ធសាសនា ហើយទ្រង់បានជាអគ្គពុទ្ធសាសនូបត្ថម្ភក្នុងការធ្វើ **តតិយសង្គាយនា** ។ ចំណែកព្រះបរមសារីរិកធាតុដែលបាត់ឈឹងពីក្នុងលោកនេះ ក៏ព្រះបាទអសោកបានយកមកផ្សព្វផ្សាយទូទាំងជម្ពូទ្វីប

www.elibraryofcambodia.org

ឡើងវិញ មានសំដែងក្នុងគម្ពីរ សមន្តប្បាសាទិកា អដ្ឋកថាវិន័យ ក្នុងគម្ពីរសុមង្គលវិលាសិនីជាដើមថា ៖

ព្រះបាទអសោកឱ្យសាងមហាវិហារឈ្មោះ អសោការាមហើយទ្រង់បានតាំងភត្តដើម្បីថ្វាយភិក្ខុ ៦ សែនរូបទៀត និងទ្រង់ត្រាស់ឱ្យសាងព្រះវិហារ ៨ ម៉ឺន ៤ ពាន់ខ្នង ដែលប្រដាប់ដោយចេតិយ ៨ ម៉ឺន ៤ ពាន់កន្លែងក្នុងជម្ពូទ្វីបទាំងអស់ ដោយសេចក្តីពេញចិត្តក្នុងធម៌ មិនមែនដោយមិនពេញចិត្តទេ ។ ក្រោយពីការកសាងព្រះចេតិយរួច ព្រះបាទអសោកបានបញ្ជារាជបុរសឱ្យទៅរុះរើព្រះចេតិយ ដែលបញ្ចុះព្រះសារីរិកធាតុទាំង ៨ កន្លែង មានក្រុងរាជគ្រឹះជាដើមតែមិនបានព្រះសារីរិកធាតុសូម្បីបន្តិចសោះ ទើបទ្រង់ក្រាបទូលដល់ព្រះសង្ឃជាមហាថេរឱ្យប្រជុំព្រះភិក្ខុសង្ឃនិងភិក្ខុនីសង្ឃ ដើម្បីសួរមើល ក្រែងមានព្រះថេរៈអង្គណាមួយជ្រាបរឿងព្រះធាតុនេះ ។ កាលបើជួបជុំព្រះភិក្ខុសង្ឃហើយព្រះរាជាត្រាស់ថា លោកម្ចាស់ខ្ញុំព្រះករុណាបានកសាងព្រះចេតិយរួចហើយ តែរកព្រះសារីរិកធាតុមិនបានសោះ តើលោកម្ចាស់អង្គណាបានដឹងដំណឹងខ្លះពីព្រះសារីរិកធាតុទេ ? ខណៈ

www.elibraryofcambodia.org

## .៣៧. ព្រះថេរៈព្រះជន្ម ១២០ ប្រាប់ដំណើងព្រះធាតុ

នោះមានព្រះថេរៈមួយអង្គបួសតាំងពីព្រះជន្ម ៧ ឆ្នាំ រហូតមានព្រះជន្ម ១២០ ឆ្នាំ តបព្រះរាជាថា បពិត្រមហារាជ កាលពីអាត្មានៅជាសាមណេរតូចជន្មាយុ ៧ ឆ្នាំ ព្រះមហាថេរៈជាបិតាអាត្មាបបួលអាត្មាថា នែ៎សាមណេរអ្នកចូរមកនេះ ចូរយកផ្កាកម្រងនិងគ្រឿងក្រអូបហើយបូជាកន្លែងនេះ. នេះជាកន្លែងតម្កល់ព្រះបរមសារីរិកធាតុ. មហាបពិត្រកន្លែងនោះទេដឹង ដែលតម្កល់ព្រះបរមសារីរិកធាតុ ! ។ ព្រះរាជាទ្រង់ត្រេកអរណាស់ក៏បាននាំពួករាជបុរសទៅកន្លែងនោះ ជីកចុះទៅខាងក្រោមក៏ជួបកំពូលស្តូប ដែលព្រះបាទអជាសត្តុសាងតម្កល់ព្រះបរមសារីរិកធាតុ ហើយក៏ជីកយកព្រះបរមសារីរិកធាតុចំនួន ៧ ទោណ មកតម្កល់ទុកក្នុងព្រះចេតិយទាំង៨៤០០០ ព្រះចេតិយរហូតផ្សព្វផ្សាយទាំងជម្ពូទ្វីបរហូតមកដល់យើងសព្វថ្ងៃនេះ ។ ដូចដែលបានរកឃើញស្តូបមួយនៅក្នុងបិប្រវា លើព្រំប្រទាល់ដែននេប៉ាល់ ស្តូបនោះមានកោដ្ឋមួយនៅក្នុងនោះហើយ មានព្រះធាតុតូច ១ ខ្លះ ក្នុងកោដ្ឋនោះផងនៅលើគ្របកោដ្ឋនោះ ឃើញមានអក្សរព្រះបាទអសោកចារឹកទុកថាដូច្នេះ ៖

www.elibraryofcambodia.org

**សុកិតិភតិនំ សភគិនិកនំ សបុតទលនំ ឥយំ សលិលនិធានេ ពុទ្ធសភគវតេសាកិយានំ** ។ បានសេចក្តីថា ៖ កន្លែងដាក់នូវសារីរិកធាតុព្រះពុទ្ធ ជាត្រកូលសាក្យៈនេះ ជាការទ្រទ្រង់សាសនានៃបងប្អូនសុកិតិ មួយអន្លើនិងបងប្អូនស្រីនិងបុត្រប្រុសនិងភរិយា ។

សិលាចារឹកនេះគេរកឃើញក្នុងឆ្នាំ១៨៩៨ នៅជិតស្រុកបិព្រាវា នៅចុងព្រំប្រទេសនេផាល់ ក្នុងព្រៃឈ្មោះលុម្ពិនី ចម្ងាយប្រហែល ១ គីឡូម៉ែត្រពីខាងអាយព្រំដែននេប៉ាល់ ។ នៅក្នុងសិលចារឹកនេះជាសាក្សីថា ព្រះបាទធម្មាសោក ទ្រង់បាន សាងព្រះចេតិយតម្កល់ព្រះបរមសារីរិកធាតុមែន ។

ចប់ព្រះសារីរិកធាតុក្នុងប្រទេសឥណ្ឌា

www.elibraryofcambodia.org

## ព្រះបរមសារីរិកធាតុមកកោះសិរីលង្កាមុនដំបូង

(សមន្ត.១/១៤១, សមន្តបាសាទិកា បាលី- ប្រែ ១/១៥៨)

គ្រានោះ ព្រះមហិន្ទត្ថេរដ៏មានអាយុចាំវស្សារួចហើយ បវារណាហើយ បានទូលពាក្យនេះនឹងព្រះរាជា ក្នុងថ្ងៃឧបោសថ ពេញបូណ៌មី ខែកត្តិកថា មហារាជ អាត្មាទាំងឡាយ បានគាល់ព្រះសម្មាសម្ពុទ្ធមកយូរហើយ នៅដោយការនៅដូចជាឥតទីពឹង ពួកអាត្មានឹងទៅកាន់ជម្ពូទ្វីប ។ ព្រះរាជាត្រាស់ថា លោកម្ចាស់ ខ្ញុំទំនុកបំរុងលោកម្ចាស់ដោយបច្ច័យបួន ឯមហាជនអាស្រ័យលោកម្ចាស់ តាំងនៅក្នុងសរណៈទាំងឡាយ ៣ ព្រោះហេតុអ្វីលោកម្ចាស់ទាំងឡាយ ទើបនឿយណាយ ។ ព្រះថេរៈទូលថា មហារាជ ពួកអាត្មាមិនបានគាល់ព្រះសម្មាសម្ពុទ្ធអស់វេលាយូរហើយ ទីជាទីគួរធ្វើអភិវាទនកម្មបច្ចុដ្ឋានកម្ម អញ្ជលីកម្ម និងសាមីចិកម្ម មិនមាន ព្រោះហេតុនោះ ពួកអាត្មាទើបនឿយណាយ ។ (ព្រះរាជាត្រាស់ថា) លោកម្ចាស់ លោកបាននិយាយហើយ មិនមែនឬថា ព្រះសម្មាសម្ពុទ្ធទ្រង់បរិនិព្វានហើយ ។ ព្រះថេរៈទូលថា មហារាជ ទ្រង់បរិនិព្វានហើយមែន តែ

www.elibraryofcambodia.org

ព្រះសារីរិកធាតុរបស់ព្រះអង្គនៅមាន ។ ព្រះរាជាត្រាស់ថា ខ្ញុំដឹងហើយលោកម្ចាស់ លោកម្ចាស់បំណងសាងទីជាទីប្រតិស្ឋានព្រះស្តូប ហើយបានត្រាស់ថាបពិត្រលោកម្ចាស់ ខ្ញុំនឹងសាងព្រះស្តូប និមន្តលោកម្ចាស់ជ្រើសរើសផ្ទៃដី ឥឡូវនេះចុះ ! ម្យ៉ាងទៀត ខ្ញុំនឹងបានព្រះធាតុអំពីទីណា លោកម្ចាស់ ។ ព្រះថេរៈទូលថា មហារាជ ចូរប្រឹក្សាជាមួយសុមនសាមណេរចុះ ។ ព្រះរាជាទទូលថា ល្អហើយលោកម្ចាស់ ហើយចូលទៅរកសុមនសាមណេរសួរថា លោកម្ចាស់ ឥឡូវនេះពួកយើងនឹងបានព្រះធាតុមកអំពីទីណា សុមនសាមណេរទូលថា មហារាជចូរទ្រង់ខ្វល់ខ្វាយតិចចុះ ទ្រង់ចូរឱ្យជម្រះថ្នល់ ឱ្យប្រដាប់តាក់តែងដោយគ្រឿប្រដាប់ មានទង់ជ័យ ទង់ជ្រុង និងក្អមដែលពេញដោយទឹកជាដើម មហារាជព្រមទាំងបរិវារ ចូរសមាទានអង្គឧបោសថឱ្យពួកអ្នករបាំប្រជុំគ្នា ត្រាស់ឱ្យតែងដំរីមង្គល ប្រដាប់ដោយគ្រឿងអលង្ការគ្រប់យ៉ាង ទឹងឱ្យលើកស្វេតច្ឆត្រឡើងខាងលើដំរីនោះ ក្នុងវេលាល្ងាចចូរបែរព្រះភ័ក្ត្រឆ្ពោះទៅកាន់ឧទ្យានមហានាគវ័ន ព្រះអង្គនឹងបានព្រះធាតុពិតប្រាកដ ។ ព្រះរាជាទទូលថាព្រមហើយ ។ ព្រះ

www.elibraryofcambodia.org

ថេរៈទាំងឡាយ ក៏បានទៅកាន់ចេតិយបពិតវិញ ។ ព្រះចេតិយបពិត នោះព្រះមហិន្ទត្ថេរដ៏មានអាយុ ពោលនឹងសុមនសាមណេរថា សាម-ណេរអ្នកចូរទៅ ចូរទៅរកអសោកធម្មរាជ ដែលជាជីតារបស់អ្នកក្នុងជម្ពូទ្វីប ចូរថាតាមពាក្យរបស់យើងយ៉ាងនេះថា មហារាជ ព្រះបាទទេវានម្បិយតិស្សៈ ជាសំឡាញ់របស់ព្រះអង្គ ទ្រង់ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ប្រាថ្នានឹងឱ្យសាងស្តូប បានឮថា ព្រះអង្គមានព្រះធាតុនៅក្នុងព្រះហស្ត សូមព្រះអង្គទ្រង់ព្រះរាជទាន ព្រះធាតុនោះដល់អាត្មា ទទួលយកព្រះធាតុនោះហើយ ចូរចូលទៅរកសក្កទេវរាជហើយទូកយ៉ាងនេះថា មហារាជ បានឮថា ព្រះអង្គមានព្រះធាតុក្នុងព្រះហស្តពីរព្រះអង្គ គឺ ព្រះទាឋៈខាងស្តាំ ១ ព្រះអដ្ឋិធាតុដងកាំបិតខាងស្តាំ ១ ព្រោះហេតុនោះ សូមព្រះអង្គទ្រង់បូជាព្រះទាឋៈខាងស្តាំចុះ តែសូមព្រះរាជទានព្រះអដ្ឋិធាតុដងកាំបិតខាងស្តាំ ដល់អាត្មាភាពម្យ៉ាងទៀត ចូរទូលសក្កៈនោះយ៉ាងនេះថា មហារាជ ព្រោះហេតុអ្វី ? ព្រះអង្គបញ្ជូនពួកអាត្មាភាពទៅកាន់កោះតាម្ពបណ្ណិទ្វីបហើយ ទ្រង់មិនអើពើដូច្នេះ ។ សុមនសាមណេរ ទទួលពាក្យរបស់ព្រះថេរៈថា ល្អ

www.elibraryofcambodia.org

ហើយលោកម្ចាស់ ដូច្នេះហើយ ក៏កាន់យកបាត្រនិងចីវរហោះឡើងកាន់អាកាសក្នុងខណៈនោះឯង ចុះទៀបទ្វារនគរបាដលីបុត្រ ទៅកាន់ដំណាក់ព្រះរាជា ទូលរឿងនោះឱ្យទ្រង់ជ្រាប ។ ព្រះរាជាទ្រង់ត្រេកអរទទួលបាត្រ អំពីដៃសាមណេរ អប់ដោយរបស់ក្រអូបហើយ បានដាក់ព្រះធាតុប្រាកដស្មើដោយកែវមុក្តាដ៏ប្រសើរហើយ ទើបថ្វាយ ។ សាមណេរទទួលយកព្រះធាតុនោះហើយ ចូរទៅរកសក្កទេវរាជ ។ សក្កទេវរាជឃើញសាមណេរមកហើយត្រាស់ថា បពិត្រសុមនៈដ៏ចំរើនលោកម្ចាស់និមន្តមកព្រោះហេតុអ្វី ? ។ សាមណេរទូលថា បពិត្រមហារាជ ព្រះអង្គបញ្ជូនពួកអាត្មាទៅកាន់កោះតាម្ពបណ្ណិទ្វីប ហើយទ្រង់មិនអើពើ ព្រោះហេតុអ្វី ? ។ សក្កៈត្រាស់ថា មិនបានលះបង់ឡើយ លោកម្ចាស់ដ៏ចម្រើន និយាយទៅចុះឱ្យខ្ញុំធ្វើអ្វី ? ។ សុមនសាមណេរទូលថា បានឮថា ព្រះអង្គមានព្រះធាតុនៅក្នុងព្រះហស្ត ពីរ ព្រះអង្គ គឺ ព្រះទាឋៈខាងស្តាំ ១ និងព្រះធាតុដងកាំបិតខាងស្តាំ ១ សូមឱ្យមហាបពិត្របូជា ព្រះទាឋៈធាតុខាងស្តាំចុះ តែទ្រង់ព្រះរាជទានព្រះធាតុដងកាំបិតខាងស្តាំដល់អាត្មាភាព ។ សក្កៈជា

www.elibraryofcambodia.org

ធំជាងទេវតាត្រាស់ថា ល្អហើយលោកម្ចាស់ដ៏ចម្រើន ហើយទ្រង់បើក ព្រះស្តូបកែវមណីប្រមាណ ១ យោជន៍ បាននាំព្រះធាតុដងកាំបិត ខាងស្តាំចេញមកហើយ ថ្វាយដល់សុមនសាមណេរ ។ សុមនសាម-ណេរនោះ ទទួលយកព្រះធាតុនោះហើយ ប្រតិស្ឋានទុកក្នុងចេតិយ បពិតនោះឯង។ គ្រានោះឯង មហានាគនោះ សូម្បីទាំងអស់មានព្រះ មហិន្ទជាប្រធានប្រតិស្ឋានព្រះធាតុដែលអាសោកធម្មរាជទ្រង់ព្រះរាជ ទានមកមកទុកត្រង់ចេតិយបពិត ហើយនិមន្តព្រះធាតុដងកាំបិតាខាងស្តាំ ទៅកាន់មហានាគវ័នឧទ្យាន ក្នុងវេលារសៀល ចំណែកព្រះរាជាវិញ ទ្រង់ធ្វើការបូជាដោយសក្ការៈ ដូចដែលសុមនសាមណេរពោលហើយ គង់លើដំរីដ៏ប្រសើរ ទ្រង់បាំងស្វេតច្ឆត្រដោយព្រះអង្គឯង លើក្បាល ដំរីមង្គល ស្តេចបានទៅដល់មហានាគវ័នឧទ្យានល្មម ។ គ្រានោះ ទ្រង់មានព្រះតម្រិះថា ប្រសិនបើធាតុនេះជាធាតុរបស់ព្រះសម្មាសម្ពុទ្ធ សូមស្វេតច្ឆត្រនោះរបើកចេញទៅ ដំរីមង្គលចូរលុតជង្គង់ចុះលើផែនដី សូមឱ្យប្រអប់ចញ្ចុះធាតុ ចូរមកប្រតិស្ឋានលើក្បាលរបស់យើង ។ ព្រមដោយចិត្តដែលកើតឡើងរបស់ព្រះរាជា ស្វេតច្ឆត្រក៏បានបើកចេញ

www.elibraryofcambodia.org

ទៅដើរលុតជង្គង់ចុះលើផែនដីប្រអប់បញ្ចុះធាតុ ក៏បានមកប្រតិស្ឋានលើសិរសារបស់ព្រះរាជា ។ ព្រះរាជាទ្រង់ប្រកបដោយបីតិ និងបាមោជ្ជៈយ៉ាងក្រៃលែង ដូចមានអង្គដែលស្រោចហើយដោយទឹងអម្រិត ទើបត្រាស់សួរថាបពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំព្រះអង្គនឹងបដិបត្តិព្រះធាតុដូចម្ដេច ? ។ ព្រះថេរៈក្រាបទូលថា បពិត្រមហារាជ សូមព្រះអង្គតម្កល់ទុកលើពោងដំរីសិនចុះ ។ ព្រះរាជាទ្រង់បានលើកប្រអប់បញ្ចុះព្រះធាតុតម្កល់ទុកលើពោងដំរី ។ ដំរីមានសេចក្ដីត្រេកអរបានបន្លឺសំឡេង ដូចសំលេងសត្វក្រៀល ។ មហាមេឃតាំងឡើងហើយបានញ៉ាំងភ្លៀងបោក្ខរព័ស្សឱ្យធ្លាក់ចុះ ។ ផែនដីធំកំរើករហូតដល់ទឹកជាទីបំផុត ជាហេតុឱ្យដឹងថា ជាព្រះធាតុរបស់ព្រះសម្មាសម្ពុទ្ធនឹងប្រតិស្ឋាននៅបច្ចន្តជនបទ ។ ពួកទេវតា និងមនុស្សបាននាំគ្នាត្រេកអរហើយ ។

ព្រះមហាវីរៈ ស្ដេចមកកោះលង្កានេះ អំពីទេវលោក
បានប្រតិស្ឋាននៅលើពោងដំរីក្នុងថ្ងៃពេញបូណ៌មីខែ ៤
បានញ៉ាំងបីតិឱ្យកើតដល់ទេវតា និងមនុស្សទាំងឡាយ

www.elibraryofcambodia.org

ដោយសិរីតិភាពនៃឫទ្ធិដោយប្រការដូច្នោះឯង ។

គ្រានោះស្ដេចដំរីនោះ ដែលពួកអ្នកតន្ត្រីមិនមែតិច ហែហម ហើយមានពួកអ្នកនគរធ្វើសក្ការៈ ដោយការបូជាដោយសក្ការៈយ៉ាងក្រៃលែងមានមុខឆ្ពោះទៅទិសខាងលិចមិនថយក្រោយ ដើរទៅរហូតដល់ទ្វានគរនៃទិសខាងកើតហើយ ចូលទៅកាន់នគរតាមទ្វារទិសខាងកើត មានអ្នកនគរទាំងអស់ធ្វើការបូជាយ៉ាងឧឡារិក ចេញ (អំពីនគរ) តាមទ្វារខាងត្បូង បានឮថាទេវដ្ឋានមួយកន្លែងដែលយកឈ្មោះថា មហេជៈហួងហែង មានក្នុងចំណែកនៃទិសខាងលិចនៃថូបារាម (ដំរី) ទៅហើយ ក្នុងមហេជដ្ឋាននោះ មានមុខឆ្ពោះថូបារាម ហើយត្រឡប់មកវិញ ។

គ្រានោះរាជបុរសដើរទៅមុនដំរីនោះ ជម្រះគុម្ពឈើទាំងអស់ពង្រាបដីធ្វើឱ្យដីនោះរាបដូចបាតដៃ ។ ស្ដេចដំរីបែរមុខទៅកាន់កន្លែងនោះ បានឈរទៀបដើមពោធិ៍ទិសខាងលិចនៃទីនោះ ។ គ្រានោះពួករាជបុរសបានប្រារព្ធនឹងលើកព្រះធាតុអំពីពោងដំរីនោះ ។ ស្ដេចដំរីមិនព្រមឱ្យលើកចុះ ។ ព្រះរាជាត្រាស់សួរព្រះថេរៈថា បពិត្រលោក

www.elibraryofcambodia.org

ម្ចាស់ដ៏ចំរើន ព្រោះហេតុអ្វី បានជាដំរីនោះមិនព្រមឱ្យលើកព្រះធាតុ ដាក់ចុះ ? ។ ព្រះថេរៈថ្វាយព្រះពរថា មហារាជ ព្រះធាតុដែលលើក ឡើងហើយនឹងលើកចុះមិនសមគួរ ។ ក៏ក្នុងកាលនោះ ទឹកក្នុងបឹង អភយវាបិរីងស្ងួតអស់ទៅ ។ ផ្ទៃដីដោយជុំវិញបែកក្រហែង ។ ដុំដី ស្ថិតលើកឡើងបានដោយងាយ ។ លំដាប់នោះមហាជនប្រញាប់រួសរាន់ ជួយគ្នា នាំយកដីអំពីបឹងអភយវាបិនោះ មកធ្វើទី(ស្ថាន) ប្រមាណប៉ុន ពោងដំរី ។ ក្នុងខណៈនោះឯង ជនទាំងឡាយចាប់ផ្តើមធ្វើដុំដីឥដ្ឋ ដើម្បីកសាងព្រះស្តូប ។ ស្តេចដំរីឈរនៅក្នុងរោងដំរីជិតស្ថានរបស់ ដើមពោធិ៍ក្នុងវេលាថ្ងៃ ពេលយប់រក្សាផ្ទៃដីដែលនឹងកសាងព្រះស្តូប អស់ ២-៣ ថ្ងៃ រហូតឥដ្ឋនឹងសម្រេច ។ គ្រានោះ ព្រះរាជាទ្រង់ត្រាស់ ឱ្យពូនផ្ទៃដី(ស្ថាន)ហើយ ត្រាស់សួរព្រះថេរៈថា គប្បីសាងព្រះស្តូប មានលក្ខណៈយ៉ាងណា លោកម្ចាស់ដ៏ចម្រើន ។ ព្រះថេរៈថ្វាយព្រះ ពរថា កសាងប្រាកដដូចគំនរស្រូវ មហារាជ ។ ព្រះរាជាទ្រង់ត្រាស់ ថា ល្អហើយលោកម្ចាស់ ទើបត្រាស់ឱ្យកសាងព្រះស្តូបប្រមាណត្រឹម ជង្គង់ ហើយឱ្យធ្វើសក្ការៈដ៏ធំ ដើម្បីប្រយោជន៍ដល់ការលើកព្រះធាតុ

www.elibraryofcambodia.org

ឡើង ។ ពួកអ្នកនគរទាំងអស់និងអ្នកជនបទ ប្រជុំគ្នាហើយដើម្បី មើលការឆ្លងព្រះធាតុ ។ កំកាលមហាជននោះ ប្រជុំគ្នាហើយ ធាតុ របស់ព្រះទសពលបានហោះឡើងទៅកាន់អាកាសប្រមាណ ៧ ជួរ ត្នោត អំពីពោងដ៏រីសម្តែងយមកប្បាដិហារិយ៍ ។ ទទឹកនិងអណ្តាត ភ្លើង មានរស្មី ៦ ពណ៌ផ្សាយចេញអំពីព្រះធាតុទាំងឡាយនោះ ។ ។ បានមានបាដិហារិយ៍ប្រហែល នឹងបាដិហារិយ៍ដែលព្រះមានព្រះភាគ ទ្រង់សំដែងទៀបគល់ស្វាយជិតក្រុងសាវត្ថីដែរ កំឯបាដិហារិយនោះ មិនមែនដោយអានុភាពរបស់ព្រះថេរៈ កំមិនមែនអានុភាពរបស់ពួក ទេវតាឡើយ តាមពិតមានដោយអានុភាពរបស់ព្រះពុទ្ធតែប៉ុណ្ណោះ ។ បានឮថា ព្រះដ៏មានព្រះភាគកាលទ្រង់គង់ព្រះជន្មនៅទ្រង់បានអធិដ្ឋាន ថា កាលតថាគតបរិនិព្វាន យមកប្បាដិហារិយ៍ ចូរមានក្នុងថ្ងៃដែល ប្រតិស្ឋានព្រះធាតុ ដងកាំបិតខាងស្តាំរបស់តថាគត លើទីបរិភោគ-ចេតិយរបស់ព្រះពុទ្ធ ៣ ព្រះអង្គមុន ចំណែកទិសខាងត្បូងនៃអនុ-រាធបុរីក្នុងកោះតម្ពបណ្ណិទីប ។

ព្រះពុទ្ធជាអចិន្តេយ្យ ធម៌របស់ព្រះពុទ្ធជាអចិន្តេយ្យ

www.elibraryofcambodia.org

វិបាករបស់ពួកជនអ្នកជ្រះថ្លា ក្នុងព្រះពុទ្ធ និងគុណរបស់ព្រះពុទ្ធ ដែលជាអចិន្តេយ្យ ក៏ជាអចិន្តេយ្យដោយន័យដូចពោលមកដូច្នេះឯង ។

បានឮមកថា ព្រះសម្មាសម្ពុទ្ធស្តេចនិមន្តទៅកាន់កោះនេះអស់ ៣ ដងក្នុងកាលទ្រង់គង់ធរមាននៅ ។ លើកទី ១ ព្រះអង្គមកតែមួយព្រះអង្គប៉ុណ្ណោះ ស្តេចមកដើម្បីទូន្មានយក្ស លុះទូន្មានយក្សហើយ ទ្រង់តាំងការរក្សាក្នុងកោះតម្ពបណ្ណិ ស្តេចយាងជុំវិញ ៣ ជុំ ដោយតាំងព្រះទ័យថា កាលតថាគតបរិនិព្វាន សាសនារបស់តថាគតនឹងប្រតិស្ឋានៅក្នុងកោះនេះ ។ លើកទី ២ ស្តេចយាងមកតែមួយព្រះអង្គឯងដូចគ្នា ដើម្បីទូន្មានស្តេចនាគដែលជាឪពុកមានិងក្មួយ លុះទ្រង់ទូន្មានអ្នកទាំងពីរនោះហើយ ទើបទ្រង់យាងទៅ ។ លើកទី ៣ ស្តេចយាងមកមានភិក្ខុ ៥០០ អង្គជាបរិវារ ទ្រង់គង់ចូលនិរោធសមាបត្តិក្នុងទីនៃមហាចេតិយ ត្រង់ថូបារាមចេតិយក្នុងទីប្រតិស្ឋានមហាពោធិ ត្រង់ទីមុតិង្គចេតិយ ក្នុងកន្លែងទីឃវាបិចេតិយ និងត្រង់ទីកល្យាណិយចេតិយ ។ ការមកដោយព្រះសារីរិកធាតុលើកនេះ ជាលើកទី ៤

www.elibraryofcambodia.org

របស់ព្រះមានព្រះភាគអង្គនោះ ។ ក៏ដែលឈ្មោះថា ឱកាសបន្តិចបន្តួច លើផ្ទៃកោះតម្ពបណ្ណិទាំងអស់ ដោយកំណត់ដោយទឹកខ្ចាតចេញ អំពីព្រះសារីរិកធាតុរបស់ព្រះមានព្រះភាគអង្គនោះ មិនពាល់ត្រូវមិនមានឡើយ ។ ព្រះសារីរិកធាតុ របស់ព្រះមានព្រះភាគអង្គនោះ ញុំាងសេចក្តីក្រវល់ក្រវាយ របស់ជនអ្នកនៅកោះតម្ពបណ្ណិឱ្យស្ងប់ដោយដំណក់ទឹក ហើយបានសម្តែងបាដិហារិយ៍ដល់មហាជន ហើយបានចុះមកប្រតិស្ឋាននៅលើសិរសារបស់ព្រះរាជា ដោយប្រការយ៉ាងនេះ ។ ព្រះរាជាទ្រង់សម្គាល់ការបានអត្តភាពជាមនុស្ស ដែលមានផល ទ្រង់ធ្វើសក្ការៈធំហើយ ទ្រង់ឱ្យបញ្ចុះព្រះធាតុ ។ ព្រមដោយការបញ្ចុះព្រះធាតុ បានកើតមានផែនដីកម្រើកយ៉ាងធំ ។ ឯរាជកុមារព្រះនាមអភ័យ ជាប្អូនប្រុសរបស់ព្រះរាជា ញុំាងព្រះទ័យឱ្យជ្រះថ្លា ក្នុងបាដិហារិយ៍របស់ធាតុនោះហើយ ទ្រង់បួសជាមួយបុរសប្រមាណ ១ ពាន់នាក់ ។ ពួកទារក ៥០០ នាក់ចេញបួសអំពីស្រុកវេតាលិ ។ ពួកទារក ៥០០ ៗ ចេញអំពីស្រុកមានទ្វារមណ្ឌលជាដើមបួសហើយដូចគ្នា ។ ពួកទារកជាច្រើនរយនាក់ចេញបួសអំពីខាងក្នុងនគរនិងខាង

www.elibraryofcambodia.org

ក្រៅនគរ រួមទាំងអស់ត្រូវជាភិក្ខុចំនួន ៣ ម៉ឺនរូប ។ កំកាលព្រះស្តូបសម្រេចហើយ ព្រះរាជា រាជអាមាត្យ និងព្រះទេវី បានធ្វើការបូជាដែលគួរអស្ចារ្យផ្សេង ៗ សូម្បីដល់ពួកទេវតា នាគ និងយក្ខ ។

## ពោលពីព្រះវាមទន្តធាតុគឺចង្កូមកែវខាងឆ្វេងមកសិរីលង្កា

រឿងព្រះវាមទន្តធាតុ (ព្រះចង្កូមកែវឆ្វេងខាងលើ) មានសំដែងក្នុងគម្ពីរជិនកាលមាលីបករណ៍ ទំព័រ ៦៩ និងគម្ពីរសង្គីតិយវង្ស ទំព័រ ១៣៩ មានបាលីថា **ឥទានិ ទាឋាវំសាវកថា សម្បត្តា** ...ជាដើមដូចតទៅ ៖

ឥឡូវនេះដល់ចំណែកនៃការពោលអំពីព្រះទាឋធាតុ ។ កាលព្រះបាទមហាសេនសុគតហើយ ព្រះរាជបុត្ររបស់ព្រះអង្គ ព្រះនាមកិត្តិសិរិមេឃៈជាក្សត្រគ្រប់គ្រងរាជសម្បត្តិ ក្នុងក្រុងអនុរាធបុរី ។ គ្រានោះ ព្រះវាមទន្តធាតុខាងឆ្វេងរបស់ព្រះដ៏មានព្រះភាគមកដល់កោះលង្កាទ្វីបតី ប្រទេសសិរីលង្កា ។ រឿងនេះនឹងពោលតាមលំដាប់ដូចតទៅនេះ ៖

www.elibraryofcambodia.org

## .៥១. ព្រះខេមត្ថេរៈអារាធនាព្រះវាមទន្តធាតុពីជើងថ្ករ

បានឮមកថា កាលព្រះសម្មាសម្ពុទ្ធទ្រង់បរិនិព្វានហើយ ព្រះមហាថេរៈខីណាស្រពមួយអង្គព្រះនាម **ខេមត្ថេរៈ** បានអារាធនាព្រះទន្តធាតុខាងឆ្វេងអំពីចិតកាធានតីជើងថ្ករ ។ ហើយបានអារាធនាព្រះទន្តធាតុនោះ ទៅថ្វាយដល់ព្រះបាទព្រហ្មទត្ត ក្នុងនគរទន្តបុរៈដែនកាលិង្គរដ្ឋ ។ ចំណែកព្រះបាទព្រហ្មទត្តបានបូជាព្រះធាតុនោះទាំងយប់ទាំងថ្ងៃ ដោយសក្ការបូជាដ៏ច្រើន តម្កល់ទុកក្នុងបន្ទប់ព្រះធាតុដ៏ស្អាតវិចិត្រដោយក្បាច់ផ្សេង ៗ ។ កាលព្រះបាទព្រហ្មទត្តសោយទិវង្គតទៅ ក៏បានទៅកើតក្នុងស្ថានសួគ៌ ។ បន្ទាប់មកព្រះរាជបុត្ររបស់ព្រះរាជាអង្គនោះ ជាក្សត្រដែនកាសីបានសោយរាជបន្តក៏បានធ្វើការគោរពបូជាព្រះទន្តធាតុដូចបិតាដែរ ក្រោយអស់ជន្មាយុ ក៏បានបដិសន្ធិក្នុងស្ថានសួគ៌ ។ បន្ទាប់មកព្រះរាជបុត្ររបស់ព្រះរាជាអង្គនោះព្រះនាម **សុនន្ទៈ** បានគោរពបូជាព្រះទន្តធាតុនោះដោយសេចក្តីគោរព កាលទំលាយខន្ធរស់ជន្មាយុទៅ ក៏បានទៅបដិសន្ធិក្នុងស្ថានសួគ៌ ។ តពីនោះមកព្រះទន្តធាតុបានស្ថិតនៅក្នុងទន្តបុរៈអស់កាលយូរអង្វែង ដោយជាប់ត ៗ ពីក្សត្រមួយទៅក្សត្រមួយ រហូតមកដល់

www.elibraryofcambodia.org

កាលព្រះបាទមហាសេនគ្រងរាជសម្បត្តិក្នុងលង្កាទ្វីប ។ ចំណែកឯនគរទន្តបុរៈមានព្រះរាជាសោយរាជ្យព្រះនាមថា គុហសីវៈ គ្រងរាជសម័យជាមួយព្រះបាទមហាសេន ព្រះរាជាទាំងពីរព្រះអង្គនេះជាសម្លាញ់នឹងគ្នាដែលមិនធ្លាប់បានឃើញគ្នាឡើយ ។ ចំណែកព្រះបាទគុហសីវៈទ្រង់មិនជ្រះថ្លានឹងព្រះពុទ្ធសាសនាទេ ព្រះអង្គទ្រង់ទំនុកបំរុងពួកនិគ្រន្ថ សូម្បីព្រះអង្គកាន់តាមលទ្ធិនិគ្រន្ថក៏ពិតតែប្រជារាស្ត្រដោយច្រើនគោរពព្រះពុទ្ធសាសនា តែងនាំគ្នាទៅបូជាព្រះទន្តធាតុជាច្រើនរឿយៗ ព្រោះបានកាន់យកតាមដំណើរល្អពីបុរាណមុនៗតមក ។ កាលមហាជនបដិបត្តិយ៉ាងនេះ ថ្ងៃមួយព្រះរាជាព្រះអង្គទ្រង់ប្រថាប់ត្រង់សីហបញ្ជរទតព្រះនេត្រឃើញមហាជនធ្វើគ្រឿងសក្ការៈឱឡារិកធំធេង ទើបត្រាស់សួរអាមាត្យថា មនុស្សទាំងឡាយនាំគ្នាធ្វើអ្វី ? អាមាត្យនោះជាពុទ្ធមាមកជនទើបសរសើរពុទ្ធគុណដ៏ច្រើនហើយ ទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព ព្រះរាជាគ្រប់ៗព្រះអង្គមុនៗទ្រង់បដិបត្តិតគ្នាមកដូចព្រះអង្គឃើញព្រះនេត្រនេះឯង កាលរាងកាយបែកធ្លាយទៅហើយ ក៏បានទៅកើតក្នុងស្ថានសួគ៌ ។ កាលព្រះរាជាទ្រង់

www.elibraryofcambodia.org

ស្តាប់ពាក្យទូលនោះហើយ បានទ្រង់លះបង់ផ្លូវយល់ខុស ដែលជាមិច្ឆាទិដ្ឋិចេញ ត្រឡប់មកជ្រះថ្លាចំពោះព្រះរតនត្រៃ ទើបព្រះរាជាដេញពួកនិគ្រន្ថទាំងនោះចេញអំពីដែនរបស់ព្រះអង្គ ។ កាលណោះពួកនិគ្រន្ថនាំគ្នាចូលទៅរកព្រះបាទបណ្ឌុ ដែលជាព្រះរាជាអភិសេកឯករាជ្យធំជាងគេក្នុងជម្ពូទ្វីប ដែលប្រថាប់នៅក្នុងក្រុងបាដលិបុត្រហើយទូលញុះញង់ថា បពិត្រមហារាជ បទេសរាជឈ្មោះព្រះបាទគុហសីវៈថ្វាយបង្គំឆ្អឹងសាកសព តិះដៀលព្រះជាម្ចាស់ទាំងឡាយមានព្រះព្រហ្មជាដើម ដែលជាទីរាប់អានរបស់ព្រះអង្គ ។ ចំណែកព្រះបាទបណ្ឌុបានស្តាប់ពាក្យនិគ្រន្ថទាំងឡាយក៏បណ្តាលឱ្យទោសៈកើតឡើង ទើបត្រាស់បញ្ជាព្រះរាជាបទេសរាជរបស់ខ្លួនព្រះនាម **ចិត្តយានៈ**ថា អ្នកចូលទៅកាន់ដែនកាលិង្គៈ ហើយនាំយកព្រះបាទគុហសីវៈព្រមទាំងឆ្អឹងសាកសពដែលគេបូជានោះមក ។ ព្រះបាទចិត្តយានៈចាត់ចែងចតុរង្គសេនា ហើយស្តេចយាងទៅដែនកាលិង្គៈ ប្រាប់រឿងទាំងនោះដល់ព្រះបាទគុហសីវៈ ហើយនាំព្រះបាទគុហសីវៈព្រមទាំងទន្តធាតុ មកបង្ហាញដល់ព្រះបាទបណ្ឌុ ។ ចំណែកព្រះបាទបណ្ឌុត្រាស់បញ្ជាពួកនិគ្រន្ថ

www.elibraryofcambodia.org

ថា ព្រះគុណម្ចាស់សូមដុតឆ្អឹងសាកសពនេះទៅក្នុងគំនរភ្លើងឱ្យឆេះខ្ទិចឱ្យអស់ ។ ពួកនិគ្រន្ថសប្បាយចិត្តខ្លាំងណាស់ហើយធ្វើតាមព្រះរាជ-ឱង្ការ ស្រាប់តែក្នុងខណៈនោះផ្កាឈូកប៉ុនកង់រទេះផុសឡើងមកទទួលព្រះទន្តធាតុ ។ មនុស្សទាំងឡាយឃើញហេតុអស្ចារ្យនោះៗ ក៏បានឱ្យសាធុការរាប់រយពាន់ពោលសរសើរបូជា ដោយគ្រឿងសក្ការៈដ៏ច្រើន កាលបើដូច្នោះ ព្រះរាជាបញ្ជាឱ្យដាក់ព្រះទន្តធាតុទុកលើទ្រនាប់ដែក ហើយបញ្ជាឱ្យយកដុំដែកវាយចុះទៅ ព្រះទន្តធាតុបានលិចចុះទៅក្នុងទ្រនាប់ដែកប្រមានពាក់កណ្តាល នៅសល់ពាក់កណ្តាលឱ្យឃើញមួយចំណែកប្រាកដដូចដួងព្រះច័ន្ទផុសចេញពីកំពូលភ្នំប្រមាណពាក់កណ្តាល ។ ព្រះរាជាទតព្រះនេត្រឃើញហេតុអស្ចារ្យនោះ ហើយទ្រង់ស្ងួតព្រះទ័យជាខ្លាំង ។ ពេលនោះមាននិគ្រន្ថមួយនាក់មានចិត្តឫស្យាបានពោលពាក្យនេះដល់ព្រះបាទបណ្ឌុថា ទន្តធាតុនេះជាចំណែករាងកាយរបស់ព្រះនារាយណ៍ទើបមានអានុភាពខ្លាំងយ៉ាងនេះ បើមិនដូច្នោះទេអានុ-ភាពដូច្នេះនឹងបានមកពីណា ។ ព្រះរាជាទើបត្រាស់បញ្ជានិគ្រន្ថទាំងឡាយថា បើដូច្នោះអ្នកចូរចាប់ទាញទន្តធាតុនោះចេញមកពីទ្រនាប់

www.elibraryofcambodia.org

## ៥៥. ជាងឈើឈ្មោះសុភទ្ទៈអាចទាញព្រះធាតុពីទ្រនាប់ដែក

ដែកដោយអានុភាពរបស់ព្រះនារាយណ៍លមើល ពួកនិគ្រន្ថទាំងនោះសូម្បីព្យាយាមដោយប្រការផ្សេងៗ ក៏មិនអាចចាប់ទាញព្រះទន្តធាតុនោះបានឡើយ ។ គ្រានោះ ព្រះរាជាទ្រង់រង្កៀសពួកនិគ្រន្ថទាំងនោះ ទ្រង់រកឧបាយបណ្ដេញចេញឱ្យផុត ទើបវាយគងប្រកាសទូទាំងនគរថា អ្នកណាអាចយកទន្តធាតុចេញបាន អ្នកនោះនឹងបានទ្រព្យដ៏ធំ ។ គ្រានោះ មានជាងឈើម្នាក់មានឈ្មោះ **សុភទ្ទៈ**ជាបុត្រសេដ្ឋីមានសេចក្ដីជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ទើបធ្វើសច្ចកិរិយា( អធិដ្ឋានអាងពាក្យពិត ) ជាច្រើន ហើយទាញព្រះទន្តធាតុចេញពីទ្រនាប់ដែកដោយបានសំដែងបាដិហារិយ៍ផ្សេងៗ ។ ពេលនោះពួកនិគ្រន្ថក្រាបទូលព្រះរាជាថា បពិត្រមហារាជ នេះមានបានដោយអំណាចកំលាំងវិជ្ជារបស់គេ ។ ព្រះរាជាត្រាស់ទៅកាន់សុភទ្ទៈជាងឈើថា អ្នកចូរធ្វើឱ្យមនុស្សទាំងនេះជឿកាន់យក ហើយក៏បានធ្វើបាដិហារិយ៍អស្ចារ្យផ្សេងៗឱ្យសាធុជនទាំងនោះជឿកាន់យក ។ តែទោះបីយ៉ាងណាពួកនិគ្រន្ថនៅតែធ្វើឱ្យព្រះរាជាអ្នកមានបញ្ញាទន់ខ្សោយយល់ថា នោះជាការលេងកលរបស់គេ ហើយនាំយកព្រះទន្តធាតុទៅបោះចោលក្នុងរណ្ដៅភក់

www.elibraryofcambodia.org

ជ្រាំ គ្រាន់តែទំលាក់ទៅភ្លាមស្រាប់តែមានផ្កាឈើផ្សេង ៗ មានក្លិនក្រអូបដូចផ្កាឈើក្នុងស្រះនន្ទវ័នស្ថានតាវត្តិង្សផុសមកទទួលទៅវិញ ។ គ្រានោះសប្បុរសជនទាំងឡាយបានឱ្យពរសាធុការច្រើនរយពាន់ និងជាវត្ថុដ៏អស្ចារ្យដ៏ច្រើនអនេក ។ អាមាត្យទាំងឡាយឃើញវត្ថុដែលជាអចិន្តេយ្យនោះហើយ ទើបចូលទៅក្រាបទូលព្រះរាជាឱ្យទ្រង់ជ្រាបហេតុអស្ចារ្យផ្សេង ៗ ។ ព្រះរាជាទ្រង់គ្រាន់ស្តាប់ហេតុផលនោះភ្លាមហើយ ក៏អស់សេចក្តីសង្ស័យទ្រង់ជ្រះថ្លាចំពោះព្រះទន្តធាតុ បើដូច្នោះអ្នកចូរនាំព្រះទន្តធាតុនោះ អំពីរណ្តៅឥឡូវនេះភ្លាម យើងនឹងគោរពបូជាខ្លះ បានឮមកថាគ្រានោះ ព្រះទន្តធាតុធ្វើបាដិហារិយ៍ដ៏ច្រើនអនេកជាហេតុធ្វើឱ្យព្រះរាជាទ្រង់ជ្រះថ្លារកប្រមាណមិនបាន ហើយឱ្យយកទៅប្រតិស្ឋានក្នុងមណ្ឌៀរដែលវិចិត្រស្អាតដ៏ក្រៃលែង ហើយទ្រង់បូជាដោយពិធីបូជាផ្សេង១ ហើយទ្រង់ក៏បូជាដោយរាជសម្បត្តិរបស់ព្រះអង្គ ។ បានឮមកថា គ្រានោះមានព្រះរាជាមួយព្រះអង្គព្រះនាមព្រះបាទខិរធារៈបានចាត់ក្បួនច្បាំង ព្រមដោយចតុរង្គសេនាឡោមព័ទ្ធក្រុងបាដលិបុត្រ ។ ចំណែកព្រះបាទបណ្ឌុក៏ចាត់ក្បួនតតបទៅដោយ

www.elibraryofcambodia.org

ចតុរង្គសេនាច្រើនហើយបានជ័យជំនះពិឃាតព្រះបាទខិរធារៈនោះទៅ ។ ព្រះបាទបណ្ឌុទ្រង់បានទំនុកបំរុងព្រះបាទគុហសីវៈ ដោយរាជទ្រព្យដ៏ច្រើន ហើយទ្រង់ព្រះរាជទានព្រះទន្តធាតុ ដល់ព្រះបាទគុហសីវៈវិញក្នុងបច្ឆិមកាល ។ ព្រះបាទបណ្ឌុបានប្រគល់រាជសម្បត្តិឱ្យដល់ព្រះសាមី (ក្មួយ) និងព្រះធីតារបស់ព្រះអង្គ ។ ខាងក្រោយមកក៏បែកធ្លាយរាងកាយទៅកើតក្នុងស្ថានតាវត្តិង្ស ។

ចំណែកព្រះបាទគុហសីវៈអារាធនាព្រះទន្តធាតុនោះ ទៅកាន់ក្រុងទន្តបុរៈហើយទ្រង់ធ្វើការបូជាអស់កាលយូរអង្វែង និងព្រះអង្គបានប្រគល់ព្រះរាជធីតាព្រះនាម **ហេមជាលា** ឱ្យដល់ **ទន្តកុមារ** ជាភាគិនេយ្យរបស់ព្រះអង្គព្រះរាជបុត្ររបស់ព្រះបាទ **ឧជ្ជេនី** ។ គ្រានោះ នៅមានព្រះរាជកុមារមួយពួកដែលជាភាគិនេយ្យរបស់ព្រះបាទខិរធារៈ . បាននាំគ្នាកេៀងគរកម្លាំងទ័ពហើយលើកយកមកច្បាំងក្រុងទន្តបុរៈ ដើម្បីដណ្ដើមយកព្រះទន្តធាតុ ។ ព្រះបាទគុហសីវៈទ្រង់ជ្រាបដំណឹងសត្រូវនោះហើយ ទើបត្រាស់ហៅទន្តកុមារមកត្រាស់ថា បាកាលបើជីវិតរបស់បិតានៅរស់នៅឡើយ បិតាមិនព្រមឱ្យទន្តធាតុ

www.elibraryofcambodia.org

ដល់អ្នកដទៃឡើយ តែបើបិតាមិនអាចតស៊ូរាជកុមារទាំងនោះទេ បាចូរក្លែងខ្លួនជាព្រាហ្មណ៍អារាធនាព្រះធាតុទៅលង្កាទ្វីបចុះ ព្រោះថាក្នុងលង្កាទ្វីប ព្រះបាទមហាសេនៈជាសម្លាញ់របស់បិតា ។ កាលទ្រង់ប្រាប់ហើយក៏ចាត់ក្បួនច្បាំងតប ស្ដេចទៅច្បាំងនឹងរាជកុមារទាំងនោះ ព្រះអង្គទ្រង់ក៏សោយទិវង្គតក្នុងសមរភូមិ ។

ចំណែកទន្តកុមារបានជ្រាបដំណឹងអាក្រក់ ក៏ប្រញាប់អារាធនាព្រះទន្តធាតុហើយក្លែងខ្លួនជាព្រាហ្មណ៍ ទៅកាន់ទក្ខិណប្រទេស ដោយអានុភាពរបស់ទេវតាធ្វើឱ្យព្រះរាជកុមារអាចឆ្លងស្ទឹងដ៏ធំ ដែលពេញពោរប្រៀបដោយទឹកបាន ហើយកប់ព្រះធាតុលាក់ក្នុងគំនរខ្សាច់ ។ គ្រានោះ ព្រះអង្គទ្រង់ត្រឡប់ទៅកាន់ទន្តបុរៈម្ដងទៀតនាំយកជាយាព្រះអង្គក្លែងខ្លួនដូចគ្នា ទៅកាន់ទីលាក់ព្រះទន្តធាតុយ៉ាងប្រញាប់ហើយព្រះអង្គព្រមទាំងជាយាបានពួនសម្ងំក្នុងគុម្ពឈើមួយដើម ជិតព្រះទន្ត-ធាតុនោះ ។ លំដាប់នោះ មានព្រះថេរៈមួយព្រះអង្គសម្រេចអភិញ្ញា ៦ ឃើញពន្លឺភ្លឺចេញពីគំនរខ្សាច់ ក៏និមន្តចុះទៅនមស្សការព្រះទន្ត-ធាតុនោះ រាជកុមាររាជកុមារីឃើញព្រះថេរៈអង្គនោះ ក៏ចូលទៅ

www.elibraryofcambodia.org

នមស្សការថ្វាយបង្គំ ហើយពោលរឿងរ៉ាវមករបស់ខ្លួនទាំងអស់ដល់ព្រះថេរៈជ្រាប ។ ព្រះថេរៈមានថេរដីកាតបថា បើសិនមានអន្តរាយអ្វីកើតឡើងក្នុងរវាងផ្លូវ សូមឱ្យរលឹកដល់អាត្មាចុះ ពេលនោះព្រះថេរៈក៏សំដែងធម៌ដ៏សមគួរល្មមហើយចៀសចេញទៅ ។ គ្រានោះឯងនាគរាជ ឈ្មោះ បណ្ឌុហារៈចេញមកពីនាគពិភពត្រាច់លេង ឃើញព្រះទន្តធាតុ ក៏លេបប្រអប់កែវបញ្ចុះព្រះទន្តធាតុក្នុងទីនោះទៅ ហើយក៏ទៅដេកព័ទ្ធភ្នំសិនេរុ ដោយភ្នត់កន្ទុយរបស់ខ្លួន ។ លុះព្រឹកឡើងព្រះរាជកុមារនិងជាយាប្រាថ្នានឹងធ្វើដំណើរតទៅទៀត ទើបទ្រង់ទៅទីគំនរខ្សាច់ ដែលតម្កល់ព្រះទន្តធាតុស្រាប់តែមិនឃើញព្រះធាតុនៅក្នុងទីនោះ ទើបទ្រង់កន្ទ្បែងឃំសោកឡើង ហើយក៏រលឹកដល់ព្រះមហាថេរៈក្នុងខណៈនោះ ។ ចំណែកព្រះថេរៈ ជ្រាបកាលរលឹកដល់របស់រាជកុមារនោះ ទើបសំឡឹងដោយទិព្វចក្ខុឃើញរាជនាគកំពុងលេបប្រអប់ព្រះធាតុដេកព័ទ្ធភ្នំសិនេរុ ទើបនិមិត្តរាងកាយជាគ្រុឌធំហោះទៅកាន់មហាសមុទ្រ ដោយកំលាំងខ្យល់ស្លាបរបស់ខ្លួន គ្រានោះរាជនាគភ័យខ្លាចយ៉ាងខ្លាំង លះជាតហើយចូលទៅរកព្រះថេរៈ ដោយ

www.elibraryofcambodia.org

ភេទជាមនុស្សនិយាយយ៉ាងនេះថា បពិត្រលោកម្ចាស់ខ្ញុំនាំព្រះទន្តធាតុ មកដោយគិតថា ដោយអានុភាពនៃព្រះធាតុនេះ សូមឱ្យខ្ញុំចុតិចាក អត្តភាពនេះទៅកាន់ស្ថានសួគ៌ ។ ព្រះមហាថេរៈពោលដល់រាជនាគថា មហារាជព្រះធាតុអង្គនេះ គួរដល់អ្នកត្រាស់ដឹងនូវសច្ចធម៌ប៉ុណ្ណោះ នឹងប្រតិស្ឋានក្នុងលង្កាទ្វីប ព្រោះហេតុនោះ សូមឱ្យដល់អាត្មាមក វិញចុះ ។ រាជនាគក៏បានថ្វាយប្រអប់បញ្ចុះព្រះធាតុដល់ ព្រះថេរៈ វិញ ព្រះមហាថេរៈក៏បាននាំយកព្រះទន្តធាតុនោះ មកប្រគល់ឱ្យ រាជកុមារនិងជាយាហើយចៀសចេញទៅ ។ ព្រះរាជកុមារបានលើក ព្រះធាតុដាក់ទូលលើសីសៈ ដោយអានុភាពនៃព្រះទន្តធាតុនោះ ទេវតា ទាំងឡាយនាំគ្នាគ្រប់គ្រងរក្សាមិនឱ្យមានជម្ងឺឈឺថ្កាត់ឡើយ ។ ព្រះ រាជកុមារនិងជាយាធ្វើដំណើរតាមលំដាប់រហូតបានមក ដល់កំពង់ស្ទឹង តម្ពលិត្តៈហើយខត្តិយកុមារទាំងពីរ ដែលទ្រង់ភេទជាព្រាហ្មណ៍ក៏ចុះទូក ជាមួយឈ្មួញឆ្លងមហាសមុទ្រទៅ ។ ចំណែកនាគទាំងឡាយចេញពី នាគពិភពធ្វើការបូជាដោយគ្រឿងសក្ការៈដ៏ធំ ឯទូកក៏ឈប់នឹងថ្កល់ ត្រង់កណ្តាលសមុទ្រអស់ ៧ ថ្ងៃ ។ ចំណែកពួកឈ្មួញនាំគ្នាភ័យ

www.elibraryofcambodia.org

តក់ស្លុតនឹងសេចក្ដីស្លាប់ទាំងអស់គ្នា ។ កាលបានឃើញដូច្នោះ ព្រះរាជកុមារនិងជាយាបានរលឹកដល់ព្រះថេរៈក្នុងពេលនោះភ្លាម ពេលនោះឯង ព្រះថេរៈជ្រាបហេតុនោះហើយ ក៏ក្លែងខ្លួនជាគ្រុឌបណ្ដេញនាគទាំងនោះឱ្យចៀសចេញទៅ ។ ចំណែកទូកក៏មកដល់កំពង់លង្កាបដ្ដនៈក្នុងខណៈនោះ ដោយឫទ្ធិរបស់ព្រះថេរៈ ។

បានឮមកថា ក្នុងកាលណោះឯង ព្រះរាជបុត្ររបស់ព្រះបាទមហាសេនៈ ព្រះនាម **តិត្ថសិរិមេឃៈ** ជាក្សត្រអភិសេកហើយបាន ៩ ឆ្នាំ ។ ក្នុងវេលាល្ងាចថ្ងៃ ដែលទូកទៅដល់កំពង់រាជកុមារនិងជាយាបានសម្រាកត្រង់ទេវាល័យ ។ ព្រាហ្មណ៍បុរោហិតរបស់ព្រះរាជាឃើញស្វាមីនិងភរិយាដើរតែងខ្លួនជាព្រាហ្មណ៍ ទើបបដិបត្តិទំនុកបំរុងស្វាមីភរិយានោះដោយសេចក្ដីពេញចិត្ត ហើយបានប្រាប់ផ្លូវទៅកាន់ក្រុងអនុរាធបុរីដល់ស្វាមីភរិយានោះ ។ ក្នុងថ្ងៃព្រឹកឡើង ស្វាមីភរិយានោះធ្វើដំណើរទៅស្រុកជិតទ្វារក្រុងអនុរាធបុរី ទើបបានជ្រាបដំណឹងការសោយទិវង្គតរបស់ព្រះបាទមហាសេនៈ ស្វាមីភរិយាទាំងពីរនាក់ក៏យំខ្សឹកខ្សួលហូរទឹកភ្នែកឡើង តែកាលបានជ្រាបដំណឹងថា ព្រះបាទ

www.elibraryofcambodia.org

កិត្តិសិរិមេឃៈជាព្រះរាជបុត្ររបស់ព្រះបាទមហាសេនៈ ជាអ្នករាប់អាន រាប់កាន់ព្រះរតនត្រៃ ក៏បន្ទោបង់សេចក្តីសោកបន្តិចហើយទាំងពីរនាក់ ស្វាមីភរិយានោះក៏ចូលទៅរកព្រះមហាថេរៈមួយអង្គ ដែលជាទីរាប់ អានរបស់ព្រះរាជា នៅក្នុងមេឃមហាវិហារទិសខាងលិចឆៀងខាង ជើងក្រុងអនុរាធបុរី ។ ហើយពោលប្រវត្តិមកតាមលំដាប់ឱ្យព្រះថេរៈ ជ្រាបទាំងអស់ ចំណែកព្រះថេរៈបានស្តាប់ប្រវត្តិព្រះធាតុនោះហើយក៏ មានចិត្តរីករាយ ទើបអារាធនាព្រះធាតុចូលទៅក្នុងកុដិរបស់ខ្លួនធ្វើ ការអនុគ្រោះជួយដល់ស្វាមីភរិយានោះ ហើយប្រើភិក្ខុមួយអង្គទៅ ពោលប្រវត្តិការណ៍មករបស់ព្រះធាតុឱ្យព្រះរាជាទ្រង់ជ្រាប ។ ក្នុងថ្ងៃ នោះ ព្រះរាជាកំពុងទ្រង់ក្រសាលឧទ្យានជាមួយពួកនាងរបាំទាំងឡាយ ក្នុងរដូវភ្លៀង លុះព្រះអង្គទ្រង់ជ្រាបការណ៍មករបស់ព្រះធាតុអំពីភិក្ខុ នោះប៉ុណ្ណោះ ក៏ទ្រង់កើតបីតិដ៏មានកម្លាំងខ្លាំងក្លាដូចបានសម្បត្តិស្តេច ចក្រពត្តិ ។ បានឮថា ព្រះរាជាបានស្តាប់ពាក្យទាយរបស់ហោរាមុន មកហើយថា និងមានស្វាមីភរិយាពីរនាក់ទ្រង់ភេទជាព្រាហ្មណ៍ នាំព្រះ ទន្តធាតុរបស់ព្រះពុទ្ធមកមិនយូរ ។ គ្រានោះព្រះរាជាទ្រង់យាង

www.elibraryofcambodia.org

ដោយព្រះបាទអំពីឧទ្យានចូលទៅកាន់មេឃគិរីវិហារ ទតព្រះនេត្រឃើញព្រះទន្តធាតុរបស់ព្រះពុទ្ធទ្រង់សំដែងបាដិហារ្យច្រើនយ៉ាង ហើយទ្រង់កើតបីតិបាមោជ្ជៈច្រើន ទ្រង់សក្ការបូជាដោយគ្រឿងសក្ការៈពិសេសច្រើនយ៉ាង ហើយអារាធនាព្រះទន្តធាតុទៅប្រតិស្ឋានលើរាជរថបុស្បុក (រាជរថសទឹមដោយសេះស) លើទង់ដ៏រីចូលក្បួនដង្ហែទូទៅនគរ ហើយដង្ហែមកក្រុងអនុរាធបុរី ។ គ្រាដង្ហែមកហើយក៏បានយកទៅ ប្រតិស្ឋានព្រះធាតុលើព្រះទែនក្នុងបន្ទប់ព្រះធាតុ ដែលប្រដាប់ដោយរតនៈច្រើនប្រការ ធ្វើពិធីសក្ការបូជាដោយពិធីបូជាដ៏ច្រើន ហើយបានបដិបត្តិទំនុកបំរុងព្រះទន្តធាតុដោយសេចក្តីគោរព ។ ព្រះរាជាបានព្រះរាជាទានសក្ការៈដ៏ធំក្រៃលែងនិងដំណែងដ៏សមគួរដល់រាជកុមាររាជកុមារីជាស្វាមីភរិយាទាំងពីរអង្គនោះ និងព្រះរាជាអង្គនោះទ្រង់សក្ការបូជាព្រះទន្តធាតុរបស់ព្រះពុទ្ធ ទ្រង់បុណ្យបារមីដ៏ធំធេងកាលបែកធ្លាយរាងកាយទៅ ក៏បានទៅបដិសន្ធិក្នុងស្ថានតាវត្តិង្ស ។ ព្រះទន្តធាតុខាងឆ្វេង (ខាងលើ) នោះជាបូជនីយវត្ថុគួរដល់ការបូជាពិសេសយ៉ាងក្រៃលែងរបស់ព្រះមហាក្សត្រលង្កាទ្វីប តព្រះរាជបុត្រ

www.elibraryofcambodia.org

ព្រះរាជនត្តា ព្រះរាជបនត្តា រហូតមកដល់សព្វថ្ងៃ ។ ព្រះទន្តធាតុខាងឆ្វេងរបស់ព្រះសាស្តា ប្រតិស្ឋានក្នុងលង្កាទ្វីបកាលវស្សានរដូវ ឆ្នាំទី ៧៤០ ក្រោយពីព្រះសាស្តាទ្រង់បរិនិព្វានទៅ បណ្ឌិតទាំងឡាយគប្បីជ្រាបដូច្នេះឯង ។

## ចប់ព្រះវាមទន្តធាតុគឺចង្កូមកែវឆ្វេងមកលង្កាទ្វីប

នៅក្នុងតម្រាគម្ពីរទាំងនេះជាបាលីដែលលើកមកពីគម្ពីរទាឋវិស (ទាឋវំស្ស) ដែលព្រះថេរៈជនជាតិសិរីលង្កា (មានពោលទុកក្នុងគម្ពីរចូឡគន្ថវិស) ជាអ្នករៀបរៀងឡើង ហើយពោលទុកតាមគ្នាត១មក នៅក្នុងតម្រានេះមានប្រាកដពីព្រះធាតុមកពីកាលិង្គរដ្ឋ ជាវាមទន្តធាតុ បើសិនជាយើងប្រែទៅតី ទន្ត បើប្រែចំស័ព្ទថា ធ្មេញ វាម ប្រែថា ខាងឆ្វេង តែតាមក្នុងទីនេះ ឱ្យប្រែថា ចង្កូមកែវ ។ តែទោះបីនៅក្នុងតម្រានេះពោលថា ព្រះធាតុបានមកពីកាលិង្គរដ្ឋ ជាវាមទន្តធាតុព្រះចង្កូមកែវខាងឆ្វេងក៏ដោយ តែពាក្យនោះមិនត្រូវគ្នា និងគម្ពីរព្រះត្រៃបិដក លេខ ១៦ ទំព័រ ៣៤៩ ដែលពោលថា ៖

**ឯកា ហិ ទាឋា តិទិវេហិ បូជិតា**

www.elibraryofcambodia.org

**ឯកា បន គន្ធារបូរេ មហិយ្យតិ**
**កាលិង្គរញ្ញោ វិជិតា បុនេកំ**
**ឯកំ បុន នាគរាជា មហេន្តិ ។**
**ព្រះទាឋា (ចង្កូម)១ ពួកទេវតា**
**នាំយកទៅបូជា ព្រះទាឋា ១**
**ទៀត ពួកជនធ្វើសក្ការបូជា**
**ក្នុងគន្ធារបុរី ព្រះទាឋា ១**
**ទៀត ពួកជនធ្វើសក្ការបូជា**
**ក្នុងដែនរបស់ស្តេចកាលិង្គ ព្រះ**
**ទាឋា ១ ទៀត ពួកនាគរាជ**
**នាំយកទៅធ្វើសក្ការបូជា ។**

នៅក្នុងបាលីបិដកជាតម្រាទេះអដ្ឋកថាបានបញ្ជាក់ថា ព្រះថេរៈនៅក្នុងកោះតាម្ពបណ្ណិទ្វីបបានពោលទុកមក (ប្រហែលក្នុងពេលចារព្រះត្រៃបិដកចុះក្នុងសាស្ត្រាស្លឹករិត្ត[១] ? ) ។ នៅក្នុងគម្ពីរព្រះត្រៃបិដកបានពោលហើយថា ព្រះចង្កូមកែវមានតែពីរក្នុងមនុស្សលោក គឺនៅក្នុង

១.ពាក្យថា សាស្ត្រាស្លឹករឹត នេះគួរតែសរសេរ ថា សាស្ត្រាស្លឹករិត្ត វិញ ព្រោះ រិត្តៈជាភាសាបាលី ដូចពាក្យនៅក្នុងអដ្ឋកថា បបញ្ចសូទនីថា រិត្តពោត្តកេ ប្រែថា សាស្ត្រាស្លឹករិតបើតាមច្បាប់ត្រូវថែរក្សាពាក្យបាលីទុកដូចដើម ត្រូវសរសេរថា សាស្ត្រាស្លឹករិត្ត ។

www.elibraryofcambodia.org

ដែនកាលិង្គ ១ និងក្នុងដែនគន្ធារបុរី ១ ។ ព្រះចង្កូមកែវនៅក្នុងដែនកាលិង្គៈនេះត្រូវបានធ្លាក់មកក្នុងកោះសិរីលង្កា ដូចពោលមកហើយ តែគម្ពីរដែលថា ព្រះចង្កូមដែលធ្លាក់មកនោះ ជា ខាមទន្តធាតុព្រះទន្តធាតុគឺចង្កូមកែវខាងឆ្វេងទៅវិញ ។ ហើយនៅក្នុងគម្ពីរតម្រារបស់សិរីលង្កាគឺទាឋវិស និងជិនកាលមាលិបករណ៍ហើយសង្គិតិយវង្សសុទ្ធតែលើកយកពីតម្រារបស់ទាឋវិស ( តម្រារបស់សិរីលង្កា ) មកពោលទាំងអស់ ។ ហើយបញ្ជាក់ការមករបស់ទក្ខិណទាឋធាតុ គឺចង្កូមកែវខាងស្តាំផ្សេងពីព្រះធាតុបានពីកាលិង្គរដ្ឋថា ៖

បានឮមកថា កាលព្រះបាទគោធាភយៈសោយទិវង្គតទៅ ព្រះរាជកុមារកាកវណ្ណតិស្សៈ បានឡើងគ្រងរាជ្យសម្បត្តិ ។ បានឮថា ព្រះបាទកាកវណ្ណតិស្សៈអាចស្តាប់សំឡេងសត្វក្អែកបាន ទើបទ្រង់មានព្រះនាមយ៉ាងនោះ ព្រះអង្គមានអគ្គមហេសីទ្រង់ព្រះនាមថា ព្រះនាងវិហារទេវី ជាព្រះធីតារបស់ក្សត្រក្រុងកល្យាណី និងព្រះនាងនោះមានព្រះរាជឱរស ២ ព្រះអង្គ គឺព្រះបាទគាមិនិអភ័យនិង តិស្សៈ ( សទ្ធាតិស្សៈ ) ។ ឯព្រះបាទកាកវណ្ណតិស្សៈមហារាជ មានព្រះភគិនី

www.elibraryofcambodia.org

(ប្អូនស្រី) ព្រះនាមថា សោមទេវី បានជាអគ្គមហេសីរបស់ព្រះបាទអភយរាជកុមារ ជាព្រះរាជភាគិនេយ្យ (ក្មួយ) របស់ព្រះបាទសិរីមហារាជក្នុងក្រុងកល្យាណី ។ កាលព្រះរាជកុមារអភយៈគ្រងរាជ្យក្នុងគិរិនគរនោះ ព្រះបាទកាកវណ្ណតិស្សៈទ្រង់ហៅ ទុដ្ឋគាមិនី-អភ័យជាព្រះរាជបុត្ររបស់ព្រះអង្គមកហើយ ត្រាស់បញ្ជាឱ្យទៅកាន់គិរិនគរ ហើយទ្រង់តាំងអាមាត្យម្នាក់ឱ្យឋានៈជាបិតារបស់ទុដ្ឋគាមិនី-អភ័យហើយបញ្ជូនទៅគិរិនគរ ។ ខាងក្រោយមកព្រះបាទអភយៈនិងព្រះរាជកុមារគាមិនីអភ័យកើតវិវាទទាស់ទែងគ្នាឡើង ព្រោះហេតុជាតិជាក្សត្រដូចគ្នា ។ ព្រះបាទអភយៈទើបនាំពលពាហនៈនិងទេវីរបស់ព្រះអង្គយាងទៅនគរសេរុ ។ ឯក្សត្រនគរសេរុ ទ្រង់ព្រះនាមថា សិវរាជជាសម្លាញ់របស់ព្រះបាទអភយៈ និងក្សត្រនគរសេរុនោះបានសាងនគរឡើងមួយ មានស្ថានទីភូមិភាគគួរីករាយនៅទីបំផុតបឹងធំហើយប្រទានឱ្យដល់ព្រះបាទអភយៈ ។ ព្រះបាទអភយៈទ្រង់តាំងនគរនោះ ឱ្យដូចនាមរបស់ព្រះទេវីថា សោមនគរ តែសោមនគរនោះបរិបូណ៌ដោយបាយទឹកអាហារនិងទ្រព្យមាសប្រាក់ច្រើន ។ ព្រះបាទ

www.elibraryofcambodia.org

អភយៈទ្រង់សោយរាជ្យនៅក្នុងសោមនគរនោះរហូតទៅ ។

គ្រាខាងក្រោយមក ព្រះនាងសោមទេវី ប្រឹក្សាជាមួយព្រះរាជស្វាមីថា ក្នុងនគររបស់យើងមិនមានចេតិយនិងវត្តនៅឡើយ ព្រោះហេតុដូច្នោះគួរសាងព្រះចេតិយឡើង ។ ព្រះបាទអភយៈទ្រង់ទទួលពាក្យថា ល្អហើយ ទើបស្វែងរកស្ថានទីកសាងវត្តទ្រង់ទតឃើញព្រៃសាលវ័នមួយខាងក្រៅនគរ មិនឆ្ងាយពេកមិនជិតពេក ។ បានឮថាព្រះថេរៈមួយអង្គជាវង្សរបស់ព្រះមហាអរិដ្ឋៈ ព្រះនាម ព្រះមហិន្ទត្ថេរៈបានមក នៅក្នុងវិហារនោះ ជាមួយព្រះភិក្ខុ ៦០ អង្គ ។ ព្រះរាជាទ្រង់ពេញព្រះរាជហឫទ័យស្ថានទីនោះ ទើបទ្រង់ចាត់ឱ្យសាងព្រះវិហារនិងបន្ទប់ បញ្ចុះប្រតិស្ឋានព្រះធាតុ ហើយត្រាស់សួរព្រះថេរៈថាបពិត្រលោកម្ចាស់ដ៏ចំរើនតើខ្ញុំព្រះករុណា នឹងបានព្រះធាតុមកពីណា ? ព្រះថេរៈទើបថ្វាយ ព្រះចង្កូមកែវខាងស្តាំរបស់ព្រះតថាគតដែលខ្លួនរក្សាទុកមក ( **តទា ថេរោ អត្តនា បរិហរណំ សត្ថុនោ ទក្ខិណទាឋធាតុំ រញ្ញោ អទាសិ** ) ។ ព្រះរាជាទ្រង់សោមនស្សត្រេកអរក្រៃលែង កាលបានសុនក្ខត្តឫក្សល្អហើយ ទើបប្រតិស្ឋាន

www.elibraryofcambodia.org

ព្រះទក្ខិណទាឋធាតុនោះក្នុងបន្ទប់ព្រះធាតុ ហើយទ្រង់ប្រោសឱ្យសាង ចេតិយលើកំពូលភ្នំឧទកបុព្ពលកេលសបពិតដែលមានវិចិត្រក្រៃលែង។ ព្រះរាជានិងព្រះនាងទេវីបានធ្វើសក្ការបូជាព្រះធាតុជាធំ និងទ្រង់ថ្វាយ មហាទានចំពោះព្រះភិក្ខុសង្ឃមានព្រះមហិន្ទត្ថេរជាប្រធាន (ព្រះម-ហិន្ទត្ថេរសម័យក្រោយមិនមែនព្រះរាជបុត្រព្រះបាទធម្មាសោកទេ) ។ ព្រោះហេតុនោះព្រះគន្ថរចនាចារ្យបានប្រព័ន្ធគាថាទុកថា ៖

**សោមវ្ហយេ រម្មណីយេ សមិទ្ធេ**
**បុរេ និវន្តោ គិរិរាជសោកោ**
**មហិន្ទត្ថេរោ ច អរិយវំសោ**
**ទន្តធាតុំ ទក្ខិណំ បតិដ្ឋាសិ ។**
**ព្រះបាទគិរិរាជាសោកជាធំលើ**
**មហាជន និង ព្រះមហិន្ទត្ថេរ**
**ជាវង្សព្រះអរិយៈ បានប្រតិស្ឋាន**
**ព្រះទន្តធាតុ ខាងស្តាំ ក្នុងក្រុង**
**សោមបុរៈជាក្រុងគួរីករាយ**

www.elibraryofcambodia.org

ដោយទឹកនិងអាហារ ។

តែការសិក្សានៅក្នុងព្រះត្រៃបិដកឃើញថា ព្រះធាតុ ១ នៅក្នុងក្រុងកាលិង្គៈ ហើយព្រះធាតុនេះឯងត្រូវធ្លាក់មកក្នុងលង្កាទ្វីបដូចពោលខាងដើម តែទាស់ថា ព្រះធាតុដែលបានពីកាលិង្គៈនោះជាព្រះចង្កូមកែវខាងឆ្វេងទៅវិញ ចំណែកប្រទេសសិរីលង្កាសព្វថ្ងៃបានអះអាងថាព្រះធាតុនៅក្នុងក្រុងកន្ទីនេះ ជាព្រះទក្ខិណទាឋធាតុ ព្រះចង្កូមកែវខាងស្តាំ ហើយថែមទាំងមានការគូររូបទន្តកុមារ ដែលយកព្រះធាតុមកលង្កាទ្វីបទៀតផង ។ ហើយមានការពោលពីការមកព្រះទក្ខិណទាឋធាតុផ្សេងគ្នា ដូចពោលខាងដើម ។ តាមនៅក្នុងគម្ពីរប្រភពសិរីលង្កាបានបញ្ជាក់ឱ្យឃើញថា ប្រទេសសិរីលង្កាមានព្រះចង្កូមកែវដល់ទៅពីរឯណោះ តែពិតប្រាកដនោះ មានតែមួយគាត់ ព្រោះហេតុអ្វីទើបពោលយ៉ាងនេះ? ព្រោះក្នុងព្រះត្រៃបិដកបានបញ្ជាក់ថា ព្រះចង្កូមកែវ ១ នៅក្នុង កាលិង្គរដ្ឋ ព្រះចង្កូមកែវ ១ ទៀតនៅក្នុងគន្ធារបុរី ហើយចង្កូមកែវនៅក្នុងគន្ធាបុរីនេះមានប្រាកដដល់សម័យព្រះបាទកនិស្កៈ ខ្ញុំនឹងពោលតទៅខាងមុខ ។ ព្រោះហេតុនោះ ការ

www.elibraryofcambodia.org

## ព្រះចង្កូមកែវបានពីកាលិង្គរដ្ឋជាចង្កូមកែវខាងស្ដាំ

សិក្សាសាវជ្រាវរបស់ខ្ញុំយល់ឃើញថា ព្រះធាតុដែលបានពីកាលិង្គរដ្ឋនោះ គួរជាទក្ខិណទាឋធាតុ ( ព្រះចង្កូមកែវខាងស្ដាំ ) គួរមិនមែនវាមទាឋធាតុ ( ព្រះចង្កូមកែវខាងឆ្វេង ) ព្រោះចង្កូមកែវខាងឆ្វេងនៅក្នុងគន្ធាររដ្ឋបុរី ព្រះចង្កូមកែវខាងស្ដាំនៅក្នុងកាលិង្គៈ ហើយដែនកាលិង្គរដ្ឋនេះត្រូវបានមកប្រតិស្ឋានក្នុងលង្កាទ្វីប រហូតមកដល់សព្វថ្ងៃហើយរាជរដ្ឋាភិបាលនិងប្រជាជនសិរីលង្កាបានកាន់យកថា ព្រះចង្កូមកែវដែលតម្កល់នៅក្នុងទីក្រុងកន្ទី ជាមតិកបានមកពីកាលិង្គរដ្ឋ ហើយនៅអះអាងថា ព្រះចង្កូមកែវនេះជាចង្កូមកែវខាងស្ដាំខាងក្រោមទៀតផង ។ ចំណែកខ្ញុំមិនមានឧបនិស្ស័យបុណ្យកុសលគ្រប់គ្រាន់នឹងបានទៅថ្វាយបង្គំព្រះចង្កូមកែវនោះផ្ទាល់ទេ គ្រាន់បានការសិក្សានៅក្នុងគម្ពីរព្រះពុទ្ធសាសនាហើយលើកមកសម្រាប់បណ្ឌិតពិចារណាចុះ ។

ខាងក្រោយមកមានតំណាលពីព្រះទន្តធាតុថា ព្រះទន្តធាតុតែងផ្លាស់កន្លែងទៅតាមការផ្លាស់ទីតាំងរបស់ព្រះរាជា ដែលទ្រង់ផ្លាស់ទីក្រុង ។ ក្នុង ព.ស.១៩៤៣ ពួកទមិឡបានដណ្ដើមព្រះទន្តធាតុ គឺព្រះចង្កូមកែវ ពីលង្កាទៅទុកត្រង់ឥណ្ឌាខាងក្រោម តែព្រះបាទបរក្ក-

www.elibraryofcambodia.org

ពាហុព្រះចៅលង្កាក៏វាយដណ្តើមយកមកវិញបាន ។

កាលព.ស.២១០៣ ពួកបតុកេត គ្រិស្តសាសនិក និកាយរោម៉ន កត្តូលិកនៅត្រង់ទីក្រុងកូតណ្តោក្រោម បានវាយចូលមកក្រុងជពនា បានដណ្តើមយកព្រះទន្តធាតុពីចង្កូមកែវទៅក្រុងកូ ហើយវាយកំទេចបោះទៅក្នុងគំនរភ្លើងហើយយកផេ្សងទៅបោះក្នុងទន្លេ ។ តែព្រះបាទលង្កាប្រកាសថា ព្រះចង្កូមកែវដែលពួកបតុកេតយកទៅនោះជារបស់ក្លែងក្លាយទេ (របស់ប្លម) មិនមែនអង្គពិតទេ ចំណែកចង្កូមកែវពិតនោះនៅនឹងព្រះអង្គ ។ កាលព្រះបាទបុរេនងនៃប្រទេសភូមាបានជ្រាបដំណឹងនោះ ទើបប្រើមនុស្សឱ្យទៅស្វែងរកព្រះចង្កូមកែវពិតត្រង់ក្រុងចត្តៈ ក៏បានព្រះចង្កូមកែវប្លមមួយអង្គទៀត ចំណែកព្រះចៅក្រុងកន្ទី (Candy) ទ្រង់ធានារាប់រងថា ព្រះចង្កូមដែលពិតនោះនៅនឹងព្រះអង្គ ព្រះចង្កូមកែវដែលព្រះចៅបុរេនងបានទៅនោះជារបស់ប្លម គឺក្លែងក្លាយ ។ សព្វថ្ងៃនេះព្រះធាតុចង្កូមកែវពិតនេះតម្កល់ នៅទន្តប្រាសាទ ក្នុងក្រុងកន្ទី ដែលជនជាតិសិរីលង្កា តែងតែធ្វើសក្ការៈគោរពបូជា និងជនជាតិដទៃ ១ ទៀត មានជនជាតិខ្មែរជា

www.elibraryofcambodia.org

ដើម តែងតែទៅនមស្សការគោរពបូជា ។

## ព្រះឧណ្ហិសធាតុ (ថ្ងាស) ឬនលាដធាតុមកកាន់លង្កាទ្វីប

នៅក្នុងគម្ពីរជិនកាលមាលីបករណ៍ ទំព័រ ៥៦ និងគម្ពីរសម្ពីតិ-យវិស បានពោលពីការមកនៃព្រះឧណ្ហិសធាតុឬព្រះនលាដធាតុថាដូចតទៅ ៖

បានឮមកថា ក្រោយការបែងចែកព្រះបរមសារីរិធាតុ ព្រះនលាដធាតុរបស់ព្រះតថាគតធ្លាក់ជាចំណែកដល់ពួកមល្លក្សត្រ អ្នកក្រុងកុសិនារា ។ កាលនោះព្រះមហាកស្សបត្ថេរៈ ពោលឱ្យពួកមល្លក្សត្រជ្រាបថា កាលព្រះដ៏មានព្រះភាគទ្រង់គង់ធរមាននៅឡើយ ព្រះអង្គអនុញ្ញាតព្រះនលាដធាតុនេះទុកក្នុងកោះលង្កា ព្រោះហេតុនោះ សូមមហាបពិត្រអនុញ្ញាតព្រះធាតុនោះដល់អាត្មាចុះ ។ ហើយទទួលយកព្រះនលាដធាតុនោះទុក ក្រោយមកក៏ប្រគល់ឱ្យព្រះនន្ទត្ថេរៈជាសទ្ធិវិហារិករបស់ខ្លួន ហើយប្រាប់នូវធាតុវង្សថា **ឥមំ នលាដំ តម្ពបណ្ណិទីបេ មហាគង្គាយ ទក្ខិណភាគេ សេរុនាមរហទស្ស អាគ្នេ វរភស្សនាមសោណ្ឌិយមត្ថកេ កាកវណ្ណតិស្សោ នាម**

www.elibraryofcambodia.org

**រាជា បតិដ្ឋបេស្សតិ សចេតិយំ សង្ឃារាមំ ការាបេស្សតិ ។**

ព្រះរាជាមួយព្រះអង្គព្រះនាមកាកវណ្ណតិស្សៈ នឹងអារាធនានូវព្រះធាតុនេះប្រតិស្ឋានទុកខាងលើស្ទឹង ឈ្មោះ វរភស្សៈ នៅទីបំផុតស្រះឈ្មោះសេរុ ផ្នែកទក្ខិណភាគស្ទឹងមហាគង្គា ក្នុងលង្កាទ្វីប ហើយព្រះរាជាអង្គនោះទ្រង់សាងសង្ឃារាមព្រមទាំងព្រះចេតិយឡើង ។ ហើយប្រាប់ដល់ព្រះនន្ទត្ថេរៈទៀតថា អ្នកចូរប្រតិស្ឋាននូវនលាដធាតុនេះក្នុងព្រះគន្ធកុដិ ដែលព្រះសាស្ដាទ្រង់គង់ប្រថាប់ក្នុងកូដាគារសាលានាព្រៃមហាវ័ន ជិតនគរវេសាលី ហើយធ្វើសក្ការបូជា កាលអ្នកជរាអស់សង្ខារហើយ ចូរណែនាំសទ្ធិវិហារិករបស់ខ្លួនឱ្យប្រាបត១ត្ថា ។ ក្រោយមកព្រះមហាកស្សបត្ថេរៈក៏បរិនិព្វានទៅ ។ ចំណែកព្រះនន្ទត្ថេរៈបានបដិបត្តិតាមព្រះមហាកស្សបត្ថេរៈប្រាប់ទុកហើយ ក៏ឯសទ្ធិវិហារិករបស់ព្រះនន្ទត្ថេរៈព្រះនាមថា ចន្ទគុត្តត្ថេរៈ បានបដិបត្តិដូចគ្នា គឺប្រតិស្ឋានព្រះនលាដធាតុនោះ ទុកក្នុងព្រះគន្ធកុដិដែលព្រះទសពលទ្រង់គង់ប្រថាប់ ក្នុងព្រះវិហារជេតពនជិតក្រុងសាវត្ថី ហើយធ្វើការបូជារហូតបរិនិព្វាន និងសទ្ធិវិហារិករបស់ព្រះចន្ទគុត្តត្ថេរៈព្រះនាម

www.elibraryofcambodia.org

ភទ្ទសេនត្ថេរៈ ក៏បានបដិបត្តិដូចគ្នាបានប្រតិស្ឋានព្រះនលាដធាតុនោះ ក្នុងព្រះគន្ធកុដិ ព្រៃឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ហើយបូជារហូតបរិនិព្វាន ។ ក៏សទ្ធិវិហារិរបស់ព្រះភទ្ទសេនត្ថេរៈព្រះនាម ជយសេនត្ថេរៈ ក៏បានបដិបត្តិដូចគ្នាគឺប្រតិស្ឋានព្រះនលាដធាតុក្នុងព្រះគន្ធកុដិ ដែលជាទីគង់នៃព្រះសម្មាសម្ពុទ្ធក្នុងវត្តវេឡុវ័នជិតក្រុងរាជគ្រឹះ បូជារហូតបរិនិព្វាន ។ ក៏សទ្ធិវិហារិករបស់ព្រះជយសេនត្ថេរៈព្រះនាម មហាសង្ឃរក្ខិត្ថេរៈ ក៏បដិបត្តិដូចគ្នាគឺប្រតិស្ឋានព្រះនលាដធាតុក្នុងព្រះគន្ធកុដិវត្តឃោសិតារាម ក្រុងកោសម្ពី បូជារហូតបរិនិព្វាន ។ ក៏សទ្ធិវិហារិរបស់ព្រះមហាសង្ឃរក្ខិត្ថេរៈព្រះនាម មហាទេវត្ថេរៈបានអារាធនា ព្រះនលាដធាតុនោះហោះតាមអាកាសហើយចុះទៅប្រតិស្ឋានទុកក្នុងគល់ឈើមហាសារៈក្នុងកក្កុដៈនាបត្តោជនបទ (មល្លជនបទ) ត្រង់ជាមួយសម័យដែលព្រះឧបយុរាជទ្រង់ព្រះនាមថា ព្រះបាទមហានាគ បានលើកស្វេតឆ័ត្រសោយរាជ្យក្នុងរោហានជនបទមហាគ្រាម កោះលង្កា ។ ក្នុងកាលនោះ ឧបាសកមួយនាក់ឈ្មោះ មហាកាលព្រម ដោយបុត្រនិងភរិយាបានបដិបត្តិទំនុកបំរុងព្រះមហាថេរៈ (ព្រះទេវ-

www.elibraryofcambodia.org

ត្ថេរៈ) ជាមួយព្រះជិនធាតុ អស់កាលដ៏យូរ ។ ម្យ៉ាងទៀត ក្នុងថ្ងៃឧបោសថមានឆព្វណ្ណរង្សីផុសឡើងអំពីព្រះធាតុ និងស្ថានទីកន្លែងនោះមានដូចព្រះបរមសម្ពុទ្ធទ្រង់គង់ព្រះធរមាននៅ ។

សួរថា ព្រះបាទមហានាគ នោះជាអ្នកណា ? ព្រះបាទមហានាគនោះជាអនុជារបស់ព្រះបាទទេវានម្បិយតិស្សៈ ដែលជាឧបរាជ ។ ព្រះមហានាគនោះខ្លាចព្រះទេវីជាមហេសីរបស់ព្រះរាម(បងថ្លៃ) ទើបនាំព្រះទេវីរបស់ព្រះអង្គនិងពលពាហនៈទៅកាន់រោហនជនបទ ។ ព្រះមហេសីរបស់ព្រះមហានាគនោះទ្រង់ប្រសូតព្រះរាជឱរស ត្រង់តំបន់លង្កាវិហារក្នុងរវាងផ្លូវ ទើបដាក់ព្រះនាមរាជឱរសថា លង្កាតិស្សៈដោយកាន់យកព្រះនាមព្រះបាទទេវានម្បិយតិស្សៈជាព្រះជេដ្ឋា និងឈ្មោះវិហារផ្សំគ្នា ទើបដាក់ព្រះនាមយ៉ាងនោះ ។ ឧបរាជកាលស្ដេចចេញពីក្រុងអនុរាធៈ ទៅប្រថាប់ក្នុងមហាគ្រាមសោយរាជ្យសម្បត្តិក្នុងរោហនជនបទ ។ ថ្ងៃមួយឧបរាជទ្រង់ជ្រាបដំណឹងព្រះនលាដធាតុ អំពីមហាកាលអាមាត្យហើយត្រាស់ឱ្យមហាកាលអាមាត្យជាមគ្គុទ្ទេសក៍ លើកពលចតុរង្គសេនាទៅកាន់សំណាក់ព្រះមហាទេ-

www.elibraryofcambodia.org

វត្ថេរៈ នមស្សការព្រះថេរៈហើយសួរថា បពិត្រលោកម្ចាស់ ខ្ញុំព្រះករុណាជ្រាបថា ព្រះនលាដធាតុរបស់ព្រះដ៏មានព្រះភាគរបស់យើងនៅនឹងលោកម្ចាស់ពិតមែនឬ ? ខ្ញុំព្រះករុណាមកនេះ ក៏ដើម្បីនិងអារាធនាព្រះធាតុនោះទៅ ។ ព្រះមហាទេវត្ថេរៈឆ្លើយតបថា បពិត្រមហារាជ ល្អហើយ ហើយនាំព្រះនលាដធាតុចេញមកឱ្យទតព្រះនេត្រឃើញ ។ ព្រះរាជាទ្រង់ទតព្រះនេត្រឃើញបាដិហារ្យរបស់ព្រះធាតុក៏មានព្រះហឫទ័យសោមនស្សរីករាយត្រាស់សូមព្រះធាតុនោះនឹងព្រះថេរៈ ។ ព្រះថេរៈថ្វាយព្រះពរថា បានមហាបពិត្រ កាលព្រះដ៏មានព្រះភាគទ្រង់គង់ព្រះធរមាននៅ បានត្រាស់ព្យាករណ៍ថា ព្រះរាជាមួយអង្គព្រះនាម កាកវណ្ណតិស្សៈ នឹងទ្រង់សាងស្តូបធំបញ្ចុះព្រះធាតុនេះទុកលើកពូលកពង់ឈ្មោះ វរភស្សៈ នៅទីបំផុតស្រះឈ្មោះសេរុ លើច្រាំងស្តាំនៃស្ទឹងមហាវាលុកគង្គាក្នុងកោះលង្កានេះ ហើយព្រះដ៏មានព្រះភាគទ្រង់ចូលនិរោធសមាបត្តិក្នុងទីនោះ ។ ព្រះរាជាព្រមដោយរាជបរិវារអារាធនាព្រះធាតុទៅកាន់ មហាគ្រាមដោយគ្រឿងសក្ការៈដ៏ធំ ហើយប្រោសឱ្យសាងមណ្ឌបប្រតិស្ឋានព្រះធាតុ ក្នុងទីមិនឆ្ងាយអំពី

www.elibraryofcambodia.org

រាជនិវេសន៍ ប្រតិស្ឋានប្រអប់កែវ(កោដ្ឋ)បញ្ចុះព្រះធាតុទុកក្នុងមណ្ឌប នោះ ។ ហើយទ្រង់សក្ការបូជាជានិច្ចជាកាលអស់កាលដ៏យូរ ក្នុងទីបំផុតព្រះរាជាត្រាស់បញ្ជាដល់លង្កាតិស្សៈព្រះរាជបុត្ររបស់ព្រះអង្គថា តិស្សៈអ្នកចូរបូជានូវព្រះធាតុដែលពូកយើងធ្លាប់បូជាមកហើយកុំខានតពីយើង ហើយព្រះអង្គត្រាស់ប្រវត្តិមកនៃព្រះធាតុប្រៀនប្រដៅរហូតសោយទីវង្គតបានទៅកើតក្នុងស្ថានសួគ៌ ។ កាលព្រះបាទមហានាគកន្លងទៅ កុមារលង្កាតិស្សៈបានសោយរាជ្យសម្បត្តិ ទ្រង់ធ្វើការគោរពព្រះធាតុដោយសក្ការបូជាយ៉ាងឱឡារិក ។ ក្នុងទីបំផុតព្រះអង្គបានប្រគល់ប្រអប់ព្រះធាតុទុកដល់កុមារគោធាភយៈ ជាព្រះរាជបុត្ររបស់ព្រះអង្គត្រាស់បញ្ជាឱ្យបូជាព្រះធាតុដូចពោលមកហើយ ហើយព្រះអង្គក៏សោយទីវង្គតទៅ ។ កាលព្រះបាទលង្កាតិស្សៈកន្លងទៅព្រះបាទគោធាភយៈគ្រងរាជ្យសម្បត្តិក៏ទ្រង់បដិបត្តិដូចគ្នា ក្នុងកាលជាទីបំផុតព្រះអង្គត្រាស់ណែនាំព្រះធាតុដល់កុមារកាកវណ្ណតិស្សៈព្រះរាជបុត្ររបស់ព្រះអង្គហើយបញ្ជាថា កាលបិតាសោយទីវង្គតហើយ បាចូរប្រតិស្ឋានព្រះធាតុនេះទុកក្នុងទីនោះ ហើយព្រះអង្គក៏សោយទីវង្គត

www.elibraryofcambodia.org

.៧៧. ព្រះឧបរាជមហានាគយាងទៅសូមព្រះធាតុពីព្រះថេរៈ

វត្ថេរៈ នមស្សការព្រះថេរៈហើយសួរថា បពិត្រលោកម្ចាស់ ខ្ញុំព្រះករុណាជ្រាបថា ព្រះនលាដធាតុរបស់ព្រះដ៏មានព្រះភាគរបស់យើងនៅនឹងលោកម្ចាស់ពិតមែនឬ ? ខ្ញុំព្រះករុណាមកនេះ ក៏ដើម្បីនិងអារាធនាព្រះធាតុនោះទៅ ។ ព្រះមហាទេវត្ថេរៈឆ្លើយតបថា បពិត្រមហារាជ ល្អហើយ ហើយនាំព្រះនលាដធាតុចេញមកឱ្យទតព្រះនេត្រឃើញ ។ ព្រះរាជាទ្រង់ទតព្រះនេត្រឃើញបាដិហារ្យរបស់ព្រះធាតុក៏មានព្រះហឫទ័យសោមនស្សរីករាយត្រាស់សូមព្រះធាតុនោះនឹងព្រះថេរៈ ។ ព្រះថេរៈថ្វាយព្រះពរថា បានមហាបពិត្រ កាលព្រះដ៏មានព្រះភាគទ្រង់គង់ព្រះជរមានទៅ បានត្រាស់ព្យាករណ៍ថា ព្រះរាជាមួយអង្គព្រះនាម កាកវណ្ណតិស្សៈ នឹងទ្រង់សាងស្តូបធំបញ្ចុះព្រះធាតុនេះទុកលើកពូលកពង់ឈ្មោះ វរភស្សៈ នៅទីបំផុតស្រះឈ្មោះសេរុ លើច្រាំងស្តាំនៃស្ទឹងមហាវាលុកគង្គាក្នុងកោះលង្កានេះ ហើយព្រះដ៏មានព្រះភាគទ្រង់ចូលនិរោធសមាបត្តិក្នុងទីនោះ ។ ព្រះរាជាព្រមដោយរាជបរិវារអារាធនាព្រះធាតុទៅកាន់ មហាគ្រាមដោយគ្រឿងសក្ការៈដ៏ធំ ហើយប្រោសឱ្យសាងមណ្ឌបប្រតិស្ឋានព្រះធាតុ ក្នុងទីមិនឆ្ងាយអំពី

www.elibraryofcambodia.org

រាជនិវេសន៍ ប្រតិស្ឋានប្រអប់កែវ(កោដ្ឋ)បញ្ចុះព្រះធាតុទុកក្នុងមណ្ឌប នោះ ។ ហើយទ្រង់សក្ការបូជាជានិច្ចជាកាលអស់កាលដ៏យូរ ក្នុងទីបំផុតព្រះរាជាត្រាស់បញ្ជាដល់លង្កាតិស្ស: ព្រះរាជបុត្ររបស់ព្រះអង្គថា តិស្ស: អ្នកចូរបូជានូវព្រះធាតុដែលពួកយើងធ្លាប់បូជាមកហើយកុំខានត ពីយើង ហើយព្រះអង្គត្រាស់ប្រវត្តិមកនៃព្រះធាតុប្រៀនប្រដៅរហូត សោយទិវង្គតបានទៅកើតក្នុងស្ថានសួគ៌ ។ កាលព្រះបាទមហានាគ កន្លងទៅ កុមារលង្កាតិស្ស:បានសោយរាជ្យសម្បត្តិ ទ្រង់ធ្វើការគោរព ព្រះធាតុដោយសក្ការបូជាយ៉ាងឱឡារិក ។ ក្នុងទីបំផុតព្រះអង្គបាន ប្រគល់ប្រអប់ព្រះធាតុទុកដល់កុមារគោធាភយ: ជាព្រះរាជបុត្ររបស់ ព្រះអង្គត្រាស់បញ្ជាឱ្យបូជាព្រះធាតុដូចពោលមកហើយ ហើយព្រះ អង្គក៏សោយទិវង្គតទៅ ។ កាលព្រះបាទលង្កាតិស្ស:កន្លងទៅព្រះ បាទគោធាភយ:គ្រងរាជ្យសម្បត្តិក៏ទ្រង់បដិបត្តិដូចគ្នា ក្នុងកាលជាទីបំផុតព្រះអង្គត្រាស់ណែនាំព្រះធាតុដល់កុមារកាកវណ្ណតិស្ស: ព្រះរាជបុត្ររបស់ព្រះអង្គហើយបញ្ជាថា កាលបិតាសោយទិវង្គតហើយ បាចូរ ប្រតិស្ឋានព្រះធាតុនេះទុកក្នុងទីនោះ ហើយព្រះអង្គក៏សោយទិវង្គត

www.elibraryofcambodia.org

ទៅ ។ កាលព្រះបាទគោធាភយៈកន្លងទៅ ព្រះបាទកាកវណ្ណតិស្សៈក៏បានឡើងសោយរាជ្យ ។ កាលទ្រង់សោយរាជ្យសម្បត្តិអស់កាលយូរអង្វែងពេលជិតអស់ជន្មាយុ ព្រះចូឡបិណ្ឌបាតតិស្សត្ថេរៈជាព្រះភាតារបស់ព្រះនាងវិហារទេវី ព្រះថេរៈពិចារណាមើលអាយុសង្ខាររបស់ព្រះកាកវណ្ណតិស្សៈជ្រាបថា អាយុសង្ខាររបស់ព្រះបាទកាកវណ្ណតិស្សៈនៅសល់បន្តិចទៀតទេ ។ លុះព្រឹកឡើងទៅប្រាប់ដល់ព្រះរាជាថា មហាបពិត្រកាលព្រះសាស្តាគង់ព្រះធរមាននៅត្រាស់ព្យាករណ៍ដូច្នេះថា ព្រះនលាដធាតុនេះមហាបពិត្រជាអ្នកនឹងរក្សា នឹងប្រតិស្ឋានទូវព្រះធាតុនេះទុកលើថ្មុកទឹកឈ្មោះ វរភស្ស នៅទីបំផុតផ្នែកស្តាំនៃស្ទឹងនៃមហាវាលុកគង្គា (លង្កាទ្វីប) ព្រះដ៏មានព្រះភាគទ្រង់សំដៅដល់ព្រះមហាបពិត្រហើយព្រះអង្គទ្រង់ចូលសមាធិក្នុងទីនោះ ឥឡូវនេះ មហាពិត្រ គួររលឹកដល់ពុទ្ធព្យាករណ៍ ។ តាមពិតព្រះបាទកាកវណ្ណតិស្សៈសូម្បីរលឹកដល់ដែលព្រះបិតារបស់ព្រះអង្គត្រាស់លើព្រះទែនមរណៈតែទ្រង់មិនដាក់ព្រះទ័យការប្រតិស្ឋានព្រះធាតុ គ្រាបានឮពាក្យព្រះថេរៈក៏ទ្រង់រលឹកដល់ពាក្យបិតាត្រាស់បញ្ជាទុក ទើបទ្រង់ទទួលពាក្យព្រះ

www.elibraryofcambodia.org

ថេរៈថា សាធុ លោកម្ចាស់ ។ តាមពិតព្រះបាទកាកវណ្ណតិស្សៈនោះ ទ្រង់ធំជាងក្សត្រទាំង ៣ ព្រះអង្គគឺព្រះបាទសិវៈនៃនគរសេរុ ព្រះបាទមហានាគនៃនគរសោណៈ ព្រះបាទគិរិអភយៈនៃនគរសោមៈ ។ កាលព្រះអង្គនឹងប្រតិស្ឋានព្រះធាតុទើបប្រជុំក្សត្រទាំង ៣ នោះ លុះដល់ថ្ងៃពេញបូណ៌មីខែវិសាខ ព្រះច័ន្ទប្រកបដោយវិសាខឫក្ស ទើបទ្រង់ដាក់ឥដ្ឋមង្គលឫក្ស នឹងកាលបន្ទប់ព្រះធាតុប្រតិស្ឋានព្រះធាតុសាងស្រេចហើយ ព្រះបាទកាកវណ្ណតិស្សៈទើបប្រឹក្សាជាមួយព្រះថេរៈថា ធាតុគព្ភគឺបន្ទប់ប្រតិស្ឋានព្រះធាតុបានសាងស្រេចហើយ ព្រឹកនេះបានឫក្សរោហិណី ខ្ញុំព្រះករុណានឹងបញ្ចុះព្រះធាតុ តើលោកម្ចាស់ជ្រាបរឿងព្រះកេសធាតុខ្លះទេ ? ទើបព្រះថេរៈត្រាស់ថា ប្រគល់នាទីនេះឱ្យព្រះចូឡបិណ្ឌបាតតិស្សត្ថេរៈ បន្តរកព្រះកេសធាតុតទៅ ។ ចំណែកព្រះថេរៈ បានបញ្ជាព្រះសិវត្ថេរៈ ដែលជាសទ្ធិវិហារិករបស់ខ្លួនឱ្យជ្រាបថា មាននាគរាជឈ្មោះថា ជយសេនៈ ប្រថាប់ក្នុងវិមានភូមិនទរនាគ ក៏ជយសេននាគរាជនោះ តែងបូជាព្រះកេសធាតុដែលតបុស្សៈនិងភល្លិកៈនាយឈ្មួញពីរនាក់បងប្អូន រក្សាទុកព្រឹកនេះអ្នកចូរទៅអារាធនាព្រះធាតុ

www.elibraryofcambodia.org

នោះមកថ្វាយព្រះមហាក្សត្រ ។ លុះព្រឹកឡើង ព្រះសិវត្ថេរៈនិមន្តទៅកាន់ភូមិនទរនាគពិភព អារាធនាព្រះកេសធាតុក្នុងសំណាក់ជយសេននាគរាជ មកថ្វាយដល់ព្រះបាទកាកវណ្ណតិស្សៈ ។ ព្រះចូឡបិណ្ឌបាត-តិស្សត្ថេរៈនិងព្រះមហាសាគលត្ថេរៈនិងព្រះមហិន្ទត្ថេរៈ ទាំងបីអង្គនេះគ្រប់៧ព្រះអង្គមានបរិវារច្រើនរយ ព្រមទាំងព្រះមហាក្សត្រ ៤ ព្រះអង្គមានព្រះបាទកាកវណ្ណតិស្សៈជាប្រធាន បានប្រតិស្ឋានព្រះនលាដធាតុរបស់ព្រះដ៏មានព្រះភាគក្នុងខាងលើស្ទឹងឈ្មោះវរភស្សៈ នៅក្នុងទីបំផុតស្រះឈ្មោះសេរុ ផ្នែកស្តាំស្ទឹងមហាវាលុកគង្គា គ្រាប្រតិស្ឋានស្រេចហើយ ។ ព្រះបាទកាកវណ្ណតិស្សៈប្រោសឱ្យសាងស្តូបធំការពារទឹកឬទ្រទ្រង់កំពូលភ្នំកៃលាស (គ្របពីលើ )និងព្រះអង្គទ្រង់ធ្វើកិច្ចដែលគួរធ្វើរួចហើយ ព្រះអង្គទ្រង់បូជារហូតមកដោយសំដែងពុទ្ធគារវៈជាអនេកប្បការរហូតមក ។

## រឿងមហិយង្គចេតិយ

កាលព្រះបាទកាកវណ្ណតិស្សៈសោយទីវង្គតទៅ ព្រះរាជបុត្រអង្គតូច (ពៅ) របស់ព្រះអង្គព្រះនាមថា តិស្សៈយាងមកពីទីឃវាបី

www.elibraryofcambodia.org

ទ្រង់ចាត់ចែងបូជាព្រះសពព្រះរាជបិតាស្រេចហើយ ទើបនាំព្រះមាតា (ព្រះនាងវិហារទេវី) ជាមួយដំរីឈ្មោះកុណ្ឌលៈទៅកាន់ទីឃវាបី ព្រោះខ្លាចព្រះជេដ្ឋា ។ ព្រះរាជកុមារទុដ្ឋគាមិនីអភ័យព្រះរាជបុត្រ ច្បងបានស្ដេចយាងទៅកាន់មលួយប្រទេស ខណៈកាលមានព្រះជន្ម ១៦ ឆ្នាំ ព្រោះខ្លាចព្រះបិតាចាប់ចង។ ខណៈនោះព្រះរាជកុមារទុដ្ឋគាមិនីអភ័យស្ដេចយាងពីមលួយជនបទមករាជាភិសេក ក្នុងស្រុកមហាគ្រាម។ ព្រះរាជកុមារទាំងពីរនាក់បងប្អូននោះ ឈ្លោះទាស់ទែងគ្នា ដោយសាររឿងដំរី កុណ្ឌលៈ ពេលនោះព្រះរាជកុមារតិស្សៈជាអនុជ ទ្រង់ឈ្នះមុនក្នុងពេលធ្វើយុទ្ធសង្គ្រាមត្រង់លានចុឡង្គណិមិដ្ឋិ ។ តែក្នុងគ្រាទី ២ ព្រះរាជកុមារអភ័យជាព្រះជេដ្ឋារួបរួមពលបាន ៦០០០០ ចេញច្បាំងបានឈ្នះ។ ខាងក្រោយមកព្រះថេរៈទាំងឡាយបានញ៉ាំងព្រះរាជកុមារទាំងពីរឱ្យរម្ងាប់ទោសគ្នាទៅវិញទៅមកថា ព្រះបាទអភយទុដ្ឋគាមិនីបញ្ចុះព្រះបរមធាតុទុកក្នុងលំពែង ឡោមព័ទ្ធដោយពលពាហនៈ ស្ដេចយាងទៅវត្តតិសារាម ទ្រង់នមស្សការព្រះសង្ឃហើយត្រាស់ថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណានឹងឆ្លងទៅកាន់ច្រាំងខាងនាយ

www.elibraryofcambodia.org

ដើម្បីនឹងញ៉ាំងព្រះសាសនាឱ្យរុងរឿង សូមលោកម្ចាស់មេត្តាអនុញ្ញាតឱ្យព្រះភិក្ខុទាំងឡាយទៅជាមួយខ្ញុំព្រះករុណា ដើម្បីបានជាស្រែបុណ្យរបស់ខ្ញុំ ។ ព្រះសង្ឃទើបអនុញ្ញាតឱ្យភិក្ខុ ៥០០ អង្គទៅជាមួយព្រះរាជា. ព្រះរាជានាំភិក្ខុសង្ឃទៅហើយ ឡើងប្រថាប់លើដីរីកុណ្ឌលដែលឡោមព័ទ្ធទៅដោយពលទាហានចំនួន ១០ កងពល ស្តេចចេញទៅកាន់សង្គ្រាម ដោយចតុរង្គពលសេនាស្តេចយាងទៅកាន់ទីលានមហិយង្គណៈ ញ៉ាំងទាហានរបស់ទ្រង់ឱ្យច្បាំងជាមួយពួកទមិឡ ពេលនោះទ្រង់ក៏បានទទួលជ័យជំនះ ហើយទ្រង់ឱ្យសាងកញ្ចុកស្តូប[១] ក្នុងទីលានមហិយង្គណៈនោះ ។ បានឮថា ព្រះដ៏មានព្រះភាគក្រោយអំពីបានត្រាស់ដឹងហើយបាន ៩ ខែ ព្រះអង្គបាននិមន្តមកកោះលង្កានេះទ្រង់ប្រថាប់ឈរនៅលើអាកាសចំខាងលើស្ថានទីមហិយង្គណៈស្តូបនោះក្នុងមហានាគវ័នឧទ្យាន ទៀបមាត់ច្រាំងស្ទឹងគង្គា (លង្កា) ព្រះអង្គទ្រង់បង្ក្រាបយក្សឱ្យអស់អំណាច ហើយព្រះអង្គទ្រង់ត្រឡប់ទៅវិញគ្រាព្រះសាស្តាបរិនិព្វានហើយ នៅមានព្រះថេរៈមួយអង្គព្រះនាមសរភូជាអន្តេវាសិករបស់ព្រះសារីបុត្តត្ថេរៈបានអារាធនាព្រះសីវធាតុ (ព្រះ

១. កញ្ចុកស្តូប ស្តូបធ្វើស្រោបពីលើ គឺ ចេតិយរក្សាចេតិយទុកខាងក្នុង ។

www.elibraryofcambodia.org

ធាតុត្រង់ក) អំពីជើងថ្ករ ហើយមានព្រះភិក្ខុសង្ឃជាច្រើនមកជាមួយ បានប្រតិស្ឋានព្រះសីវធាតុទុកត្រង់ទីនេះ ហើយសាងស្តូបកំពស់ ១២ ហត្ថរក្សាទុកហើយនិមន្តត្រឡប់ទៅវិញ ។ ព្រះបាទចុឡាភយៈជាព្រះភាតារបស់ព្រះបាទទេវានម្បិយតិស្សៈ បានទ្រង់សាងបន្ថែមអង្គចេតិយឡើង ៣០ ហត្ថ ។ មកដល់ពេលនេះព្រះបាទទុដ្ឋគាមិនីអភ័យឱ្យគេសាងកញ្ចុកចេតិយ ៨០ ហត្ថ បន្ថែមពីលើទៀត ។

ចប់

**មហិយង្គណស្តូប**

## រឿងបរិច្ចចេតិយ

ចំណែកព្រះបាទទុដ្ឋគាមិនីអភ័យចាប់ខ្លួនឆត្តទមិឡ ត្រង់កន្លែងលានមហិយង្គណៈនោះបានហើយ ទើបចាប់រាជទមិឡទាំងឡាយ គឺរាជាអម្ពទមិឡ ចំណាយវេលា ៤ ខែទើបចាប់បាន, រាជាកច្ឆកាទមិឡ ចំណាយវេលា ៤ ខែទើបចាប់បាន, រាជាវិជិតនគរ ចំណាយ

www.elibraryofcambodia.org

វេលា ៤ ខែទើបចាប់បាន. រាជាមហេលទមិឡ ចំណាយ វេលា ៤ ខែទើបចាប់បាន. ព្រះរាជាទ្រង់ចំណាយវេលាដើម្បីចាប់រាជាទមិឡមួយអង្គ ៤ ខែ ។ ដោយលំដាប់អំពីនោះមកក៏ស្តេចទៅកាន់អនុរាធបុរី ត្រាស់បញ្ជាឱ្យទ័ពសម្រាកនៅត្រង់ឱកាសពិត ហើយទ្រង់បញ្ជាឱ្យជីកស្រះក្នុងទីនោះ ហើយព្រះអង្គទ្រង់ហែលទឹកលេងក្នុងខាងដើមខែជេស្ឋ ។ ហើយទ្រង់ត្រាស់បញ្ជាឱ្យសាងបជោតនគរនៅក្នុងទីនោះ។ ព្រះអង្គទ្រង់ប្រហារឯឡាររាជទមិឡ ព្រមទាំងទាហានទាំងឡាយ ហើយស្តេចទ្រង់យាងចូលកាន់ខាងក្នុងនគរ ។ ព្រះបាទទុដ្ឋគាមិនីអភ័យទ្រង់បានប្រហារទមិឡអស់ ៣២ ព្រះអង្គ ។ ហើយទ្រង់ឱ្យលើកស្វេតឆត្រឡើងជាឯករាជ្យតែមួយទូទាំងកោះលង្កា ។ កាលព្រះរាជពិធីឆត្តមង្គលកន្លងទៅហើយ ៧ ថ្ងៃ ព្រះរាជាបញ្ជាឱ្យគេកសាងមរិច្ចវត្តិវិហារព្រមទាំងចេតិយ ។ កសាងអស់រយៈពេល ៣ ឆ្នាំទើបសំរេច ។ កាលមរិច្ចវត្តិវិហារសំរេចហើយ ព្រះរាជាទ្រង់ធ្វើរាជពិធីឆ្លងដ៏ធំធេង ។

**ចប់ រឿងមរិច្ចចេតិយ**

www.elibraryofcambodia.org

## រឿងលោហប្រាសាទ

តអំពីនោះមក ព្រះបាទទុដ្ឋគាមិនីអភ័យ ទ្រង់ពិនិត្យមើល ក៏ទ្រង់ទតព្រះនេត្រឃើញអក្សរចារឹកក្នុងសុវណ្ណបដ្ដ ដាក់នៅក្នុងប្រអប់ក្នុងព្រះរាជវាំង ទើបរអានចារឹកនោះដែលមានន័យដូចេ្នះថា ៖

នៅក្នុងពេលជាអនាគត កន្លង ១៤០ ឆ្នាំទៅ ព្រះរាជបុត្ររបស់ព្រះបាទកាកវណ្ណតិស្សៈ ទ្រង់ព្រះនាមថា ព្រះបាទទុដ្ឋគាមិនីអភ័យនឹងបញ្ជាឱ្យធ្វើយ៉ាងនេះ ទើបទ្រង់ព្រះតម្រិះថា ខ្លួនយើងនេះដែលព្រះមហិន្ទត្ថេរៈជាអ្នកឃើញអំពីចំងាយ បានឃើញត្រឹមត្រូវហើយ ទ្រង់ព្រះសោមនស្សត្រេកអរយ៉ាងក្រៃលែង គ្រានោះព្រះអង្គទ្រង់ទតព្រះនេត្រឃើញរបៀបគូរទិព្វវិមាន ទើបបញ្ជាឱ្យសាងលោហប្រាសាទតាមរបៀបនោះគឺ ផ្នែកទទឹងនិងផ្នែកកំពស់ក្នុងម្ខាង ៗ ១០០ ហត្ថ មាន ៩ ជាន់ មាន ១.០០០ បន្ទប់ វត្ថុផ្សេង ៗ ដូចជា សីហបញ្ជរ (បង្អួច) សុទ្ធសឹងតែក្បូរក្បាចវិចិត្រយ៉ាងក្រៃលែង ហើយទ្រង់ក៏ស្រោចទឹកទក្ខិណោទកថ្វាយដល់ព្រះភិក្ខុសង្ឃ ។

www.elibraryofcambodia.org

រឿងដែលពោលមកនេះ មាននៅក្នុងគម្ពីរជាច្រើន ដូចជាគម្ពីរមហាវំសជាដើម សូម្បីក្នុងគណ្ឋិបទទាំង ៣ ក៏លោកពោលថា ព្រះបាទទេវានម្បិយតិស្សៈតែប៉ុណ្ណោះ ដែលជាអ្នកកសាងលោហប្រាសាទ តែតាមសេចក្តីពិតក្នុងសម័យព្រះបាទទេវានម្បិយតិស្សៈនោះ មិនមានលោហប្រាសាទឡើយ គឺ លោកបានប្រើពាក្យថា "នឹង" ដែលសំដៅដល់កាលជាអនាគត ។

ចប់ រឿងលោហប្រាសាទ

## រឿងសុវណ្ណមាលិកចេតិយ

សម័យថ្ងៃមួយ ព្រះបាទទុដ្ឋគាមិនីអភ័យ ស្តេចយាងទៅបូជាមហាពោធិហើយ កាលស្តេចចូលកាន់នគរទ្រង់ទតព្រះនេត្រឃើញសសរសិលា ដែលព្រះរាជឯយ្យកាពេលបានរាជាភិសេកហើយបាន ៦ ឆ្នាំ បញ្ជាឱ្យបោះបង្គោលទុកត្រង់ទីស្ថានស្តូបទើបទ្រង់រលឹកដល់ពាក្យរបស់ព្រះមហិន្ទត្ថេរៈ ទ្រង់ចាប់ផ្តើមតាក់តែងផ្ទៃដីដើម្បីកសាងព្រះមហាស្តូប នៅក្នុងថ្ងៃឧបោសថពេញបូណមី

www.elibraryofcambodia.org

ខែវិសាខ ព្រះច័ន្ទប្រកបដោយវិសាខឫក្ស គ្រាដល់ថ្ងៃឧបោសថពេញបូណ៌មីអាសាឍ ព្រះច័ន្ទសោយឧត្តរាសាឡ្ហឫក្ស ទើបទ្រង់ដាក់ឥដ្ឋមង្គលក្នុងអង្គចេតិយ ។ ព្រះរាជាទ្រង់ធ្វើកិច្ចដែលគួរធ្វើក្នុងបន្ទប់បញ្ចុះព្រះធាតុរួចស្រេចហើយ ទ្រង់នមស្សការព្រះភិក្ខុសង្ឃហើយ ទ្រង់ត្រាស់ប្រគល់កិច្ចការថា បពិត្រលោកម្ចាស់ដ៏ចំរើន កិច្ចការក្នុងបន្ទប់បញ្ចុះព្រះធាតុស្រេចរៀបរយហើយ ថ្ងៃស្អែកនេះជាឧបោសថពេញបូណ៌មីខែអាសាឍ ខ្ញុំព្រះករុណានឹងប្រតិស្ឋានបញ្ចុះព្រះធាតុ សូមលោកម្ចាស់ទទួលជ្រាបពីរឿងព្រះធាតុនេះផងចុះ ដូច្នេះ ។ ព្រះរាជាទ្រង់ប្រគល់នាទីនេះឱ្យដល់ភិក្ខុសង្ឃយ៉ាងនេះហើយ ស្ដេចយាងត្រឡប់ទៅកាន់នគរវិញ ។ ចំណែកព្រះសង្ឃបានប្រគល់ការងានោះ ឱ្យដល់សោណុត្តរសាមណេរដែលមានព្រះជន្ម ១៦ ឆ្នាំ ស្ថិតនៅក្នុងសំណាក់ធជបរិវេណយ៉ាងនេះថា សាមណេរសោណុត្តរៈ ថ្ងៃស្អែកនេះ នឹងមានការបញ្ចុះព្រះធាតុ កាលដែលព្រះសាស្ដាផ្ទំលើគ្រឡាបរិនិព្វានទ្រង់

www.elibraryofcambodia.org

ត្រាស់ហៅស្ដេចសក្កទេវរាជមកចូលគាល់ហើយត្រាស់ថា ៖ ធាតុរបស់តថាគតមានចំនួន ៨ ទោណ ក្នុងអនាគតកាលក្សត្រកោឡិយៈដង្ហែយកទៅបូជា ១ ទោណ តទៅខាងមុខព្រះធាតុទាំងនោះនឹងយកទៅប្រតិស្ឋាននៅក្នុងមហាចេតិយ ឯលង្កាទ្វីប ។ កាលដែលព្រះដ៏មានព្រះភាគទ្រង់បរិនិព្វានហើយ ក្សត្រកោឡិយៈបានបញ្ចុះព្រះបរមសារីរិកធាតុក្នុងចេតិយធំ ដែលធ្វើហើយក្នុងរាមគ្រាម វេលាចេតិយត្រូវខ្សែទឹកដ៏ធំហូរចោះ ប្រអប់ទុកព្រះបរមសារីរិកធាតុបានធ្លាក់ចុះទៅក្នុងសមុទ្រ មហាកាឡនាគរាជបាននាំព្រះបរមសារីរិកធាតុនោះ ទៅមញ្ជេរិកនាគពិភពរក្សាទុករហូតមកដល់សព្វថ្ងៃនេះ ព្រោះហេតុដូច្នោះ សាមណេរចូលទៅមញ្ជេរិកនាគពិភពបរិយាយរឿងនោះ ឱ្យនាគរាជបានជ្រាបហើយយកព្រះបរមសារីរិកធាតុមក សោណុត្តរសាមណេរទទួលពាក្យបញ្ជាហើយស្មែកឡើងទ្រង់ជ្រាបថា ព្រះមហាក្សត្រស្ដេចចេញមក ព្រោះបានឮតន្ត្រីប្រគុំគឹកកង ទើបចូលចតុត្ថជ្ឈាន

www.elibraryofcambodia.org

មានអភិញ្ញាជាបាទ មុជចុះទៅក្នុងផែនដីហើយផុសឡើងត្រង់មុខមហាកាឡនាគរាជក្នុងមញ្ជេរិកពិភព ហើយសាមណេរបាននាំយកព្រះបរមសារីរិកធាតុដែលមហាកាឡនាគថ្វាយមកប្រគល់ឱ្យដល់ព្រះបាទទុដ្ឋគាមិនីអភ័យ ចំណែកព្រះរាជាទើបទ្រង់ធ្វើការបញ្ចុះព្រះបរមសារីរិកធាតុ ក្នុងថ្ងៃពេញបូណ៌មី ខែអាសាឍព្រះច័ន្ទប្រកបដោយឧត្តរាសាឡឫក្ស គ្រាបញ្ចុះព្រះបរមសារីរិកធាតុរួចស្រេចហើយ ទើបព្រះរាជាទ្រង់បញ្ជាឱ្យសាងព្រះស្តូបឈ្មោះសុវណ្ណមាលិនី ដែលមានកំពស់ ១២០ ហត្ថ គ្រប់រក្សាពីលើព្រះសារីរិកធាតុនោះទុកទៀត ។ ព្រះបាទទុដ្ឋគាមិនីអភ័យទ្រង់បំពេញព្រះរាជមហាកុសលជាអនេក សោយរាជ្យសម្បត្តិបាន ២៤ ឆ្នាំ ទ្រង់ក៏បានប្រគល់សរីររាងកាយរបស់ព្រះអង្គថ្វាយចំពោះព្រះសង្ឃ ទ្រង់រំលឹកដល់បុណ្យកុសលជាដរាបមិនដែលដាច់ចុតិអំពីនោះទ្រង់បដិសន្ធិក្នុងទិព្វរថដែលមកអំពីតុសិតពិភព ទ្រង់មានប្រដាប់ដោយគ្រឿងអាភរណៈជាទិព្វ កាលមហាជនកំពុង

www.elibraryofcambodia.org

មើលទ្រង់បានធ្វើប្រទក្សិណមហាស្តូប ៣ ជុំ នមស្សការព្រះភិក្ខុ-សង្ឃហើយ ស្តេចក៏បានយាងទៅកាន់តុសិតពិភព ។ ចំណែកព្រះបាទកាកវណ្ណតិស្សៈ នឹងបានជាព្រះបិតារបស់ព្រះដ៏មានព្រះភាគមេត្តេយ្យ. ព្រះនាងវិហារទេវីនឹងបានជាព្រះពុទ្ធមាតា ។ ព្រះបាទទុដ្ឋគាមិនីអភ័យនេះនឹងបានជាបឋមសាវ័កគឺអគ្គសាវ័កទី ១ ។ ចំណែកព្រះបាទសទ្ធាតិស្សៈដែលជាព្រះរាជអនុជនឹងបានជាព្រះទុតិយសាវ័ក ទី ២ ព្រះនាងអនុឡាទេវីដែលជាព្រះបិតុច្ឆារបស់ព្រះបាទទុដ្ឋគាមិនីអភ័យ នឹងបានជាព្រះអគ្គមហេសីរបស់ព្រះមេត្តេយ្យ ។ សាលីរាជកុមារ ដែលជាព្រះរាជបុត្ររបស់ព្រះបាទទុដ្ឋគាមិនីអភ័យ នឹងបានជារាជបុត្ររបស់ព្រះមេត្តេយ្យ ឯនាយឃ្លាំងឈ្មោះ សង្ឃាមច្ចា នឹងបានជាកំពូលពុទ្ធបដ្ឋាក ។ ក៏ធីតារបស់តិស្សៈអាមាត្រនឹងបានជាកំពូលពុទ្ធបដ្ឋាយិកា ។ បានឮថា ជនទាំងឡាយនេះជាអ្នកសុទ្ធតែមានអធិការដែលបានធ្វើទុកហើយទាំងអស់គ្នាដោយប្រការដូច្នេះឯង ។

www.elibraryofcambodia.org

ចំណែកព្រះមេត្តេយ្យពោធិសត្វ ធ្លាប់បានទទួលការព្យាករណ៍ពីសំណាក់ព្រះពុទ្ធអង្គ បច្ចុប្បន្ននេះបានបំពេញបារមី ១៦ អសង្ខេយ្យ និងមួយសែនកប្បរួចមកហើយ ខណៈនេះកំពុងកើតនៅក្នុងតុសិតបុរី តទៅខាងមុខនឹងបានត្រាស់ជាព្រះពុទ្ធក្នុងលោកនេះដោយពិត លោកបានចងជាគាថាទុកដោយមានសេចក្តីថា ÷

ព្រះរាជាទុដ្ឋគាមិនីនេះ កសាងស្តូបសុវណ្ណមាលិនី
កំពស់ ១២០ ហត្ថ ហើយបូជាជាប់ជានិច្ច ព្រះ
វររាជអភ័យ (ទុដ្ឋគាមិនី) ជាស្តេចផែនដីតែមួយ
អង្គដែលប្រសើរក្រៃលែង នៅក្នុងកោះដ៏ប្រសើរ
(លង្កា) ទាំងអស់ ទ្រង់សន្សំបុណ្យបារមីដ៏ប្រសើរ
ទ្រង់គ្រប់គ្រងរាជ្យសម្បត្តិដ៏ប្រសើរ ២៤ ឆ្នាំ និង
ស្តេចទៅកាន់ស្ថានសួគ៌ទេវបុរៈដ៏ប្រសើរ ។

ចប់

**ការកសាងសុវណ្ណមាលិកចេតិយ**

www.elibraryofcambodia.org

## រឿងព្រះបរមសារីរិកធាតុក្នុងប្រទេសកម្ពុជា

ក្នុងប្រទេសកម្ពុជាយើងមិនសូវមានពោលដល់ការកសាងព្រះចេតិយតម្កល់ព្រះបរមសារីរិកធាតុទេ ព្រោះសម័យមុននោះខ្មែរយើងជាអ្នកចូលចិត្តនិយមកសាងប្រាសាទប្រាង្គ ដើម្បីឧទ្ទិសដល់ព្រះសិវៈឬព្រះពោធិសត្វអវលោកេស្វរៈ (ក្នុងព្រះពុទ្ធសាសនាមហាយាន) ។ ចំណែកប្រទេសជិតខាងយើងមានប្រទេសថៃ ភូមាជាដើមមានប្រវត្តិពោលដល់ការកសាងព្រះចេតិយនិងការតម្កល់ព្រះបរមសារីរិកធាតុ ដូចនៅភូមាមានព្រះចេតិយឈ្មោះសិង្គុត្តរចេតិយ ឬហៅថា ចេតិយស្វេតាគន តម្កល់ព្រះកេសធាតុនៃព្រះសម្ពុទ្ធ ។ ក្នុងប្រទេសថៃមានចេតិយតម្កល់ព្រះបរមសារីរិកធាតុ ដូចនៅលើជយសុទេព បាងឡាំពូនជាដើម (ក្នុងគម្ពីរជិនកាលមាលីបករណ៍) ។ តែទោះថានៅក្នុងប្រទេសខ្មែរយើងមិនមានព្រះចេតិយ តម្កល់ព្រះបរមសារីរិកធាតុ

www.elibraryofcambodia.org

ឱ្យយើងឃើញជាសក្ខីភាពដល់បច្ចុប្បន្នក៏ដោយ តែក៏មានប្រវត្តិខ្លះពីប្រភពប្រទេសចិននិងសិលាចារឹកថា ខ្មែរយើងក៏បានទទួលនូវព្រះបរមសារីរិកធាតុនឹងក៏បានតម្កល់ ក្នុងប្រទេសខ្មែរទៀតផងដូចខ្ញុំនឹងពោលខាងមុខនេះដូចតទៅ ÷

ព្រះបាទរុទ្រវរ្ម័ន(១) ទង់ឡើងសោយរាជ្យតសន្តតិវង្សព្រះវរបិតាមក ។ ប្រភពចិនពង្សាវតាររាជវង្សត្យ៊ីខាងត្បូងនិយាយតមកទៀតថា ព្រះបាទល្យើវ-តូ-ប៉ា-ម៉ូ គឺរុទ្រវរ្ម័ន ជាព្រះរាជបុត្រព្រះស្នំ មិនមែនជាអគ្គមហេសីទេ ទ្រង់ធ្វើឃាតមកុដរាជកុមារ (ប្រហែលជារាជកុមាគុណវរ្ម័នជាព្រះរាជបុត្រព្រះអគ្គមហេសីព្រះនាងកុលប្រភាវតី ?) ហើយឡើងសោយរាជ្យក្នុង គ.ស. ៥១៤ គឺឆ្នាំដែលព្រះវរ-បិតាទ្រង់ទីវង្គត ។ លុះបានឡើងសោយរាជ្យហើយក៏ទ្រង់បញ្ជូនរាជទូតទៅកាន់សំណាក់ ព្រះចៅក្រុងចិនច្រើនដង

1. P. Pelliot, Le Founan,

www.elibraryofcambodia.org

រាជទូតដែលទ្រង់បញ្ជូនក្នុង ព.ស. ១០៦២ (គ.ស. ៥១៩) បាននាំយកគ្រឿងបណ្ណាការព្រះអង្គគឺបដិមា[1] ព្រះនាងទេវី ? (Image heureuse) ធ្វើពីខ្លឹមចន្ទន៍ឥណ្ឌា ស្លឹកពោធិ៍ព្រឹកគជខ្យង គ្រឿងទេស គ្រឿងក្រអូបផ្សេង ៗ ច្រើនទៅថ្វាយព្រះចៅក្រុងចិន ។ រាជទូតដែលទ្រង់បញ្ជូនក្នុង ព.ស. ១០៨២ (គ.ស. ៥៣៩) បាននាំគ្រឿងបណ្ណាការព្រះអង្គគឺសត្វរមាសព្រមទាំងផលិតផលប្រទេសដទៃៗផ្សេង ។ រាជទូតនេះបានក្រាបទូលព្រះចៅក្រុងចិនថា នៅប្រទេសនគរភ្នំមានព្រះបរមសារីរិកធាតុ គឺព្រះកេសមួយសរសៃវែងប្រវែង ៣ ម៉ែត្រ ។ ទ្រង់ជ្រាបដំណឹងប្រសើរនេះហើយ ព្រះចៅក្រុងចិនបញ្ជូនភិក្ខុចេ-ឃុន-ប៉ាយ ឱ្យតាមរាជទូតខ្មែរមកដណ្តើមព្រះបរមសារីរិកធាតុនោះ យកបាត់រហូតឥឡូវនេះទៅ ។

1. P.Pelliot le Founan

www.elibraryofcambodia.org

ប្រភពចិននេះ មានសេចក្ដីឆ្លើយស្របនឹងសិលាចារឹកខ្មែរនៅប្រាសាទតាព្រហ្មទន្លេបាទីពីក្នុងពុទ្ធសតវត្សទី ១១ (គ្រិស្តសតវត្សទី ៦) ថា ព្រះបាទរុទ្រវរ្ម័នជាព្រះរាជបុត្រព្រះបាទកៅណ្ឌិន្យជយវរ្ម័ននេះ ទ្រង់កាន់ពុទ្ធសាសនាដែរ ហើយគោរពព្រះបរមសារីរិកធាតុនៃអង្គព្រះសម្មាសម្ពុទ្ធ ដូចមានសេចក្ដីក្នុងសីលាចារឹកនោះថា[១] ៖

ព្រះជិនស្រី ទ្រង់ឈ្នះនូវសឹកសត្រូវពោលគឺកិលេសព្រមទាំងវាសនា ទ្រង់ប្រកបដោយសម្បទាគ្រប់ប្រការ មានពោធិញ្ញាណឥតទើសទាល់សល់ជំពាក់អ្វីមួយឡើយ មានព្រះទ័យប្រកបដោយករុណាចំពោះសព្វសត្វ មានព្រះយសធំទូលំទូលាយ ឥតមានមោះមន្ទិលអ្វីឡើយ ។ ហើយផ្សាយទូទៅគ្រប់ទិសានុទិស ។ ព្រះអង្គស្រោចស្រង់សត្វដែលលិចលង់ក្នុងវាលវដ្តសង្សារគឺត្រៃភព ហើយបានដល់ត្រើយស្ថាន

1. G: cadés, BEFFO. XXXI, P. 8 et suiv .

និព្វានដ៏ឧត្តមឥតអ្វីប្រៀបបានឡើយ ។ ព្រះស្រីធាតុ (គឺព្រះបរមសារីរិកធាតុ) ព្រះអង្គដែលតែងតែផ្តល់ប្រយោជន៍ធំដល់សព្វសត្វទាំងឡាយ ក៏នៅតែផ្តល់ប្រយោជន៍ដល់សព្វសត្វលុះរហូតមកដល់ឥឡូវនេះ....... ។ អំពើជាព្រះរាជកុសលដែលទ្រង់ (ព្រះបាទរុទ្រវរ្ម័ន) បានបំពេញចំពោះព្រះធម៌ហើយ មិនមែនដើម្បីតែព្រះរាជករណីយកិច្ចប៉ុណ្ណោះទេ គឺ ទ្រង់បំពេញដើម្បីអនុគ្រោះដល់សត្វលោកទាំងមូលផង ។ ទ្រង់គោរពព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ... ទ្រង់បានតាំងព្រះអង្គពេញជាឧបាសកដែលឥតមានអំពើបាបលាមក... ។

សេចក្តីប៉ុណ្ណោះឱ្យយើងដឹងបានថា ក្នុងរជ្ជកាលព្រះបាទរុទ្រវរ្ម័ន យើងមានព្រះបរមសារីរិកធាតុ គឺព្រះកេសមួយសរសៃ សម្រាប់ជាទីសក្ការបូជា តែគួរឱ្យអនិច្ចា យើងត្រូវខាតបាត់បង់លែងបានគោរពទៅ ដោយព្រះចៅក្រុងចិន

www.elibraryofcambodia.org

(រាជវង្សត្បីខាងត្បូង) យកបាត់ទៅ ។

## ព្រះបរមសារីរិកធាតុ
## និងព្រះអរហន្តធាតុនៃព្រះសារីបុត្រនិងព្រះមោគ្គល្លាន
## មកស្ថិតនៅក្នុងប្រទេសកម្ពុជាអស់ ៧ ថ្ងៃ

ប្រជាជននៅកម្ពុជរដ្ឋ បានស្គាល់នូវពិធីបុណ្យមួយដ៏ឧឡារិកធំអស្ចារ្យជាបុណ្យដែលពុំធ្លាប់មានពីមុនៗ មកទាល់សោះ គឺពិធីបុណ្យដែលស្ថិតនៅក្នុងព្រះរាជធានីភ្នំពេញ ចំនួន ១ សប្តាហ៍ គឺពីថ្ងៃសៅរ៍ទី ១១ តុលា ឆ្នាំ ១៩៥២ ។ ពិធីបុណ្យនោះ មានរបៀបដូចពោលតទៅនេះ ÷

ទី ១ កាលពីថ្ងៃអាទិត្យ ២ រោច ខែ អស្សុជ ឆ្នាំរោង ចត្វាស័ក ព.ស. ២៤៩៥ ត្រូវនឹងថ្ងៃទី ៥ ខែតុលា គ.ស. ១៩៥២. ព្រះករុណាជាអង្គម្ចាស់ជីវិតតម្កល់លើត្បូង ព្រមទាំងព្រះរាជវង្សានុវង្ស នឹងទីប្រឹក្សាឯកជនអមព្រះអង្គ

www.elibraryofcambodia.org

សម្ដេចព្រះសង្ឃនាយកទាំង ២ គណៈ សម្ដេចឧត្ដម ប្រឹក្សា សមាជិករដ្ឋាភិបាល សមាជិករដ្ឋសភា សមាជិក ក្រុមប្រឹក្សា ព្រះរាជាណាចក្រ លោកកុម្មិស្ស៊ែរ និង លោក ឧត្ដមសិនី ព្រមទាំងនាម៉ឺនសព្វមុខមន្ត្រីគ្រប់ជំណែង បានស្ដេច យាងអញ្ជើញទៅស្ថានីយ៍អាកាសយានពោធិ៍ចិនតុង ដែល វិចិត្រដោយទង់ជាតិ និង ទង់សាសនាដើម្បីនឹងចាំទទួល ព្រះបរមសារីរិកធាតុ និង ព្រះអរហន្ដធាតុ ។ ចំណែកប្រ ជាជនទាំងគ្រហស្ថទាំងបព្វជិត ក្នុងក្រុងនិងខេត្តក្រៅ ក៏បាន ទៅជួបជុំកកកុញនៅពោធិ៍ចិនតុងដើម្បីដង្ហែ ព្រះសារីរិកធាតុ និង អរហន្ដធាតុ ។ មានរថយន្ដក្នុងក្រុង និង មកពីខេត្ត ផ្សេងៗ ជាងពីរពាន់ ដែលប្រដាប់ដោយភ្ញីផ្កាយ៉ាងក្រៃលែង បានទៅប្រច្រៀត រង់ចាំសំដែងគារវកិច្ចតាំងពីរម៉ោង ១ រសៀល ។

www.elibraryofcambodia.org

លុះដល់ម៉ោង ១៦ និង ៤៥ នាទី អាកាសយាន ដែលដង្ហែព្រះសារីរិកធាតុ និង ព្រះអរហន្តធាតុ បាន ប្រទក្សិណទីក្រុង ៣ ជុំ មុននឹងចុះមកកាន់ប្រថពី ។

ក្នុងពេលនោះ សង្កេតឃើញគណៈប្រតិភូ ដែលដង្ហែ ព្រះបរមធាតុមក ខាងផ្នែក ឥណ្ឌៀមាន ៩ រូបគឺ លោក ដុកទ័រស្យាមៈប្រាសាទម៉ូកែរ្ស៊ី(Syama Prasad mongerjé) ប្រធានមហាពោធិសមាគម អតីតរដ្ឋមន្ត្រីនៃប្រទេសឥណ្ឌៀ មានព្រះភិក្ខុ ន. ជិតរតនៈ (នាមដើមបែល-ឡុង) ជា អតីតចៅហ្វាយស្រុកនៃប្រទេសកម្ពុជា ហើយបួសនៅប្រ ទេសឥណ្ឌៀ ជាយូរឆ្នាំមកហើយ ព្រះភិក្ខុ ម. សង្ឃរតនៈ សាមណេរ ត. សរណង្ករ សាមណេរ សុលភទេវ ដុកទ័រឧត្តៈ. នាងកញ្ញា ម.ដុណ្ណារ នាងកញ្ញា មុនថារ៉ូ នាងកញ្ញា សាស្ត្រី ។

www.elibraryofcambodia.org

ឯគណៈប្រតិភូថៃ ដែលបានឡើងយន្តហោះដង្ហែពីក្រុងបាងកកមកតាមសេចក្តីអញ្ជើញនៃប្រទេសកម្ពុជា មានទាំងអស់ ៨ រូបគឺ ចៅឃុនចិត្តាករមុន. ចៅឃុនសោភណាគណារណ៍ ព្រះគ្រូសមុហ៍អនុវត្ត ព្រះមហាមូនកុត្តធនោ ព្រះយ៉ាភរតរាជសុពិជ ប្រធានពុទ្ធិកសមាគមនៃប្រទេសថៃ លោកស្រីភៀនដាំរ៉ុងធម្មសារ លោកឡឺសតិធម្មពិជា អុកស្រីនឿងអិមសម្បត្តិ ។

ក្រៅពីនេះមានគណៈប្រតិភូខ្មែរ ៣ រូប ដែលបានទៅដង្ហែព្រះបរមសារីរិកធាតុ និង ព្រះអរហន្តធាតុ តាំងពីក័លួកត្តាមកដែរ គឺព្រះគ្រូសង្ឃសត្ថា ប៉ុណ្ណ-សម្តាជ លោកតាន់-ជូហេង សមាជិកក្រុមប្រឹក្សា ព្រះរាជអាណាចក្រ និង លោក ក្រឹង-ទិល ។

ក្នុងពេលនោះ ក្រោយដែលមានការប្រគំភ្លេងជាតិរួច

www.elibraryofcambodia.org

ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដែលទ្រង់ព្រះពស្ត្រផាយ តាមប្រពៃណី បានទ្រង់ស្តេចទទួលព្រះបរមសារីរិកធាតុពី ដៃលោកប្រធានមហាពោធិសមាគម ដោយមានថ្វាយព្រះ ក្លស់ថ្វាយស័ង្ខជាព្រះកិត្តិយសផង សម្តេចក្រុមព្រះមុនីរ៉េត បានទ្រង់ទទួលព្រះអរហន្តធាតុនៃព្រះសារីបុត្រ និងព្រះធាតុ ព្រះមោគ្គល្លាន ពីលោកប្រធាននេះដែរ ហើយមានថ្វាយ ព្រះក្លស់ និង ស័ង្ខ ជាកិត្តិយសដូចមុន ។ បន្ទាប់ពី ការប្រគំស័ង្ខ នៃពួកបារគូ ៨ នាក់នោះមក ក៏មានភ្លេង មហោស្រពលាន់ឮយ៉ាងគឹកកង ជាមួយនឹងភ្លេងនៃក្រុម ទាហានដែលបន្លឺឡើងជាកិច្ច សំដែលសេចក្តីគោរពចំពោះ ព្រះបរមសារីរិកធាតុ ។

ស្រេចហើយ ព្រះរាជាក៏និមន្តព្រះសារីរិកធាតុដែល តម្កល់លើព្រះកោដ្ឋមាសយ៉ាងធំ ដែលមានដាំពេជ្រទាំង

www.elibraryofcambodia.org

គ្រាប់នៅខាងលើ ទៅតម្កល់លើបវរាសនៈ នៅមុខព្រះពន្លា ដែលមានការប្រដាប់តាក់តែងយ៉ាងប្រពៃ។ សម្តេចក្រុមព្រះមុនីរ៉េត នឹងសម្តេចព្រះមហាសុមេធាធិបតី ក៏និមន្តព្រះអរហន្តធាតុទទួលយកគ្រឿងសក្ការៈ ដែលនាំមកពីប្រទេសឥណ្ឌា ទៅតម្កល់លើបវរាសនៈនោះដែរ ។ មានកូនពោធិ៍ព្រឹក្ស ២ ដើមកំពស់ ១ ចំអាម បានត្រូវនាំមកជាមួយព្រះបរមសារីរិកធាតុនោះ ដើម្បីប្រតិស្ឋានទុកជាទីរលឹកដល់ថ្ងៃនក្ខត្តឫក្សនេះនៅប្រទេសយើង ។

លុះតម្កល់ព្រះបរមសារីរិកធាតុ លើបវរាសនៈរួចហើយ សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយក៏ថ្លែងសេចក្តីបួងសួងឥតព្រាងមួយ ដើម្បីជាកិច្ចអារាធនានិមន្តព្រះបរមសារីរិកធាតុតាមប្រពៃណី។ សម្តេចបានឆ្លៀតបួងសួងសុំឱ្យអសន្តិសុខទាំងឡាយ វិនាសបាត់បង់

www.elibraryofcambodia.org

ទៅដោយអានុភាពនៃព្រះបរមសារីរិកធាតុ និង ព្រះអរហន្តធាតុនេះ ។ គឺសេចក្តីបួងសួងនៃសម្តេចនេះហើយ ដែលគេឃើញមានសរសេរជាភាសាខ្មែរ និង ភាសាសំស្ក្រឹត នៅលើបដាផ្សេង ៗ នៃរថយន្តដង្ហែ ។ នៅទីបំផុតនៃសេចក្តីអារាធនារបស់សម្តេចនេះ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និង សម្តេចក្រុមព្រះមុនីរ៉េត ក៏ស្តេចនិមន្តព្រះបរមសារីរិកធាតុ និង ព្រះអរហន្តធាតុទៅតម្កល់លើបុស្បុករថយន្ត ដែលមានអាចារ្យជា បណ្ឌិត ៤ នាក់ ស្លៀកសំពត់ស ពាក់អាវផាយស ពាក់លំផក អង្គុយអមព្រះបរមធាតុ ។

លុះធ្វើកិច្ចគារវៈរួចហើយ ក្បួនរថយន្តដង្ហែ បានចេញពីចំណតពោធិ៍ចិនតុងនៅម៉ោង ៦ និង ១៨ នាទីល្ងាច ដោយមានរៀបតាក់តែងជាលំដាប់លំដោយដូច្នេះ

www.elibraryofcambodia.org

គឺនៅមុខក្បួន មានរថយន្តក្រសួងឃោសនាការ ដែលប្រដាប់ដោយភ្ញីផ្កា ជាសេចក្តីបួងសួងសុំឱ្យពិភពលោកបានសន្តិភាព ដោយសរសេរជាអក្សរក្លិង្គ ដើម្បីជាកិច្ចលើកដំកើនដល់ចំណង នៃមេត្រីភាពខាងសាសនា ដែលប្រទេសទាំងពីរនេះធ្លាប់មាននឹងគ្នា តាំងពីបុរាណកាលមកផង មានឧគ្ឃោសនស័ព្ទ នៃក្រុមនេះ បានបន្លឺនូវព្រះកិត្តិគុណ នៃព្រះសម្មាសម្ពុទ្ធនិងព្រះអគ្គសាវ័កទាំងគូ ដើម្បីក្រើនទឹកចិត្តប្រជាជនឱ្យមានសេចក្តីរីករាយស៊ូប្បូរចំពោះសាសនា ដែលជាមតិករបស់បុព្វបុរស បន្ទាប់មករថយន្តហ្ស៊ីបនាំមុខក្បួន វង់ភ្លេងឆៃយ៉ាំ រថយន្តហ្ស៊ីបផ្ទុកព្រះថេរៈ ៣ អង្គ ដោយគ្រឿងសក្ការៈ វង់ភ្លេងត្រៃ ព្រះរាជទ្រព្យ ដោយរថយន្តកាម៉្យុង ៣ រថយន្ត ១០ នៃបព្វជិត ទោចក្រយានយន្តទាហាន ៣ រថយន្តហ្ស៊ីបជំនួយព្រះរាជរថនៃព្រះបរមសារីរិកធាតុ ទោចក្រយាន

www.elibraryofcambodia.org

ទាហាន ៣ រថយន្តនៃសម្តេចព្រះសង្ឃនាយក គណៈ-មហានិកាយ រថយន្តនៃសម្តេចព្រះធម្មលិខិត ព្រះរាជទីនាំង រថយន្តនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះទីនាំរថយន្តនៃសម្តេចក្រុមព្រះមុនីរ៉េត និងព្រះទីនាំងរថយន្តសម្តេចព្រះវររាជជននីនាថ រថយន្តនៃគណៈប្រតិភូឥណ្ឌៀ រថយន្តនៃលោកកុម្ម៉ីស្សែរជីឡាវ៉េពុយព្លឹក រថយន្តលោកឧត្តមសេនីយ៍ដឺឡង់ក្លាដ រថយន្តប្រតិភូប្រទេសភូមា លង្កា- នេប៉ាល់-ចិន -ថៃ -លាវ-យួន-រថយន្តព្រះបរមរាជវាំង រថយន្តសមាជិករដ្ឋាភិបាល រថយន្តរដ្ឋាភិបាលខ្មែរ ដែលមានប្រដាប់ដោយគ្រឿងបូជា និង ភ្ញីផ្កាយ៉ាងប្រពៃ ។ រថយន្តនៃកងថ្មើរជើងអាណានិគម និងកងខេមរភូមិន្ទ រថយន្តពុទ្ធិកសមាគម រថយន្តសមាគមមិត្តសាលាបាលីកម្ពុជរដ្ឋ ដែលមានវិចិត្រដោយកង់ចក្រ ជាសញ្ញានៃសមាគម និងរថយន្តពួកពាណិជ

www.elibraryofcambodia.org

ផ្សេង ៗ ។ ដែលសុទ្ធតែប្រដាប់ដោយទង់ជាតិ និង ទង់សាសនា ហើយនិងអក្សរសំស្រ្កឹត ដែលនាំឱ្យប្រតិភូឥណ្ឌាមានសេចក្តីរីករាយ ចំពោះដែលប្រទេសកម្ពុជា បានជូនកិត្តិយសយ៉ាងខ្ពង់ខ្ពស់ ដល់ខ្លួនខាងផ្នែកអក្សរសាស្រ្តជាតិថែមទៀត ។

រថយន្តទាំងអស់ជាងពីរពាន់ បានដង្ហែបន្តគ្នាចេញពីស្ថានីយ៍អាកាសយានពោធិ៍ចិនតុង តាំងពីម៉ោង ៦ និង ១៨ នាទីរសៀល រហូតដល់ម៉ោង ១០ យប់ ដល់វត្តកែវមរកត ។ នៅពេលនោះគេបានសង្កេតឃើញ នៅតាមផ្លូវមានស៊ុំជ័យជាច្រើនកន្លែង ហើយមានព្រះសង្ឃរៀបគ្រឿងសក្ការៈតាមចញ្ចើមថ្នល់ គ្រប់វត្តដែលមានតាមផ្លូវ ។ ឧបាសកឧបាសិកានាំគ្នាអង្គុយនៅដី ហើយលើកដៃប្រណម្យសំពះបូជាគ្រឿងសក្ការៈគ្រប់តែទីតំបន់ ។

www.elibraryofcambodia.org

ក្បួនដង្ហែបានគោចរតាមផ្លូវកំពត វេវណេវិល មហាវិថីខ្ញុងជីឡាក្រេ វិថីប្រ៉ាង់ស៊ីកាញៀ តិរវិថីស៊ីសុវត្ថិ វិថីឧកញ៉ាឈុន និង វិថីព្រះបរមរាជវាំងហើយនិមន្តព្រះបរមធាតុ ចូលកាន់វត្តព្រះកែវមរកតតាមស៊ុំក្លោងទ្វារជ័យ ខាងកើត ដោយមានសម្តេចព្រះបរមរាជបិតា ទ្រង់ទទួលព្រះបរមសារីរិកធាតុ ព្រះអង្គក្រុមហ្លួងមុនីពង្សទីប្រឹក្សា ព្រះរាជរដ្ឋាភិបាលទ្រង់ទទួលព្រះអរហន្តធាតុពីលើរថយន្ត ទៅតម្កល់លើបវរាសនៈ ក្នុងព្រះវិហារកែវមរកត ដែលប្រដាប់ដោយគ្រឿងសក្ការៈមានតម្លៃយ៉ាងប្រពៃ ។

នៅម៉ោង ២១ និង ៣០ នាទី ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង បានទ្រង់ស្តេចយាងចេញពីព្រះបរមរាជវាំង មកកាន់វត្តព្រះកែវមរកត ដោយមានសមាជិករដ្ឋាភិបាល សមាជិកសភា ទាំងពីរ បានទៅក្រាបថ្វាយ

www.elibraryofcambodia.org

បង្គំគាល់ ។ ក្នុងពេលនោះ មានទាហានរក្សាព្រះអង្គ និង ក្រុមខេមរភូមិន្ទចាំធ្វើគារវកិច្ច ។

ព្រះមហាក្សត្រិយ៍ បានស្តេចយាងទៅប្រថាប់លើព្រះទីនាំងកៅអីនៅមុខព្រះវិហារថ្នាក់ក្រោម ទ្រង់ព្រះសណ្តាប់សុន្ទរកថា នៃលោកប្រធានមហាពោធិសមាគម ដែលថ្លែងសេចក្តីរំលឹកអំពីមេត្រីភាពខាងផ្លូវសាសនា ដែលប្រទេសទាំងពីរនេះធ្លាប់មានទឹងគ្នាពីអតីតកាល ។ ហើយព្រះមហាក្សត្រ ក៏ទ្រង់ត្រាស់តបវិញ ដោយបញ្ជាក់អំពីសេចក្តីស្មោះសនៃប្រជាជនខ្មែរ ដែលមានយ៉ាងមាំមួនចំពោះព្រះពុទ្ធសាសនា ។

លុះចប់សុន្ទរកថានេះហើយ ព្រះមហាក្សត្រ ក៏ទ្រង់ស្តេចចូលទៅ នមស្សការព្រះបរមសារីរិកធាតុ ដោយមានឧកញ៉ាព្រះស្តេចចាងហ្វាង ក្រុមសង្ឃការីនាំនមស្សការ ។

www.elibraryofcambodia.org

ស្រេចហើយព្រះមហាក្សត្រ ក៏ទ្រង់ស្ដេចយាងទៅកាន់ព្រះរាជនិវេសន៍វិញ ។

នៅម៉ោង ២២ ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ស្ដេចព្រះបរមរាជជននីនាថ ស្ដេចព្រះបរមរាជបិតា និង ព្រះរាជវង្សានុវង្ស បានចូលធ្វើនមស្សការ បូជាចំពោះព្រះបរមសារីរិកធាតុ ហើយព្រះមហាក្សត្រ បានទ្រង់ទទួលកិត្តិយស ក្នុងការបង្ហាញព្រះបរមធាតុ ដល់ព្រះរាជវង្សានុវង្សទាំងឡាយផង ។

ក្នុងចំណោមកិច្ចបូជា ដែលមានសារៈសំខាន់នាំឱ្យប្រតិភូប្រទេសទាំងឡាយ ។ ចាប់អារម្មណ៍ជាទីបំផុតនោះគឺពិធីពុទ្ធាភិសេកយ៉ាងខ្លីមួយ ដែលមានក្រុមភ្លេងព្រះរាជទ្រព្យសំដែងរឿងសម័យមានវិជ័យ ក្រោមការណែនាំនៃសម្ដេចព្រះបរមជននីនាថ ។

www.elibraryofcambodia.org

## របៀបដង្ហែប្រទក្សិណក្រុងភ្នំពេញ

ទី២- ថ្ងៃ ច័ន្ទ ៣ រោច ខែ អស្សុជ គឺថ្ងៃទី ៦ ខែ តុលា ឆ្នាំ ១៩៥២ ម៉ោង ៨ ព្រឹក សម្តេចសង្ឃនាយក ទាំង ២ ព្រះអង្គ និមន្តព្រះសារីរិកធាតុ និង ព្រះអរហន្ត-ធាតុ ពីក្នុងព្រះវិហារព្រះកែវមរកត យកទៅតម្កល់លើព្រះរាជយានម៉ាត (ព្រះរាជយានមាស) ដែលតម្កល់លើរថយន្ត ចេញក្បួនហែព្រះសារីរិកធាតុ និង ព្រះអរហន្តធាតុដោយក្បួនជាឱឡារិក មានភ្លេងតូរ្យតន្ត្រីព្រះរាជទ្រព្យ និង ភ្លេងជាតិនានា ទាហានក្រុមរក្សាព្រះអង្គ រថយន្តដែលរចនាផ្សេង ៗ របស់ក្រសួងរាជការទាំងឡាយ និង ក្រុមសមាគមព្រះសង្ឃ ហើយនិងទង់ ១ មានប្រវែង ៤០ ម៉ែត្រ ព្រមទាំងជនានុជនខ្មែរ ចិន យួន ជាពុទ្ធបរិស័ទ ដើរតាមហែ ណែនណាន់តាន់តាប់ជាអនេកជាមួយផង ហែតាមវិថីព្រះ

www.elibraryofcambodia.org

បរមរាជវាំង វិថីឱកញ៉ាឈុន វិថីបទុមវតី (ឈប់ ៣ នាទី នៅមុខវត្តបទុមវតី) ធ្វើនមស្សការរួចហែទៅតាមវិថីឡេង ស៊ីសុវត្ថិ មហាវិថីខ្ទង់ដាជីឡាក្រេ រុក្ខវិថីវេវដង់ (ឈប់៣ នាទី នៅវត្តលង្កា) ធ្វើនមស្សការ ហើយហែទៅតាមមហាវិថីព្រៀ បាស្តឺយ៉េរ ដល់មុខស្ថានីយ៍អយស្ម័យាន ឈប់នៅទីនោះ ព្រះរាជដំណាងព្រះករុណាពីររូប និមន្តព្រះសារីរិកធាតុ និង ព្រះអរហន្តធាតុ ពីលើរថយន្តទៅតម្កល់លើបរិវាសនៈ នា វេទិកា ដែលរចនាដោយទង់ជាតិ និង ទង់សាសនា ហើយ ធ្វើពិធីសម្ពោធតាមរបៀបដូចខាងក្រោម ។

ប្រធាននៃមហាពោធិសមាគម ពុទ្ធិកសមាគមកម្ពុជ-រដ្ឋ និងប្រតិភូនៃនានាប្រទេស បានថ្លែងសុន្ទរកថារៀងរាល់ខ្លួន ឆ្លើយឆ្លងគ្នាទៅវិញទៅមក ។ រួចសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក គណៈមហានិកាយ ប្រកាស

www.elibraryofcambodia.org

សេចក្តីឱ្យពុទ្ធបរិស័ទថាតាម មានទំនងដូចជាវេរសក្ការៈ បូជា នៅទីបំផុតពុទ្ធបរិស័ទបន្លឺសាធុការ ៣ ដងឮខ្លាំង ៗ ។

លុះរួចវិធីសម្ពោធដូចខាងលើនេះហើយ ទើបដង្ហែព្រះសារីរិកធាតុនិង ព្រះអរហន្តធាតុ ត្រឡប់មកកាន់វត្តព្រះកែវមរកតវិញ តាមវុត្ថិវិថីជីវរណ៍វិល តិវិថីឡាក្រង់យ៉េរ តិវិថីនរោត្តម វិថីព្រះបរមរាជវាំង (ឈប់ ៣ នាទី នៅមុខវត្តឧណ្ណាលោម) ក្បួនហែមកដល់វត្តព្រះកែវមរកត សម្តេចព្រះធម្មលិខិត និង រាជាគណៈ ១ អង្គ ជាតំណាងសម្តេចព្រះសង្ឃនាយកគណៈធម្មយុត្តិទទួលនិមន្តព្រះសារីរិកធាតុនិងព្រះអរហន្តធាតុ ពីលើរថយន្តទៅតម្កល់លើបុស្បុកធំ នៅទិសអគ្នេយ៍ព្រះកែវមរកត ។

មហាបុស្បុកនោះធ្វើពីឈើតាក់តែងរចនាដោយគ្រឿងរចនាដ៏វិចិត្រមានរំលេចពណ៌ផ្សេង ៗ ដោយពន្លឺ អគ្គិសនី

www.elibraryofcambodia.org

មានកំពូល ៧ ថ្នាក់ទ្រង់ទ្រាយជា ៤ ជ្រុងស្មើ ផ្ទៃខាងក្រោមក្រាលក្តារ មានរបៀងជុំវិញព័ទ្ធដោយព្រះរាជវ័តិ មានទ្វារ ៤ គ្រប់ទិសទាំង ៤ នៅមានទ្វារមានរោងតូបតម្កល់ហិប១សម្រាប់ទទួលបច្ច័យជាពុទ្ធបូជាអំពីពុទ្ធបរិស័ទ។

ចាប់តាំងពីពេលរសៀលក្នុងថ្ងៃទី ៦ និងក្នុងថ្ងៃទី ៧-៨-៩ និង ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៥២ បើកឱ្យប្រជាជន និង ព្រះភិក្ខុ-សាមណេរចូលក្នុងវត្តព្រះកែវមរកត ធ្វើសក្ការបូជា តាមពេលម៉ោងដូចមានខាងក្រោមនេះ ។

ពេលព្រឹក ពីម៉ោង ៧ ដល់ម៉ោង ៨ សម្រាប់ព្រះសង្ឃ ពីម៉ោង ៨ ដល់ម៉ោង ១២ សម្រាប់ប្រជាជន ។

ពេលរសៀល ពីម៉ោង ១៤ ដល់ម៉ោង ១៥ និង ៣០ នាទី សម្រាប់ព្រះសង្ឃ ពីម៉ោង ១៥ និង ៣០ នាទី ដល់ម៉ោង ២២ សម្រាប់ប្រជាជនជារៀងរាល់ថ្ងៃ ។

www.elibraryofcambodia.org

ក្នុងឱកាសទទួលព្រះបរមសារីរិកធាតុ គេសង្កេតឃើញថាប្រជាជនខ្មែរ ក្នុងក្រុង និង ខេត្តក្រៅ បានសម្ដែងសេចក្ដីស្មោះសចំពោះជំនឿជាកេរ្តិ៍ ដំណែលនៃដូនតាខ្លួន នាំគ្នាមកប្រជុំយ៉ាងណែនណាន់តាន់តាប់គ្រប់ផ្លូវ ស្ទើរតែរកកន្លែងបើកបរយានពុំបាន ហើយដោយគ្មានគេហស្ថាន និងទទួលឱ្យបានគ្រប់គ្រាន់ ប្រជាជនខ្លះក៏ស៊ូទទួលទានដំណេក និង វាលស្មៅតាមចិញ្ចើមផ្លូវ ឱ្យតែបានក្រាបថ្វាយបង្គំធ្វើសក្ការបូជាព្រះបរមធាតុ នៃព្រះសម្មាសម្ពុទ្ធ និង ព្រះអគ្គសាវ័កទាំងគូ ។ ពិធីនេះ បាននាំឱ្យក្រោមមេឃទាំងមូលឃើញច្បាស់ថា លទ្ធិដទៃពុំអាចនឹងទំលាយទំនប់យ៉ាងមាំគឺព្រះពុទ្ធសាសនា ដែលចាក់ឫសជាយូរអង្វែងណាស់មកហើយនោះទេ ។

www.elibraryofcambodia.org

## របៀបដង្ហែត្រឡប់ទៅវិញ

ទី ៣- ថ្ងៃ សៅរ៍ ៨ រោច ខែ អស្សុជ គឺថ្ងៃ ១១ ខែ តុលា ឆ្នាំ ១៩៥២ ម៉ោង ៧ ព្រឹក ព្រះករុណាអម្ចាស់ជីវិតលើត្បូង សម្ដេចព្រះសង្ឃនាយកទាំងពីរគណៈ និមន្តព្រះសារីរិកធាតុ និងព្រះអរហន្តធាតុ ទៅតម្កល់លើបុស្បុករថយន្តហើយដង្ហែចេញទៅកាន់ស្ថានីយ៍អាកាសយានពោធិ៍-ចិនតុងដោយក្បួនហែ ដូចកាលដង្ហែចូលមកក្នុងព្រះរាជធានីនោះដែរ ។

ម៉ោង ៨ ដល់ទៅស្ថានីយ៍អាកាសយាន លើកព្រះបរមធាតុទៅតម្កល់លើបរវាសនៈ ក្នុងព្រះពន្លាដដែល ។ សម្ដេចព្រះសង្ឃនាយកគណៈមហានិកាយ ថ្លែងសេចក្ដីគោរពថ្វាយព្រះពុទ្ធដំណើរ ពុទ្ធបរិស័ទបន្លឺសាធុការ ៣ ដងយ៉ាងខ្លាំងព្រមៗគ្នា ។ រួចហើយនិមន្តព្រះសារីរិកធាតុ

www.elibraryofcambodia.org

និង ព្រះអរហន្តធាតុឡើងទៅដម្កល់លើយន្តហោះ វេលាអាកាសយានហោះឡើងផុតពីប្រថពី ពុទ្ធបរិស័ទដែលមានព្រះករុណាជាប្រមុខបន្ទន់កាយគោរពព្រមៗគ្នា ។

លុះអាកាសយានហោះចេញផុត ទស្សនវិស័យហើយព្រះករុណាទ្រង់ស្តេចត្រឡប់មកព្រះរាជធានីវិញ ។

( ដកចេញពីកម្ពុជសុរិយា លេខ ២៤ ក្បាល ២ ឆ្នាំ ១៩៥២ ពីទំព័រ ៧៨៥-៧៨៦ )

## បុណ្យរាត់កណ្តាលសាសនា

ក្រោយមកប្រទេសកម្ពុជាយើង បានចាត់ចែងសម្ភោធពុទ្ធសាសនាយុកាលគម្រប់ ២៥០០ នៅក្នុងទីក្រុងភ្នំពេញជាបុណ្យធំអស្ចារ្យ សមតាមឆន្ទៈនិងជំនឿរបស់ពុទ្ធសាសនិកជននៅកម្ពុជរដ្ឋទាំងមូល ។ បុណ្យនេះជាបុណ្យផ្លូវការរបស់កម្ពុជរដ្ឋ, រាជរដ្ឋាភិបាលចាត់ចែងធ្វើក្នុងព្រះបរមរាជូបត្ថម្ភនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង.សម្តេចព្រះមហា

www.elibraryofcambodia.org

ក្សត្រិយានី, សម្ដេចព្រះឧបយុវរាជ និងសេចក្ដីទំនុកបំរុង នៃសម្ដេចសង្ឃនាយកទាំងពីរគណៈ ធ្វើអស់ចិរវេលា ៧ថ្ងៃ គឺតាំងផ្ដើមដំបូងនៅថ្ងៃ ១ ១៤ ៦ ឆ្នាំរកានព្វស័ក ពុទ្ធសករាជ ២៥០០ ត្រូវនឹងថ្ងៃទី ១២ ខែ ឧសភា គ្រិស្ដសករាជ ១៩៥៧ ដល់ថ្ងៃ ៧ ៥ ៦ ត្រូវនឹងថ្ងៃទី ១៨ ខែ ឆ្នាំ នឹងសករាជដដែល ជាថ្ងៃបង្ហើយបុណ្យ ។

បុណ្យនេះ ធ្វើជា ២ ផ្នែកគឺ ៖

១-បុណ្យ ព.ស. ២៥០០.

២-បុណ្យឆ្លងព្រះសក្យមុនីចេតិយបញ្ចុះព្រះបរមសារីរិកធាតុ ។

បុណ្យទាំងពីរផ្នែកនេះ ប្រជុំធ្វើនៅព្រះសក្យមុនីចេតិយ ត្រង់មុខស្ថានីយរាជអយស្ម័យយាន ក្រុងភ្នំពេញ ។

ព្រះចេតិយនេះដែលបានជានាមថា "ព្រះសក្យមុនី

www.elibraryofcambodia.org

ចេតិយ" ព្រោះជាព្រះចេតិយស្ថាបនាឡើងទុកជាទីរលឹកដល់ថ្ងៃដែលព្រះបរមសារីរិកធាតុនៃព្រះសម្ពុទ្ធ និងព្រះអរហន្ត-ធាតុនៃអគ្គសាវ័កទាំងគូ បាននិមន្តពីប្រទេសឥណ្ឌៀមកប្រថាប់នៅក្នុងរាជធានីភ្នំពេញ អស់វេលា ៧ ថ្ងៃ គឺ ពីថ្ងៃអាទិត្យទី ៥ ដល់ថ្ងៃសៅរ៍ទី ១១ ខែតុលា ព.ស. ២៤៩៥ គ.ស. ១៩៥២ ទើបបាននិមន្តយាងត្រឡប់ទៅប្រទេសឥណ្ឌៀវិញ ។ កាលទ្រង់និមន្តប្រថាប់ ៧ ថ្ងៃនោះ ពុទ្ធបរិស័ទនៅប្រទេសខ្មែរយើង ទាំងព្រះរាជា ទាំងប្រជារាស្ត្រទូទៅទាំងប្រទេសមានសេចក្តីជ្រះថ្លាមហិមាកក្រើករំពើក អស់ទាំងស្រុកតូចស្រុកធំនិគមជនបទនានា ។

តាមនៅក្នុងអារម្ភកថា របស់គណៈកម្មការរៀបចំពិធីបុណ្យពាក់កណ្តាលសាសនាបានបញ្ជាក់ថា ព្រះបរមសារីរិក-ធាតុបានទទួលមកពីប្រទេសឥណ្ឌៀនោះជាព្រះបរមសារីរិក-

www.elibraryofcambodia.org

ធាតុ ដែលខ្ចីមកហើយក៏សងត្រឡប់ឱ្យទៅប្រទេសឥណ្ឌៀវិញ ចុះព្រះបរមសារីរិកធាតុ ដែលតម្កល់នៅក្នុងព្រះសក្យ-មុនីចេតិយនោះបានមកពីណាវិញ ? តាមនៅក្នុងកម្ពុជ-សុរិយា ឆ្នាំ ទី ៣១ លេខ ៥ ខែ ឧសភា ព.ស. ២៥០២ គ.ស. ១៩៥៩ ត្រង់ទំព័រ៥៨៧-៥៨៨ ព្រះអាចារ្យ ចាប-ពិន លោកសរសេរទុកថា ៖

ក្នុង ព.ស. ២៤៩៩ គ.ស. ១៩៥៦ ប្រទេសកម្ពុជាបានសាងព្រះចេតិយ ១ នៅមុខស្ថានីយរាជាអយស្ម័យានក្រុងភ្នំពេញ ជាទីប្រតិស្ឋានព្រះបរមសារីរិកធាតុនៃព្រះសក្យមុនីសម្ពុទ្ធ ដែលសម្ដេចព្រះ **នរោត្តម សីហនុ** ទ្រង់បានមកពីប្រទេសសិរីលង្កា រាជការបានធ្វើបុណ្យឆ្លងព្រះចេតិយនេះជាមហោឡារិក ហៅថា "**បុណ្យ ព.ស. ២៥០០**" រួចហើយ ។

www.elibraryofcambodia.org

តាមពាក្យពោលរបស់អាចារ្យ ចាប-ពិន ដែលមានជីវិតរស់នៅក្នុងកំឡុងពេលនោះ ជាអ្នករៀបចំកម្មវិធីបុណ្យពាក់កណ្តាលសាសនានោះ ថាជាព្រះបរមសារីរិកាធាតុដែលបានមកពីប្រទេសសីរីលង្កាហើយក៏ធ្វើបុណ្យឆ្លងពាក់កណ្តាលសាសនា ព.ស. ២៥០០ តម្កល់ទុកក្នុងព្រះសក្យមុនីចេតិយក្រុងភ្នំពេញ ។

ខាងក្រោយមកឃើញថា ព្រះបរមសារីរិកធាតុដែលតម្កល់ នៅក្នុងព្រះសក្យមុនីចេតិយមុខស្ថានីរាជាយស្ម័យយានដូចជាមិនសមគួរ ទើបព្រះករុណាជាម្ចាស់ជីវិតតម្កល់លើត្បូងទ្រង់សព្វព្រះរាជហឫទ័យមានព្រះបំណងនឹងសាងព្រះសក្យ-មុនីចេតិយថ្មីលើភ្នំអដ្ឋរស្សឬភ្នំព្រះរាជទ្រព្យឡើងដោយរៀបចំគណៈកម្មការសាងសង់ឡើងមាន ៖

សម្តេច ជា ស៊ីម ប្រធាន ព្រឹទ្ធសភា

www.elibraryofcambodia.org

សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ព្រះប្រធានរដ្ឋសភា

សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី

ក/ អ្នកម៉ៅការសាងសង់ : ក្រុមហ៊ុន ខូច ជីលី អឹមតាតា

ខ/ ក្រុមរៀបចំបំពាក់ក្បាច់រចនា

១- អ្នកឧកញ៉ាចៅហ្វាវាំង គង់ សំអុល ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីព្រះបរមរាជាវាំង ប្រធានក្រុមបំពាក់ក្បាច់ និង ជាទីប្រឹក្សាបច្ចេកទេស

២- ឯកឧត្តម ជុំ ទឿន រដ្ឋលេខាធិការ ទទួលការងារអភិរក្សព្រះបរមរាជវាំង អនុប្រធាន

៣- លោក ស៊ុម សារ៉ៃ សាស្ត្រាចារ្យ នៃ មហាវិទ្យាល័យសិល្បៈសូនរូប ផ្នែកជាងទង សមាជិកទទួលការងារផ្នែកឆត្រូត

www.elibraryofcambodia.org

៤- លោក រី សារឿន សាស្ត្រាចារ្យ នៃ មហាវិទ្យាល័យសិល្បៈសូនរូប ផ្នែកចំលាក់ សមាជិកទទួលការងារផ្នែកតួអង្គរាង កណ្ដឹង

៥- លោក ឃួន ប៊ុនណា សាស្ត្រាចារ្យ នៃ មហាវិទ្យាល័យសិល្បៈសូនរូប ផ្នែកគំនូរចំលាក់ សមាជិកទទួលការងារផ្នែកបល្ល័ង្ក

៦- លោក ហ៊ី សាម៉ន សាស្ត្រាចារ្យ នៃ មហាវិទ្យាល័យសិល្បៈសូនរូប ផ្នែកគំនូរបុរាណ អនុប្រធាននាយកដ្ឋាន អភិរក្ស សមាជិកទទួលការងារ ផ្នែកឃឿន ក្បាច់ក្បាលសសរ និងលាបពណ៌

៧- លោក យូរ សំអ៊ែល សាស្ត្រាចារ្យ នៃ មហាវិទ្យាល័យសូនរូប ផ្នែកស្ថាបត្យកម្មបុរាណ ប្រធាននាយកដ្ឋាន អភិរក្ស សមាជិក ទទួលការងារ ផ្នែកក្បាច់ជើងទៀន

www.elibraryofcambodia.org

បង្កាន់ដៃ ចំលាក់រូបមូល ទ្វារក្បាច់ឈើ និង អភិរម្យទិស ។

កាលរៀបចំគណៈកម្មការរួចស្រេចហើយ សម្តេច ព្រះរាជអគ្គមហេសី មុនីនាថ សីហនុ ទ្រង់ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ព្រះអង្គយាងបញ្ចុះបឋមសិលាសាងសង់ ព្រះសក្យមុនីចេតិយនៅលើខ្នងភ្នំព្រះរាជទ្រព្យ (ភ្នំ ឧត្តុង្គ) នៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៩៩៦ ។

លុះមកដល់ថ្ងៃ ៩ កើត ខែ មិគសិរ ឆ្នាំ មមី ចត្វាស័ក ព.ស.២៥៤៦ ព្រះសង្ឃព្រមទាំងពុទ្ធបរិស័ទបាននាំគ្នាធ្វើសក្ការៈគោរពបូជាព្រះបរមសារីរិកធាតុអស់ ៧ យប់ ៧ ថ្ងៃ យ៉ាងមហោឡារិកគគ្រឹកគគ្រេងដើម្បីបញ្ជាក់ នូវភាពនៃខ្លួនជាពុទ្ធសាសនិកជនអ្នកជ្រះថ្លាក្នុងព្រះរតនត្រៃ ។ លុះដល់ព្រឹកឡើងត្រូវនឹងថ្ងៃ ១៥ កើត ខែ មិគសិរ ឆ្នាំ មមី ចត្វាស័ក ព.ស. ២៥៤៦ ត្រូវនឹងថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០២ បានដង្ហែ

www.elibraryofcambodia.org

ព្រះបរមសារីរិកធាតុពីសក្យមុនីចាស់ ឆ្ពោះទៅកាន់សក្យមុនីថ្មី ឯភ្នំព្រះរាជទ្រព្យឬភ្នំអដ្ឋរស្ស ដោយមាន ៖

-សម្តេចព្រះសុមេធាធិបតី នន្ទ ខឿ្យ សង្ឃរាជ គណៈមហានិកាយ

-សម្តេច ម៉ូ គ្រី សង្ឃរាជ គណៈធម្មយុត្តិក

-ព្រះថេរានុត្ថេរគ្រប់ព្រះអង្គ ទូទាំងព្រះរាជាណាចក្រកម្ពុជា

- សម្តេចព្រះ នរោត្តម សីហនុ ព្រមទាំងអគ្គមហេសី
- សម្តេច ហ៊ុន សែន ព្រមទាំងលោកជំទាវ
- សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ និងព្រះជាយា
- សម្តេច ជា ស៊ីម ព្រមទាំងលោកជំទាវ
- នឹងឯកឧត្តម លោកជំទាវ ជាច្រើនរូបទៀត

ក្បួនដង្ហែបានធ្វើដំណើរឆ្ពោះទៅ កាន់ភ្នំព្រះរាជទ្រព្យ

www.elibraryofcambodia.org

សន្និមេ ១ ក៏បានដល់ភ្នំព្រះរាជទ្រព្យ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ក៏ទ្រង់បានតម្កល់នូវព្រះបរមសារីរិកធាតុលើភ្នំព្រះរាជទ្រព្យចំពោះមុខពុទ្ធបរិស័ទ ដែលមកពីខេត្តនានាកុះករណែនណាន់តាន់តាប់មានមុខស្រស់បស់ញញឹមញញែមរកឧបមា មិនបានឡើយ ។ ព្រះបរមសារីរិកធាតុបានយកទៅតម្កល់ទុកនៅលើភ្នំព្រះរាជទ្រព្យ សម្រាប់ជាទីសក្ការៈគោរពបូជារបស់ពុទ្ធ-បរិស័ទ នៅថ្ងៃ ១៥ កើត ខែ មិគសិរ ឆ្នាំ មមី ចត្វាស័ក ព.ស. ២៥៤៦ ត្រូវនឹងថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០២ ។

ក្រោយពីធ្វើពិធីតម្កល់ព្រះបរមសារីរិកធាតុហើយ ពុទ្ធ-បរិស័ទមិនអស់ចិត្តឡើយ ក៏នៅធ្វើបុណ្យអស់ ៣ យប់ ៣ ថ្ងៃថែមទៀត នេះជាប្រវត្តិសាស្ត្រមួយនៃប្រទេសកម្ពុជាដែលបានធ្វើបុណ្យយ៉ាងឱឡារិកជាទីបំផុតក្នុងការបូជាព្រះបរមសារីរិក-ធាតុនៃព្រះភគវន្តសម្មាសម្ពុទ្ធជាអម្ចាស់ ។

www.elibraryofcambodia.org

ព្រះបរមសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធជាអម្ចាស់ មិនមែនមានតែនៅក្នុងព្រះសក្យមុទីលើភ្នំអដ្ឋរស្សតែម្យ៉ាងនោះទេ សូម្បីនៅក្នុងទីវត្តដទៃ ឬអាស្រមដទៃក៏បានទទួលចំណែកព្រះបរមសារីរិកធាតុខ្លះមកពីប្រទេសឥណ្ឌា ឬប្រទេសសិរីលង្កា តាមរយៈព្រះសង្ឃទៅសិក្សា នៅក្នុងប្រទេសឥណ្ឌាឬប្រទេសសិរីលង្កាតែម្តង ឬតាមរយៈលោកអ្នកមានស័ក្តិខ្ពង់ខ្ពស់បានទទួលមកហើយប្រគេនទៅតាមវត្តឬអាស្រមនោះៗ ។ តែទោះបីជាព្រះបរមសារីរិកធាតុមិនមែនជាផ្លូវការក្នុងប្រទេស ក៏ដោយក៏គួរយើងគោរពបូជាឱ្យបានយ៉ាងល្អ ឱ្យសមខ្លួនជាពុទ្ធ-សាសនិកជនអ្នកស្រលាញ់ព្រះពុទ្ធសាសនា ។

**ពោលពីព្រះបរមសារីរិកធាតុក្នុង**

**ព្រះរាជាណាចក្រ កម្ពុជា**

**ចប់ដោយសង្ខេប**

www.elibraryofcambodia.org

## ពណ៌នាព្រះបរមសារីរិកធាតុចំណែកផ្សេងទៀត

យើងបានដឹងមកហើយថា ព្រះបរមសារីរិកធាតុនៃព្រះ ដ៏មានព្រះភាគនោះ មិនបែកចេញមាន ៧ចំណែក គឺព្រះចង្កូម កែវ ៤ ឆ្អឹងដងកាំបិត ២ និង ឆ្អឹងថ្ងាស ១ ទៀត ត្រូវជា ៧ គត់ ចុះព្រះធាតុទាំងនោះនៅទីណាខ្លះ ? សំនួរនេះដូចជាស្មុកស្មាញ បន្តិចតែយើងពិចារណាមើល ក្រែងជួបគ្រឿងសាធកៈខ្លះគ្រាន់ ពិចារណា ។

១.ព្រះចង្កូមកែវស្តាំខាងលើស្ថិតនៅក្នុងស្ថានតាវត្តិង្ស

២.ព្រះចង្កូមកែវស្តាំខាងក្រោមស្ថិតនៅក្នុងប្រទេសសិ-រីលង្កា

៣.ព្រះចង្កូមកែវឆ្វេងខាងក្រោមស្ថិតនៅពិភពនាគ

៤.ព្រះចង្កូមកែវឆ្វេងខាងលើស្ថិតនៅក្នុងប្រទេសចិន ។

៥.ព្រះអក្ខកធាតុ ដងកាំបិតខាងស្តាំស្ថិតនៅក្នុងប្រទេស សិរីលង្កា ។

www.elibraryofcambodia.org

៦.ព្រះអក្ខកធាតុ ដងកាំបិតខាងឆ្វេងស្ថិតនៅក្នុងព្រហ្ម-
លោក ។

៧. ឧណ្ហីសធាតុ (ឆ្អឹងថ្ងាស) តម្រាខ្លះថា ស្ថិតនៅក្នុង
ប្រទេសសិរីលង្កា. ខ្លះថា ស្ថិតនៅក្នុងទុស្សចេតិយ
នាស្ថានព្រហ្មលោក ។

៨.ព្រះទន្តធាតុ ព្រះកេសធាតុ និងព្រះលោមធាតុ
ទេវតានាំទៅកាន់ចក្រវាឡនីមួយ ៗ ។

៩.ព្រះបរមសារីរិកធាតុចំនួន ១៦ នាឡិ ដែលព្រះ
អសោកបានជីកមកពីទីធាតុនិធាន បានផ្សព្វផ្សាយទូទាំងពិភព
លោករហូតបានចំណែកមកដល់ប្រទេសយើងខ្លះ ។

សួរថា តើប្រទេសចិនបានទទួលព្រះចង្កូមកែវឆ្វេងខាងលើពី
ណាដែរ ? តាមប្រភពមកក្នុងព្រះត្រៃបិដកបានបញ្ជាក់ថា ព្រះ
ចង្កូមកែវឆ្វេងខាងក្រោមធ្លាក់ទៅក្នុងដែនគន្ធាររដ្ឋ ដែលអ្នក
គន្ធាររដ្ឋតែងតែគោរពបូជា ។ នៅក្នុងដែនគន្ធាររដ្ឋសម័យមុន

www.elibraryofcambodia.org

ជាអ្នកកាន់ព្រះពុទ្ធសាសនាថេរវាទយ៉ាងមាំទាំ លុះមកដល់ខាងក្រោយក៏បានទទួលព្រះពុទ្ធសាសនាបែបមហាយានកាន់តែរុងរឿងខ្លាំងលើសថេរវាទទៀត ដោយមានការជួយឧបត្ថម្ភពីសំណាក់ព្រះបាទកនិស្កៈ ។ ក្នុងព.ស.៦២១-៦៤៨ ព្រះបាទកនិស្កៈនៃរាជវង្សកុសាណៈ ជាស្ដេចគ្រប់គ្រងដែនដីធំទូលំទូលាយភាគខាងជើង គឺ សិន្ធុ បញ្ជាប កស្មីរៈ និងអាហ្វកានិស្ថាន ទ្រង់តាំងរាជធានីនៅទីក្រុងបុរុសបុរៈ ទ្រង់កសាងវត្តអារាមនិងស្តូបជាច្រើនហើយព្រះអង្គឧបត្ថម្ភឱ្យធ្វើសង្គាយនាទី ៤ ខាងប៉ែកមហាយានឡើងនឹងទ្រង់កសាងព្រះស្តូបស្អាតវិចិត្រក្រៃលែងបញ្ចុះព្រះបរមសារីរិកធាតុក្នុងក្រុងបុរុសបុរៈ ។

កាល ព.ស.២៤៥២ អ្នកបោរាណគតិជីកជួបបុរាណវត្ថុក្នុងស្តូបបុរាណមួយត្រង់តំបន់សាហ៍សិកិ ទេហ៊ីរ៍ មានឆ្អឹងព្រះធាតុនៅក្នុងប្រអប់កែវ ៣ គ្រាប់ ក្នុងកោដ្ឋមាសមានអក្សរចារឹកជាអក្សរខរោសដ្ឋី ដែលប្រើក្នុងប្រទេសឥណ្ឌាខាងជើង

www.elibraryofcambodia.org

ក្នុងវេលានោះ មានអក្សរពីរបន្ទាត់ ថា (១) **អចរិយនំ សព្វស្តិនវាទិនំ ប្រតិគ្រហេ** និង (២)ថា **កនិស្កះ** ប្រែថា សូមឱ្យអាចារ្យសរវាសតិកវាទិនប្រោសទទួលយកនិងកនិស្កៈ ។ ត្រង់តួកោដ្ឋមាន ២ បន្ទាត់ថា (១)**ទេយធម្មោ សព្វសត្តវនំ ហិទ សុហរថំ ភវតុ** , និង (២) **ទស អគិសល នវកម្មិ កនិសកស វិហរេ មហាសេនស សង្ឃារាមេ** ប្រែថា សូមថ្វាយនេះ ចូរជាប្រយោជន៍ យ៉ាងល្អដល់សត្វទាំងពួងនិង មហាត្លេក(ទាស)ឈ្មោះ អគិសល ជាជាងកសាងរបស់ព្រះ បាទកនិស្កៈ នៅក្នុងសំណាក់សង្ឃជាសង្ឃារាមរបស់ព្រះមហា-សេនៈ ។

រដ្ឋបាលឥណ្ឌៀបានប្រគល់ព្រះធាតុនោះ ឱ្យប្រទេសភូមា រក្សាទុកក្នុងវត្តមួយ ក្នុងក្រុងមណ្ឌលេ ប្រទេសភូមារហូត ឥឡូវនេះ ។

www.elibraryofcambodia.org

កាល ព.ស.១០៦១ -១០៦៤ លោកចិន សុន-យុននិង លោកចិនហួយចេង បានធ្វើដំណើរទៅប្រទេសឥណ្ឌាហើយ សរសេរហេតុការណ៍ទុកថា បានទៅនមស្សការព្រះធាតុផ្សេងៗ គឺ ឧណ្ហិសធាតុ (ឆ្អឹងថ្ងាស) ដងកាំបិត ព្រះចង្កូមកែវ និងព្រះ កេសកេតុ ត្រង់ក្រុងបុរុសបុរៈនិងបានទៅមើលស្តូបលោរិន- យោត ដែលព្រះបាទកនិស្កៈទ្រង់សាងសង់ឡើង ។

ខ្ញុំបានស្រាវជ្រាវទៅឃើញថា ព្រះចង្កូមកែវដែលស្ថិត នៅក្នុងគន្ធាររដ្ឋនោះត្រូវធ្លាក់ទៅក្នុងខោតន (khotan) ប្រទេស ចិនបច្ចុប្បន្នស្ថិតនៅក្នុងហ្ស៊ិនជៀង(Counrty of xinjiang) ក្នុងរវាងសតវត្សរ៍ទី ៥ (គ.ស.៤២៤-៤៩៨,ព.ស.៩៦៧- ១០៣៧ មានព្រះភិក្ខុសង្ឃចិនខាងត្បូងនៃរាជវង្សជី (Qi dynasty)ព្រះនាមហ្វា-ហ្សៀន (Fa-xian)បានអារាធនាព្រះ ចង្កូមកែវទៅកាន់ខោតនហើយត្រឡប់ពីនោះទៅណានជីងដែលជា រាជធានី ជី (Qi capital) ។ តាមការបង្រួបបង្រួមប្រទេស

www.elibraryofcambodia.org

ចិនរាជវង្ស ស៊ូ (Sui) ព្រះចង្កូមកែវបានទៅកាន់ទីក្រុងថ្មី ឈាង-អាន ។ ហើយមានការផ្លាស់ប្តូរកន្លែងចុះឡើងតាមរាជ-វង្ស ។ រហូតព្រះចង្កូមកែវ (The buddha's Tooth-Relic) បានទៅស្ថិតនៅក្នុងវត្ត ហ្សៅ-ហ្សៀន (Zhao-xian Pagada) ឬឈ្មោះថា លិង-គួង (The Ling-guang Monastery) នៅក្នុងខេត្តប៉ីជីង (Beijing) ក្នុងខែ ៨ ឆ្នាំទី ៧ នៃហ្សៀង-យង (Xian-yong) (ប្រហែលឆ្នាំចិនទេដឹង?) ក្នុងគ.ស.១០៧១ ។ បច្ចុប្បន្ននេះព្រះចង្កូមកែវឆ្វេងខាងលើស្ថិតនៅក្នុងវត្តលិង-គួង ខេត្តប៉ីជីងប្រទេសចិន ដែលគេកសាងកោដ្ឋ មាស ១៥០ គ.ក. ដាំដោយពេជ្ររចនាវិចិត្រ ដោយក្បូរក្បាច់ផ្សេង ៗ តាមបែបប្រទេសចិនពីបុរាណ[១] ។

នៅក្នុងប្រទេសភូមាជាប្រទេសដែលបានទទួលព្រះធាតុមុនគេតាំងពីព្រះពុទ្ធព្រះអង្គគង់ព្រះជន្មមាននៅឡើយ ។ នៅក្នុងវិនយបិដក លេខ ៦ ទំព័រ ១១ បានពោលថា ៖

---

(១) (ដកស្រង់ចេញពីឯកសារប្រទេសចិនឈ្មោះ THE BUDDHA'S TOOTH-RELIC PAGODA) ជាឯកសារសរសេរជាភាសាចិន និងភាសាអង់គ្លេស

www.elibraryofcambodia.org

សម័យនោះឯង មានពាណិជពីរនាក់(ជាបងប្អូននឹងគ្នា) ឈ្មោះតបុស្សៈ ១ ភល្លិកៈ១ ជាអ្នកដើរផ្លូវឆ្ងាយ ចេញពីឧក្កលជនបទ សំដៅទៅកាន់ប្រទេសនោះ ។ តាមនៅក្នុងអដ្ឋកថាសមន្តប្បាសាទិកា ពាណិជពីរនាក់បងប្អូននេះ ចេញពីឧក្កលជនបទ ដើម្បីទៅលក់ដូរនៅក្នុងមជ្ឈិមប្រទេស ដែលជាប្រទេសព្រះអង្គគង់ប្រថាប់ ។ ខាងក្រោយមកគាត់ក៏បានយកសដូវផង់និងសដូវដុំ ចូលទៅថ្វាយព្រះដ៏មានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ហើយក៏ថ្វាយខ្លួនជាឧបាសកក្នុងសាសនានៃព្រះដ៏មានព្រះភាគ ។ នៅក្នុងគម្ពីរសមន្តប្បាសាទិកា ៣/១២ បញ្ជាក់ថា **តេ ឯវ ឧបាសកភាវំ បដិវេទេត្វា ភគវន្តំ អាហំសុ កស្សិទានិ ភន្តេ អម្ហេហិ អជ្ជ បដ្ឋាយ អភិវាទនប្បច្ចុប្បដ្ឋានំ កាតព្វន្តិ ។ អថ ភគវា សីសំ បរាមសតិ . កេសា ហត្ថេ លគ្គិំសុ ។ តេ តេសំ អទាសិ ឥមេ តុម្ហេ បរិហរថាតិ ។ តេ កេសធាតុយោ លភិត្វា អមតេនេវ អភិសិត្តា ហដ្ឋតុដ្ឋា ភគវន្តំ**

www.elibraryofcambodia.org

**វន្ទិត្វា បក្កមឹំសុ** ។ តបុស្សៈនិងភល្លិកៈនោះ កាលប្រកាសខ្លួនជាឧបាសកយ៉ាងនេះហើយ បានក្រាបទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន តាំងពីថ្ងៃនេះតទៅ ខ្ញុំព្រះអង្គគប្បីធ្វើអភិវាទនកម្មនិងបច្ចុប្បដ្ឋានកម្ម ចំពោះព្រះដ៏មានព្រះភាគដូចម្តេច ? ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ចាប់ព្រះកេសា ,ហើយព្រះកេសាក៏ជាប់នឹងព្រះហស្តព្រះដ៏មានព្រះភាគ ហើយព្រះអង្គទ្រង់ប្រទានព្រះកេសាទាំងនោះដល់នាយពាណិជទាំងពីរនាក់នោះ ហើយទ្រង់ត្រាស់ថា អ្នកចូររក្សានូវព្រះកេសធាតុនេះទុកចុះ ។ នាយពាណិជទាំងពីរនាក់នោះ បានទទួលព្រះកេសធាតុប្រហែលនឹងខ្លួនបានអភិសេកដោយអមតធម៌ មានចិត្តត្រេកអររីករាយ ថ្វាយបង្គំព្រះដ៏មានព្រះភាគចៀសចេញទៅ ។

តាមពង្សាវតារមន-ភូមាពោលថា នាយពាណិជតបុស្សៈនិងភល្លិកៈជាជនជាតិមន ស្ថិតនៅក្នុងក្រុងឧក្កលៈដែលជា

www.elibraryofcambodia.org

បឋមឧបាសកបានទទួលព្រះកេសធាតុ ព្រះកេសធាតុពីព្រះដ៏មានព្រះភាគជាព្រះបរមគ្រូទុកជាទីគោរពបូជា កាលដែលព្រះអង្គទើបទ្រង់ត្រាស់ដឹង ។ ហើយបានវិលត្រឡប់មកតាមសមុទ្រត្រូវនាគដណ្តើមយកបានខ្លះ តែក្រោយមកសាមណេរ-សោណុត្តរៈ បានទៅយកមកពីប្រភពនាគហើយយកមកតម្កល់ទុកក្នុងកោះលង្កាសព្វថ្ងៃ ។ ព្រះកេសធាតុនៅសល់ប៉ុន្មាននាយពាណិជក៏នាំយកទៅកសាងព្រះចេតិយឡើង ដែលមានឈ្មោះថា សិង្គុត្តរចេតិយក្នុងក្រុងឧក្កលៈប្រទេសមន សព្វថ្ងៃស្ថិតនៅក្នុងប្រទេសភូមា ដែលព្រះចេតិយនោះ ឥឡូវឈ្មោះថាស្វេតាគនចេតិយ ស្ថិតនៅក្នុងក្រុងយ៉ាងកុង ។

ព្រះកេសធាតុនេះហើយ ដែលខ្មែរយើងជាជិតខាងគ្នាជាមួយមនឬជាជាតិរួមគ្នាបានចំណែកព្រះកេសធាតុខ្លះ ដែលមានក្នុងសម័យព្រះបាទរុទ្រវរ្ម័ន ព.ស. ១០៥៧-១០៩៣ ដូចខ្ញុំពោលខាងដើមរួចហើយ ។

www.elibraryofcambodia.org

ចំណែកព្រះបរមសារីរិកធាតុ ក្នុងប្រទេសថៃវិញមានប្រភពមកជាច្រើន ដូចមានសំដែងនៅក្នុងគម្ពីរជិនកាលមាលីបករណ៍ សង្គីតិយវង្ស ចាមទេវី ជាដើម ហើយនៅក្នុងប្រទេសថៃនិយម កសាងព្រះចេតិយតម្កល់ព្រះបរមសារីរិកធាតុច្រើនកន្លែងដូចព្រះធាតុនៅបាងលាំភូន ឆៀងហៃ្ម ជាដើម ។ តែខ្ញុំមិនពណ៌នាព្រះធាតុទាំងនោះ នាំឱ្យវែងឆ្ងាយពេកនិងក្រាស់ក្នុងសៀវភៅនេះ ។

## ធាតុអន្តរធាន

នៅក្នុងបំផុតនៃព្រះពុទ្ធសាសនាតទៅខាងមុខ ព្រះបរមសារីរិកធាតុមានការអន្តរធានដូចនៅក្នុងគម្ពីរ (សុមង្គលវិលាសិនី ៣/៨៨ , សម្មោហវិនោទនី អដ្ឋ.វិភង្គ ២/៤៦៣ និងគម្ពីរសារត្ថទីបនីដីកា ១/២១៧ ) បានសំដែងថា ៖

www.elibraryofcambodia.org

មែនពិតបរិនិព្វានមាន ៣ យ៉ាងគឺ **កិលេសបរិនិព្វាន ១ ខន្ធបរិនិព្វាន ១ ធាតុបរិនិព្វាន ១** , ក៏បរិនិព្វានទាំងនោះ គប្បីជ្រាបទាក់ទងជាមួយព្រះដ៏មានព្រះភាគ របស់យើងយ៉ាងនេះ កិលេសបរិនិព្វានរបស់ព្រះដ៏មានព្រះភាគនោះ បានមានហើយត្រង់ពោធិបល្ល័ង្ក .ឯខន្ធបរិនិព្វានមានមកហើយក្នុងក្រុងកុសិនារា. ចំណែកធាតុបរិនិព្វាននឹងមានក្នុងអនាគត បានឮមកថា ក្នុងកាលព្រះសាសនាវិនាសចុះ ព្រះធាតុទាំងឡាយនៅក្នុងតាម្ពបណ្ណិទ្វីបនេះ នឹងនិមន្តទៅប្រជុំគ្នាត្រង់មហាចេតិយ (សុវណ្ណមាលិកចេតិយ ) បន្ទាប់មកទៅកាន់រាជាយតនចេ-តិយក្នុងនាគទ្វីប .បន្ទាប់ពីនោះ និមន្តទៅកាន់មហាពោធិបល្ល័ង្ក ព្រះធាតុទាំងឡាយដែលស្ថិតនៅក្នុងនាគពិភពក្តី ទេវលោកក្តី ព្រហ្មលោកក្តី ក៏និមន្តមកកាន់ពោធិបល្ល័ង្កដូចគ្នា ។ ព្រះធាតុសូម្បីប៉ុនគ្រាប់ស្ពៃ មិនបានវិនាសខូចបាត់បង់ទៅណាឡើយ (តាំងពីព្រះដ៏មានព្រះភាគទ្រង់បរិនិព្វាន រហូតព្រះធាតុអន្តរ-

www.elibraryofcambodia.org

ធាន ) ។ ព្រះធាតុមកជួបជុំគ្នាហើយក៏បង្កើតជាគំនរឡើងលើ មហាពោធិបល្ល័ង្កដូចជាដុំមាសមួយដុំហើយ ( **រាសិភូតា សុវ-វណ្ណក្ខន្ធោ វិយ ឯកគ្ឃនា ហុត្វា** ) បញ្ចេញឆព្វណ្ណរង្សីផ្សាយទៅមួយម៉ឺនលោកធាតុ លំដាប់នោះ ទេវតាទាំងឡាយមួយម៉ឺនចក្រវាឡក៏មកជួបជុំគ្នា ហើយធ្វើភារៈនៃករុណាដ៏ធំក្រៃលែងជាងថ្ងៃ ដែលព្រះទសពលបរិនិព្វានថា ថ្ងៃនេះព្រះសាស្តានឹងទ្រង់បរិនិព្វាន ថ្ងៃនេះព្រះសាស្តានឹងវិនាស នេះជាការឃើញជាទីចុងបំផុតរបស់ពួកយើងហើយ ។ វៀរតែទេវតាជាអនាគាមី និងព្រះខីណាស្រពចេញ ទេវតាដ៏សេសមិនអាចទ្រទ្រង់នូវភារៈនៃខ្លួនបានឡើយ ។ ពេលនោះតេជោធាតុក៏តាំងឡើងក្នុងព្រះធាតុទាំងឡាយ ឆេះឡើងទៅរហូតដល់ព្រហ្មលោក. កាលព្រះធាតុសូម្បីត្រឹមប៉ុនគ្រាប់ស្ពៃនៅមាន ព្រះធាតុឈ្មោះថានៅមាន តែកាលណាភ្លើងឆេះនោះឯង ព្រះធាតុទាំងឡាយដល់នូវការវិនាសអស់ ភ្លើងក៏ឈប់ឆេះព្រះធាតុ ឈ្មោះថា **អន្តរធាន** ។

www.elibraryofcambodia.org

កាលដែលព្រះធាតុ សំដែងអានុភាពធំយ៉ាងនេះ ព្រះសាសនាទើបឈ្មោះថា អន្តរធាន ពីលោកយើងនេះ ។

ចំណែកនៅក្នុងគម្ពីរ (មនោរថបូរណី អដ្ឋ.អង្គុត្ត.ឯកនិបាត ១/៨២ , មោហវិច្ឆេទនី ទំព័រ ៣៤០ , សារត្ថសង្គហៈ ត្រង់បញ្ហានន្តរកថា ទំព័រ ៨៧ សំដែងថា ៖

ឈ្មោះថា អន្តរធាននៃព្រះធាតុគប្បីជ្រាបដូច្នេះ ៖ បរិនិព្វាន មាន ៣ យ៉ាង គឺ **កិលេសបរិនិព្វាន** ការបរិនិព្វាននៃកិលេស , **ខន្ធបរិនិព្វាន** ការបរិនិព្វាននៃខន្ធ , **ធាតុបរិនិព្វាន** ការបរិនិព្វាននៃព្រះធាតុ ។ បណ្តាបរិនិព្វាន ៣ យ៉ាងនោះ កិលេសបរិនិព្វាន បានមានហើយត្រង់ពោធិបល្ល័ង្ក ។ ខន្ធបរិនិព្វាន បានមានហើយត្រង់កុសិនារា , ធាតុបរិនិព្វាននឹងមានក្នុងអនាគត ។ តើព្រះធាតុបរិនិព្វាននោះមានមកយ៉ាងណា? គឺថា កាលព្រះធាតុមិនបានទទួលសក្ការៈនិង សេចក្តីគោរពកោតក្រែងក្នុង

www.elibraryofcambodia.org

ទីនោះ ៗ ក៏ទៅកាន់ទីដែលមានសក្ការៈ និងសេចក្ដីគោរពកោតក្រែង ដោយកម្លាំងអធិដ្ឋានរបស់ព្រះដ៏មានភាគ ។ កាលកន្លងទៅសក្ការៈ និង សេចក្ដីគោរពកោតក្រែងមិនមានក្នុងទីទាំងពួង។ វេលាព្រះសាសនាវិនាសខ្សោយចុះ ព្រះធាតុទាំងឡាយក្នុងតាម្ពបណ្ណិទ្វីបនេះ នឹងនិមន្តមកប្រជុំគ្នាហើយ ស្ដេចយាងទៅកាន់មហាចេតិយ ចេញពីមហាចេតិយ ទៅកាន់នាគទ្វីប បន្ទាប់ពីនោះទៅកាន់ពោធិបល្ល័ង្ក ។ ព្រះធាតុទាំងឡាយក៏មកពីនាគពិភព អំពីទេវលោក និងអំពីព្រហ្មលោកមកកាន់ពោធិបល្ល័ង្កទាំងអស់។ ព្រះធាតុរបស់ព្រះមានព្រះភាគសូម្បីប៉ុនគ្រាប់ស្ពៃក៏មិនវិនាសបាត់ក្នុងរវាង (៥០០០ ឆ្នាំដែរ) ។ ព្រះធាតុទាំងឡាយមកប្រជុំគ្នាលើមហាពោធិបល្ល័ង្កហើយ រួមជាព្រះពុទ្ធរូប សំដែងពុទ្ធសរីរៈប្រថាប់គង់សមាធិក្នុងពោធិមណ្ឌលស្ថាន ហើយមានមហាបុរិសលក្ខណៈ ៣២ ប្រការ និងអនុព្យញ្ជនៈ ៨០ ព្រះរស្មីប្រមាណ ១ ព្យាម (ព្រះធាតុសំដែង

www.elibraryofcambodia.org

បាដិហារិយ៍នេះ ១ មានលក្ខណៈគ្រប់គ្រាន់បរិបូណ៌ដូចព្រះអង្គទ្រង់គង់ព្រះធរមាននៅ ។ ក្នុងថ្ងៃនោះទ្រង់ធ្វើបាដិហារិយ៍ ដូចក្នុងថ្ងៃទ្រង់សំដែងយមកប្បាដិហារិយ៍ ។ ក្នុងកាលណោះមនុស្សសូម្បីត្រឹមមួយនាក់ក៏មិនមានក្នុងទីនោះឡើយ មានតែទេវតាមួយម៉ឺនចក្រវាឡមកប្រជុំគ្នាក្នុងទីនោះទាំងអស់ នាំគ្នាយំសោកកន្ទក់កន្ទេញថា ថ្ងៃនេះព្រះទសពលព្រះអង្គទ្រង់បរិនិព្វានហើយ ចាប់តាំងពីថ្ងៃនេះទៅនឹងមានតែសេចក្តីងងឹត ។ លំដាប់នោះ តេជោធាតុក៏ឆេះឡើងអំពីសរីរៈធ្វើឱ្យព្រះសរីរៈនោះដល់នូវសេចក្តីបញ្ញត្តមិនបាន ។ ក៏អណ្តាតភ្លើងឆេះឡើងរហូតដល់ព្រហ្មលោក កាលព្រះធាតុឆេះអស់ហើយអណ្តាតភ្លើងក៏វិនាសបាត់ទៅ ។ ព្រះធាតុព្រះបរមសាស្តាសំដែងអានុភាពដ៏ធំយ៉ាងនេះហើយ ក៏អន្តរធានទៅ ។ ក្នុងកាលណោះពួកទេវតាធ្វើសក្ការៈដោយរបស់ក្រអូប ផ្កាឈើ និងតន្ត្រីទិព្វជាដើម ដូចជាថ្ងៃដែលព្រះដ៏មានព្រះភាគទ្រង់បរិនិព្វានហើយ

www.elibraryofcambodia.org

ធ្វើប្រទក្សិណ ៣ ដង ថ្វាយបង្គំហើយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគដ៏ចំរើន ពួកខ្ញុំព្រះអង្គនឹងបានឃើញនូវព្រះពុទ្ធជាម្ចាស់ដែលត្រាស់ដឹងក្នុងអនាគតទៀតចុះ ហើយក៏ត្រឡប់ទៅកាន់ទីនៅរបស់ខ្លួន ៗ នេះឈ្មោះថា អន្តរធាននៃព្រះធាតុ ។

**ចប់ធាតុអន្តរធាន**

**ដោយសង្ខេប**

www.elibraryofcambodia.org

# ធាតុបូជនីយកថា

**មហាគោតមោ ជិនវរោ កុសិនារម្ហិ និព្វុតោ**
**ធាតុវិត្ថារិកំ អាសិ តេសុ តេសុ បទេសតោ**
**ឯកោ អជាតសត្តុស្ស ឯកោ វេសាលិយា បុរេ**
**ឯកោ កបិលវត្ថុស្មឹ ឯកោ ច អល្លកប្បកេ ។**
**ឯកោ ច រាមគាមម្ហិ ឯកោ ច វេដ្ឋទីបកេ**
**ឯកោ បាវេយ្យកេ មល្លេ ឯកោ ច កោសិនារកេ ។**

ព្រះមហាគោតមជាព្រះជិនស្រីប្រសើរទ្រង់និព្វាន
ក្នុងនគរកុសិនារាព្រះធាតុផ្សាយទៅក្នុងប្រទេសនោះ ៗ
តាមចំណែកគឺព្រះធាតុមួយចំណែកបានទៅព្រះបាទ
អជាតសត្តុ មួយចំណែក បានទៅក្រុងវេសាលី
មួយចំណែក បានទៅក្រុងកបិលភ័ស្តុ មួយចំណែក
បានទៅដែនអល្លកប្បកៈ មួយចំណែក បានទៅក្រុង
រាមគ្រាម មួយចំណែក បានទៅក្រុង វេដ្ឋទីបកៈ
មួយចំណែក បានទៅក្រុងបាវេយ្យកមល្លៈ ឯព្រះធាតុ
មួយចំណែកទៀត បានទៅអ្នកក្រុងកុសិនារា ។

www.elibraryofcambodia.org

**កុម្ភស្ស ថូបំ ការេសិ ព្រាហ្មណោ ទោណសវ្ហយោ**
**អង្គារថូបំ ការេសុំ មោរិយា តុដ្ឋមានសា ។**
**អដ្ឋ សារីរិកា ថូបា នវមោ កុម្ភចេតិយោ**
**អង្គារថូបោ ទសមោ តទាយេវ បតិដ្ឋិតោ ។**

ព្រាហ្មណ៍ឈ្មោះទោណៈ បានធ្វើស្តូបបញ្ចុះកុម្ភ (នាឡិ) ពួកមោរិយជន មានចិត្តជ្រះថ្លា បានធ្វើស្តូបបញ្ចុះ អង្គារ (ធ្យូង) ។ ព្រះស្តូបបញ្ចុះព្រះសារីរិកធាតុមាន ៨ បើរាប់កុម្ភចេតិយមួយផងជា ៩ បើគិតទាំងស្តូប បញ្ចុះព្រះអង្គារមួយទៀតត្រូវជា ១០ ដែលមហាជន ស្ថាបនាទុក ក្នុងកាលនោះ ។

**ឧណ្ហីសំ ចតស្សោ ទាឋា អក្ខកា ទ្វេ ច ធាតុយោ**
**អសម្ភិន្នា ឥមា សត្ត សេសា ភិន្នា វ ធាតុយោ**

ព្រះធាតុ ៧ យ៉ាងគឺ ព្រះឧណ្ហីសធាតុ ១ព្រះទាឋធាតុ ៤ និងដងកាំបិត ២ មិនបានបែកជាចំណែកទេ ព្រះធាតុដ៏ សេសបែកជាចំណែកតូច ៗ ។

**មហន្តា មុគ្គមត្តា ច មជ្ឈិមា ភិន្នតណ្ឌុលា**
**ខុទ្ទកា សាសបមត្តា ច នានាវណ្ណា ច ធាតុយោ**

www.elibraryofcambodia.org

ព្រះធាតុខ្នាតធំប៉ុនគ្រាប់សណ្តែកបាយ ព្រះធាតុខ្នាតកណ្តាល ប៉ុនគ្រាប់អង្ករបាក់ ព្រះធាតុខ្នាតតូចប៉ុនគ្រាប់ស្ពៃ មានពណ៌ផ្សេង ៗ គ្នា ។

**មហន្តា សុវណ្ណវណ្ណា ច  មុត្តវណ្ណា ច មជ្ឈិមា**
**ខុទ្ទកា មកុលវណ្ណា ច  សោឡស ទោណមត្តិកា ។**

ព្រះធាតុខ្នាតធំមានពណ៌ដូចមាស ព្រះធាតុខ្នាតកណ្តាល មានពណ៌ដូចកែវមុក្តា និងព្រះធាតុខ្នាតតូចមានពណ៌ដូចផ្កាម្លិះ រួមទាំងអស់មានប្រមាណ ១៦ នាឡិ ស្មើមួយទោណ ។

**មហន្តា បញ្ច នាឡិយោ  នាឡិយោ បញ្ច មជ្ឈិមា**
**ខុទ្ទកា ឆ នាឡិ ចេវ  ឯតា សព្វាបិ ធាតុយោ ។**

ព្រះធាតុសូម្បីទាំងអស់នេះគឺ ព្រះធាតុខ្នាតធំ មានចំនួន ៥ នាឡិ ព្រះធាតុខ្នាតកណ្តាល មានចំនួន ៥ នាឡិ ព្រះធាតុខ្នាតតូច មានចំនួន ៦ នាឡិ ប៉ុណ្ណោះ ។

**ឧណ្ហីសំ សីហឡេ ទីបេ  ព្រហ្មលោកេ ច វាមកំ**
**សីហឡេ ទក្ខិណក្ខញ្ច  សព្វាបេតា បតិដ្ឋិតា ។**

ព្រះឧណ្ហីសធាតុស្ថិតនៅក្នុងសីហឡទ្វីប ដងកាំបិតស្មា

www.elibraryofcambodia.org

ខាងឆ្វេងស្ថិតនៅក្នុងព្រហ្មលោក ផងកាំបិតស្នាខាងស្តាំ ស្ថិតនៅក្នុងសីហឡទ្វីប ។

**ឯកា ទាឋា តិទសបុរេ ឯកា នាគបុរេ អហុ**
**ឯកា គន្ធារវិសយេ ឯកា កាលិង្គរាជិនោ ។**
**ចត្តាឡីសសមា ទន្តា កេសា លោមា ច សព្វសោ**
**ទេវា ហរឹសុ ឯកេកំ ចក្កវាឡបរម្បរា ។**

ព្រះចង្កូម ១ តម្កល់ក្នុងឋានត្រៃត្រិង្ស ព្រះចង្កូម ១ តម្កល់នៅក្នុងនាគបុរី ព្រះចង្កូម ១ នៅក្នុងដែនគន្ធារៈ ព្រះចង្កូម ១ នៅក្នុងដែនកាលិង្គរាជ ។ ព្រះទន្តទាំង ៤០ គត់ ព្រះកេសា និង ព្រះលោមា ទាំងអស់ពួកទេវតារៀងខ្លួន បាននាំទៅមួយ ៗ កាន់ចក្រវាឡទីទៃ ៗ ។

**វជិរាយំ ភគវតោ បត្តោ ទណ្ឌោ ច ចីវរំ**
**និវាសនំ កុលឃរេ បច្ចត្ថរណំ សិលវ្ហយេ ។**

បាត្រ ឈើច្រត់ និងចីវររបស់ព្រះដ៏មានព្រះភាគតម្កល់ទុកក្នុងដែនវជិរ ស្បង់តម្កល់ទុកនៅក្នុងផ្ទះនៃត្រកូល គ្រឿងកម្រាលតម្កល់ទុកក្នុងក្រុងឈ្មោះ សិលៈ ។

www.elibraryofcambodia.org

**បាដលិបុត្តនគរេ ករកំ កាយពន្ធនំ**
**ចម្បាយំ ឧទកសាដកា ឧណ្ណលោមញ្ច កោសលេ ។**

ធម្មក្រកនិងកាយពន្ធ (វត្ថពន្ធចង្កេះ)តម្កល់ទុកក្នុងក្រុង បាដលិបុត្ត ឧទកសាដកតម្កល់ទុកក្នុងក្រុងចម្បា ព្រះឧណ្ណា-លោម (រោមចិញ្ចើម)តម្កល់ទុកក្នុងដែនកោសល ។

**កាសាវកំ ព្រហ្មលោកេ វេឋនំ តិទសេ បុរេ**
**បាសាណកេ បទំ សេដ្ឋំ យថាបិ កដ្ឋតំ បុរំ**
**និសីទនំ អវន្តីសុ ទេវរដ្ឋេ អត្ថរណំ តទា ។**

សំពត់កាសាវៈ តម្កល់ទុកក្នុងព្រហ្មលោក ផ្នួតតម្កល់ទុក ក្នុងឋានត្រៃត្រិង្ស ស្នាមព្រះបាទដ៏ប្រសើរ ដែលមិនបាត់ទៅ តម្កល់ទុលើថ្ម សំពត់និសីទនៈ តម្កល់ទុកក្នុងអវន្តិជនបទ គ្រឿងកម្រាល តម្កល់ទុកក្នុងដែនឈ្មោះទេវៈ ក្នុងកាល នោះ ។

**អរណី ច មិថិលាយំ វិទេហេ បរិសាវនំ**
**វាសី សូចិឃរញ្ចាបិ ឥន្ទបត្ថបុរេ តទា ។**

កាលនោះ ដែកភ្លើងតម្កល់ទុកក្នុងក្រុងមិថិលា តម្រងទឹក តម្កល់ទុកក្នុងដែនវិទេហៈ កាំបិតកោរនិងបំពង់ម្ជុល តម្កល់

ទុកនៅក្នុងឥន្ទបត្ថបុរី ។

**បរិក្ខារា អវសេសា ជនបទន្តកេ តទា**

**បរិភុញ្ជានិ មុនិនា ហេស្សន្តិ មនុជា តទា ។**

កាលនោះគ្រឿងបរិក្ខារដ៏សេសទាំងឡាយ តម្កល់ទុកក្នុងជនបទជាទីបំផុត ពួកមនុស្សតែងបូជាគ្រឿងបរិក្ខារទាំងឡាយ ដែលព្រះមុនីទ្រង់ប្រើប្រាស់ ។

**ធាតុវិត្ថារកំ អាសិ គោតមស្ស មហេសិនោ**

**បាណីនំ អនុកម្បាយ អាហុ បោរាណកំ តទាតិ ។**

ការផ្សាយទៅនៃព្រះធាតុរបស់ព្រះមហេសី ព្រះនាមគោតម ក្នុងកាលនោះ ជាប្រពៃណីពីបុរាណ ( នៃព្រះពុទ្ធទាំងឡាយ ) សម្រាប់ទុកអនុគ្រោះ ស្រោចស្រង់សត្វទាំងឡាយ ជាខាងក្រោយ ។

( សុត្ត. ខុទ្ទកនិកាយ ពុទ្ធវំស លេខ ៧៧ ទំព័រ ២៣៦-២៣៨)

## ចប់ធាតុភាជនីយកថា

www.elibraryofcambodia.org

**ពុទ្ធសារីរិកឋិតាគតថា**

**អដ្ឋទោណំ ចក្ខុមតោ សរីរំ**

**សត្តទោណំ ជម្ពុទីបេ មហេន្តិ**

**ឯកញ្ច ទោណំ បុរិសវរុត្តមស្ស**

**រាមគាមេ នាគរាជា មហេន្តិ ។**

ព្រះសារីរធាតុ របស់ព្រះសម្មាសម្ពុទ្ធដ៏មាន ចក្ខុ មាន ចំនួន ៨ ទោណៈ ព្រះសារីរធាតុ ៧ ទោណៈ ជនទាំងឡាយធ្វើសក្ការៈបូជាក្នុង ជម្ពូទ្វីប ព្រះសារីរធាតុរបស់ព្រះសម្ពុទ្ធជា បុរសដ៏ប្រសើរខ្ពង់ខ្ពស់ ១ ទោណៈទៀត ពួកនាគរាជធ្វើសក្ការៈបូជាក្នុងរាមគ្រាម ។

**ឯកា ហិ ទាឋា តិទិវេហិ បូជិតា**

**ឯកា បន គន្ធារបុរេ មហីយតិ**

**កាលិង្គរញ្ញោ វិជិតេ បុនេកំ**

**ឯកំ បុន នាគរាជា មហេន្តិ ។**

ព្រះទាឋា (ចង្កូម) ១ ពួកទេវតានាំយកទៅបូជា ព្រះទាឋា ១ ទៀត ពួកជនធ្វើសក្ការៈបូជាក្នុងគន្ធារបុរី ព្រះទាឋា ១ ទៅពួក

www.elibraryofcambodia.org

ជនធ្វើសក្ការៈបូជា ក្នុងដែនរបស់ស្តេចកាលិង្គ ព្រះទាឋា ១ ទៀត ពួកនាគរាជនាំទៅធ្វើសក្ការៈ បូជា ។

**តស្សេវ តេជេន អយំ វសុន្ធរា**
**អាយាគសេដ្ឋេហិ មហី អលង្កតា**
**ឯវំ ឥមំ ចក្ខុមតោ សរីរំ**
**សុសក្កតំ សក្កតសក្កតេហិ ។**

ហេតុតែតេជះ នៃព្រះសារីរិកធាតុរបស់ព្រះមានព្រះ-ភាគនោះឯង មហាប្រឋពីនេះ ក៏បានប្រដាប់ដោយគ្រឿងបូជាពិសេស ឯព្រះសារីរធាតុ របស់ព្រះសម្ពុទ្ធដ៏មានចក្ខុនេះ គឺពួកសត្វដែលធ្លាប់ធ្វើនូវគ្រឿងសក្ការៈដ៏លើសលុបទាំងឡាយ បានធ្វើសក្ការៈ ដោយល្អហើយយ៉ាងនេះ ។

**ទេវិន្ទនាគិន្ទនរិន្ទបូជិតោ**
**មនុស្សិន្ទសេដ្ឋេហិ តថេវ បូជិតោ**
**តំ តំ វន្ទថ បញ្ជលិកា ភវិត្វា**
**ពុទ្ធោ ហវេ កប្បសតេហិ ទុល្លភោតិ ។**

ស្តេចទេវតា ស្តេចនាគ និងស្តេចមនុស្ស បានបូជាហើយ ចំពោះព្រះសម្ពុទ្ធជាម្ចាស់ ទាំងពួកមនុស្សអ្នកប្រសើរ

www.elibraryofcambodia.org

ក៏បានធ្វើបូជាព្រះអង្គហើយដូច្នេះដែរ ព្រោះហេតុនោះ អ្នកទាំងឡាយ ចូរផ្គងអញ្ជលីឡើង ថ្វាយបង្គំ ព្រះពុទ្ធជាម្ចាស់នោះចុះ ព្រោះថាព្រះពុទ្ធជាម្ចាស់ទាំងឡាយ ជាបុគ្គលរកបានក្រ ដោយរយនៃកប្បទាំងឡាយ ។

**ចត្តាឡីសសមា ទន្តា**

**កេសា លោមា ច សព្វសោ**

**ទេវា ហរឹសុ ឯកេកំ**

**ចក្កវាឡបរម្បរាតិ ។**

ព្រះទន្តទាំង ៤០ គត់ក្តី កេសាក្តី

ព្រះលោមាក្តី ទាំងអស់ ពួកទេវតា

ដែលនៅក្នុងចក្រវាឡត ១ គ្នានាំយក

ទៅមួយ ១ ម្នាក់ ។

(សុត្ត.ទីឃ. មហា. ១៦/៣៤៩.៣៥០)

**មហាពុទ្ធសាវិកាចិត្តរោគមហា**

# ព្រះចេតិយ

នៅក្នុងអត្ថបទនេះ ខ្ញុំសូមរៀបរាប់អំពីពាក្យថា **"ចេតិយ"** ដើម្បីប្រគេនដល់ព្រះតេជគុណ ញាតិញោមគ្រាន់បានមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនាក្រៃលែងថែមទៀត ។

ពាក្យថា **"ចេតិយ"** នេះ នៅក្នុងគម្ពីរសារត្ថទីបនីដីកា (សារត្ថ.១/១៦៤) ថា **ចយិតព្វំ បូជេតព្វន្តិ ចេតិយំ, ឥដ្ឋកាទីហិ ចិតត្តា វា ចេតិយំ** វត្ថុឈ្មោះថា "ចេតិយ" ព្រោះអត្ថថា គួរលើកតម្កើង គឺគួរបូជារបស់ទេវតានិងមនុស្សទាំងឡាយ. ម្យ៉ាងទៀត ឈ្មោះថា "ចេតិយ" ព្រោះគេសាងឡើងដោយវត្ថុទាំងឡាយមានឥដ្ឋជាដើម ។

ចំណែកក្នុងគម្ពីរបរមត្ថជោតិកា (ខុទ្ទកបាឋដ្ឋកថា១/១៩៧) ថា **ចយិតព្វន្តិ ចេតិយំ, បូជេតព្វន្តិ វត្ថុ ហោតិ , ចិតត្តា វា ចេតិយំ** វត្ថុឈ្មោះថា "ចេតិយ" ព្រោះអត្ថថា គួរលើកតម្កើង

www.elibraryofcambodia.org

លោកអធិប្បាយថា គួរបូជារបស់ទេវតានិងមនុស្សទាំងឡាយ ម្យ៉ាងទៀត ឈ្មោះថា "ចេតិយ" ព្រោះវិចិត្រហើយ ។

ក្នុងបរមត្ថជោតិកានេះ លោកពោលបន្ថែមទៀតថា

**តម្បនេតំ តិវិធំ ហោតិ បរិភោគចេតិយំ ឧទ្ទិស្សកចេតិយំ សធាតុចេតិយន្តិ ។ តត្ថ ពោធិរុក្ខោ បរិភោគចេតិយំ , ពុទ្ធបដិមា ឧទ្ទិស្សកចេតិយំ, ធាតុគព្ភា ថូបា សធាតុចេតិយំ នាម ។**

ក៏ចេតិយនោះ មាន ៣ យ៉ាង គឺ បរិភោគចេតិយ១ ឧទ្ទិស្សកចេតិយ១ សធាតុចេតិយ១ ។ បណ្ដាចេតិយទាំងនោះ ដើមពោធិព្រឹក្ស ឈ្មោះថា **បរិភោគចេតិយ**, ព្រះពុទ្ធបដិមា ឈ្មោះថា **ឧទ្ទិស្សកចេតិយ** ព្រះសថូបដែលបញ្ចុះព្រះធាតុទុក ខាងក្នុង ឈ្មោះថា **សធាតុចេតិយ** ។

ចំណែកសារត្ថទីបនីដីកា ( សារត្ថ.១/២១៥ ) ថា ៖

**បរិភុត្តូបករណានិ និទហិត្វា កតំ ចេតិយំ បរិភោគចេតិយន្តិ មជ្ជំ ។ តិវិធម្បិ ចេតិយំ វទន្តិ បរិភោគចេតិយំ ធាតុចេតិយំ**

www.elibraryofcambodia.org

**ធម្មចេតិយន្តិ ។ តត្ថ បរិភោគចេតិយំ វុត្តនយមេវ ។ ធាតុចេតិយំ បន ធាតុយោ និទហិត្វា កតំ ។ បដិច្ចសមុប្បាទាទិលិខិតពោត្ថកំ និទហិត្វា កតំ បន ធម្មចេតិយំ នាម ។**

ព្រះចេតិយដែលគេធ្វើតម្កល់ទុកនូវវត្ថុប្រើប្រាស់( របស់ព្រះសម្មា-សម្ពុទ្ធ) បណ្ឌិតគប្បីជ្រាបថា "ជាបរិភោគចេតិយ" ។ អាចារ្យទាំងឡាយពោលថា ចេតិយមាន ៣ យ៉ាង គឺ **បរិភោគចេតិយ ១ ធាតុចេតិយ ១ ធម្មចេតិយ ១** ។ បណ្តាចេតិយទាំងឡាយនោះ បរិភោគចេតិយមានន័យដូចយើងពោលហើយ ចេតិយដែលគេធ្វើតម្កល់នូវព្រះធាតុទាំងឡាយ ឈ្មោះថា **ធាតុចេតិយ** ។ ក៏ចេតិយដែលគេធ្វើតម្កល់នូវសាស្ត្រាស្លឹករឹត្ត ដែលសរសេរធម៌ មានបដិច្ច-សមុប្បាទជាដើម( សព្វថ្ងៃបានដល់ធម្មបណ្ណាល័យតម្កល់ព្រះត្រៃ-បិដក) ឈ្មោះថា **ធម្មចេតិយ** ។

**សារីរិកំ បរិភោគិកំ ឧទ្ទិស្សកន្តិ ឯវម្បិ តិប្បភេទំ ចេតិយំ វទន្តិ ។ អយំ បន ភេទោ បរិយាយបស្សិ**

www.elibraryofcambodia.org

**ឧទ្ទិស្សចេតិយេនេវ សង្គហិតត្តា សុង្គហំ យុជ្ជតិ ។**

អាចារ្យទាំងឡាយពោលថា ចេតិយ មាន ៣ ប្រភេទ គឺ **សារីរិកធាតុចេតិយ ១ បរិភោគចេតិយ ១ ឧទ្ទិស្សកចេតិយ ១** ។ ក៏ចេតិយ ៣ ប្រភេទនោះ សមជាង(ចេតិយប្រភេទមុន) ព្រោះរួមបដិមារូប គឺ ព្រះពុទ្ធបដិមាដោយឧទ្ទិស្សកចេតិយផង ។

សរុបសេចក្តីចេតិយ មាន ៤ ប្រភេទ គឺ ÷

១- **បរិភោគចេតិយ** បានដល់ ចេតិយ ដែលបញ្ចុះបរិក្ខារប្រើប្រាស់ មានបាត្រ ចីវរ និងដើមពោធិព្រឹក្សជាដើម ។

២-**ធាតុចេតិយ** បានដល់ ចេតិយ ដែលបញ្ចុះព្រះបរមសារីរិកធាតុរបស់ព្រះសម្មាសម្ពុទ្ធ ឬព្រះអរហន្តធាតុ ។

៣-**ធម្មចេតិយ** បានដល់ ចេតិយ ដែលតម្កល់នូវសាស្ត្រាស្លឹករឹត្ត គឺតម្កល់គម្ពីរព្រះត្រៃបិដក ។

៤-**ឧទ្ទិស្សកចេតិយ** បានដល់ ព្រះពុទ្ធរូបដែលសាងឡើងតំណាងព្រះសម្មាសម្ពុទ្ធ ។

www.elibraryofcambodia.org

ចេតិយទាំង៤ប្រភេទនេះ ជាតំណាងព្រះអរហន្តសម្មាសម្ពុទ្ធ ដែលទ្រង់បរិនិព្វានទៅហើយ ជាវត្ថុគួរគោរពបូជា នមស្សការ ជំនួសព្រះអង្គ ហើយរមែងបានបុណ្យកុសលជាច្រើន រាប់ប្រមាណ មិនបាន ។ នៅក្នុងអបទាន បានសំដែងប្រវត្តិព្រះថេរៈ ព្រះថេរី ជាច្រើន ដែលក្នុងអតីតជាតិ លោកទាំងនោះ បានបូជានូវព្រះ ចេតិយ ដោយវត្ថុទាំងឡាយ មានផ្កាជាដើម ដល់មកក្នុងសាសនា ព្រះជិនស្រីរបស់យើង លោកទាំងនោះ បានស្តាប់ធម៌ សម្រេចជា ព្រះអរហន្តខ្លះ អនាគាមីខ្លះ សកទាគាមីខ្លះ សោតាបន្នខ្លះ នេះជាអានិសង្សនៃការបូជា **ព្រះចេតិយ** ។ កាលបើសាធុជន ឃើញអានិសង្សនៃការបូជាព្រះចេតិយថា នាំមកនូវអានិសង្ស ដ៏ច្រើនហើយ តើគួរស្ងៀមនៅមិនបូជាព្រះចេតិយបានទេ ។

នៅក្នុងខុទ្ទកបាឋៈនិធិកណ្ឌសូត្រព្រះអង្គត្រាស់ថា **ចេតិយ** ជាស្ថាន ទីដ៏ប្រសើរ សម្រាប់កប់កំណប់ទ្រព្យគឺបុណ្យកុសល ។

នៅក្នុងអដ្ឋកថា ធម្មបទ និង អដ្ឋកថាវិមានវត្ថុ បានពោល

www.elibraryofcambodia.org

ដល់ការសាងចេតិយ ក្នុងវេលាដែលព្រះកស្សបសម្មាសម្ពុទ្ធទ្រង់បរិនិព្វានហើយ ។

ក្នុងមហាវគ្គមានពោលដល់ការសាង ព្រះចេតិយរបស់ព្រះវិបស្សីសម្មាសម្ពុទ្ធ , ព្រះអង្គទ្រង់ត្រាស់ការបូជាផ្កាឈូកដល់ព្រះចេតិយថា មានប្រយោជន៍ធំដល់អ្នកបូជា ។

ក្នុងគម្ពីរទីឃនិកាយមហាវគ្គ (១៦) មានពោលដល់ការសាងព្រះចេតិយ១០ កន្លែងសម្រាប់ជាគ្រឿងបូជារបស់ទេវតានិងមនុស្សទាំងឡាយអស់កាលយូរអង្វែង ។

នៅក្នុងគម្ពីរមិលិន្ទបញ្ហាបករណ៍ (មិលិន្ទ.៣៤៨) ត្រង់អនុមានបញ្ហាកណ្ឌព្រះនាគសេនពោលឧបមាដល់ ព្រះចេតិយថាដូចជាផ្សារលក់ទំនិញរបស់ទាំងពួង ជាវត្ថុប្រសើរអាចឱ្យសម្បត្តិទាំងពួង ដូចតទៅ ៖

ស្តេចមិលិន្ទសួរព្រះនាគសេនថា **ភន្តេ នាគសេន កតមំ ពុទ្ធស្ស ភគវតោ សព្វាបណំ ។** បពិត្រព្រះនាគសេនដ៏ចំរើន

www.elibraryofcambodia.org

តើអ្វីជាហាងលក់ទំនិញទាំងពួងរបស់ព្រះសម្មាសម្ពុទ្ធ? ព្រះនាគ-សេនឆ្លើយតបនឹងស្តេចមិលិន្ទថា **សព្វាបណំ ខោ មហារាជ ភគវតោ នវង្គំ ពុទ្ធវចនំ សារីរិកានិ បរិភោគិកានិ ចេតិយានិ សង្ឃរតនញ្ច ។ល។ ឥទំ វុច្ចតិ មហារាជ "ភគវតោ សព្វាបណ"ន្តិ** បពិត្រមហារាជព្រះពុទ្ធវចនៈប្រកបដោយអង្គ ៩ ព្រះបរមសារីរិកធាតុ ព្រះចេតិយ ជាគ្រឿងប្រើប្រាស់នៃព្រះដ៏មានព្រះភាគ រួមទាំងព្រះសង្ឃរតនៈ ជាហាងលក់ទំនិញទាំងពួងរបស់ព្រះសម្មាសម្ពុទ្ធ ។ បពិត្រមហារាជ ព្រះដ៏មានព្រះភាគទ្រង់ដាក់លក់ជាតិសម្បត្តិ ភោគសម្បត្តិ អាយុសម្បត្តិ អារោគ្យ-សម្បត្តិ វណ្ណសម្បត្តិ បញ្ញាសម្បត្តិ មានុសិកសម្បត្តិ ទិព្វសម្បត្តិ និងនិព្វានសម្បត្តិ ក្នុងហាងលក់ទំនិញទាំងពួងនោះ ។ បុគ្គលឯណាចង់បាននូវសម្បត្តិនោះៗ គ្រាន់តែចំណាយនូវដើមទុន គឺកម្មនឹងអាចទិញនូវសម្បត្តិនោះៗ តាមសេចក្តីប្រាថ្នារបស់ខ្លួនបាន ។ បុគ្គលខ្លះទិញសម្បត្តិនោះៗ ដោយការសមាទានសីល, បុគ្គលខ្លះ

www.elibraryofcambodia.org

ទិញសម្បត្តិនោះៗ ដោយការក្សាឧបោសថ យ៉ាងណា មហាបពិត្រ ពួកគេរមែងបាននូវសម្បត្តិផ្សេងៗ ព្រោះអាស្រ័យ ដើមទុនគឺកម្មសូម្បីបន្តិចបន្តួច ។ បពិត្រមហារាជ ដូចជាទីផ្សារ លក់ល្ង សណ្តែកបាយ សណ្តែករាជមាស អ្នកទិញអាចទិញ ល្ង សណ្តែកបាយ សណ្តែករាជមាស ដោយប្រើអង្ករ សណ្តែកបាយ សណ្តែករាជមាសដូរក៏បាន ឬអាចទិញដោយដើមទុន គឺកម្មសូម្បីបន្តិចក៏បាន យ៉ាងណា មហាបពិត្រ អាត្មាពោលថា ពួកគេតែងបានសម្បត្តិផ្សេងៗ ព្រោះអាស្រ័យ ដើមទុនគឺកម្មសូម្បីបន្តិចបន្តួច ក៏ដូច្នោះដែរ ។

**កីណិត្វា សទ្ធាមូលេន សមិទ្ធា ហោថ ភិក្ខវេ ។**

ម្នាលភិក្ខុទាំងឡាយ សូមពួកលោកចូរទិញនូវសម្បត្តិទាំងនោះ និងជាអ្នកបរិបូណ៌ដោយដើមទុន គឺសទ្ធាចុះ ។

ក្នុងគម្ពីរមិលិន្ទប្បញ្ហាបករណ៍នេះ ព្រះនាគសេនបានដោះស្រាយនឹងស្តេចមិលិន្ទថា ព្រះបរមសារីរិកធាតុក្តី ព្រះចេតិយក្តី

www.elibraryofcambodia.org

ជាគ្រឿងប្រើប្រាស់របស់ព្រះអង្គ មានចីវរនិងដើមពោធិព្រឹក្សជាដើម និងព្រះពុទ្ធវចនៈគឺព្រះត្រៃបិដក ។ វត្ថុទាំងនេះ តែងនាំមកនូវប្រយោជន៍ទាំងពួងតាមសេចក្តីត្រូវការរបស់សព្វសត្វ ។ បុគ្គលណាចង់បានសម្បត្តិយ៉ាងណាមួយ គឺ មានជាតិខ្ពង់ខ្ពស់ មានទ្រព្យសម្បត្តិច្រើន មានអាយុវែង មិនមានរោគ មានពណ៌សម្បុរល្អ សម្បត្តិមនុស្ស សម្បត្តិ ទេវតា និង សម្បត្តិដ៏វិសេសគឺព្រះនិព្វាន បុគ្គលនោះបានបូជា ព្រះចេតិយ ដោយវត្ថុទាំងឡាយ មានគ្រឿងក្រអូបជាដើម រមែងបានសម្បត្តិទាំងនោះ ដោយពិត ។

សួរថា បានព្រោះហេតុអ្វី ?

ព្រោះបានបូជាព្រះអរហន្តសម្មាសម្ពុទ្ធ ជាអគ្គបុគ្គលជាទក្ខិណេយ្យបុគ្គល ជាបូជារហបុគ្គលក្នុងលោកនិងដោយកុសលចេតនាជ្រះថ្លាចំពោះព្រះអង្គ ដោយតាំងចិត្តថា អាត្មាអញសូមបូជានូវវត្ថុទាំងឡាយ មានគ្រឿងក្រអូបជាដើមនេះ ដល់ព្រះដ៏មានព្រះភាគអង្គនោះ ។ កុសលកម្មដែលបានធ្វើពេលនោះ ជាវិបាកនាំមកនូវផល

www.elibraryofcambodia.org

គឺការបាននូវសម្បត្តិទាំងពួង តាមសេចក្តីប្រាថ្នារបស់ខ្លួន ។

**យោ លោកិយសម្បត្តី ច លោកុត្តរសម្បត្តី ច**
**ឥច្ឆាហិ សព្វំ ឥច្ឆន្តិ សេដ្ឋំ ចេតិយំ បូជេយ្យុំ។**

ព្រោះហេតុនោះឯង បុគ្គលណា ប្រាថ្នានូវសម្បត្តិទាំងពួង គឺលោកិយសម្បត្តិនិងលោកុត្តរសម្បត្តិ បុគ្គលនោះគប្បីបូជានូវព្រះចេតិយដ៏ប្រសើរចុះ ។

ទោសនៃការមិនទៅកាន់ព្រះចេតិយ ឈ្មោះថា **មិនគោរពព្រះពុទ្ធ** នៅក្នុងអដ្ឋកថា លោកសំដែងច្រើនកន្លែងអំពី ទោសនៃការមិនទៅកាន់ព្រះចេតិយថា "មិនគោរពព្រះពុទ្ធ" មានគម្ពីរសមន្តបា្បសាទិកា (សមន្ត.៣/៤៣៦) និងក្នុងគម្ពីរសារត្ថប្បកាសិនី (សំ.អដ្ឋ.២/២២៧) ជាដើមថា ៖

**យោ ពុទ្ធេ ធរមានេ ឧបដ្ឋានំ ន គច្ឆតិ, បរិនិព្វុតេ ចេតិយដ្ឋានំ ពោធិដ្ឋានំ ន គច្ឆតិ, ចេតិយំ វា ពោធឹ វា ន វន្ទតិ , ចេតិយង្គណេ សឆត្តោ សឧបាហនោ ចរតិ ,**

www.elibraryofcambodia.org

**នគ្គេពស្ស ពុទ្ធេ គារវោតិ វេទិតព្វោ ។**

កាលព្រះពុទ្ធទ្រង់ព្រះធរមាននៅឡើយ បុគ្គលណា មិនទៅកាន់ទីឧបដ្ឋាកព្រះអង្គ , ពេលព្រះអង្គទ្រង់បរិនិព្វានទៅហើយ បុគ្គលណា មិនទៅកាន់ទីព្រះចេតិយ កន្លែងដើមពោធិព្រឹក្ស បុគ្គលណា មិនថ្វាយបង្គំព្រះចេតិយក្តី, មិនថ្វាយបង្គំដើមពោធិ-ព្រឹក្សក្តី,បុគ្គលណា បាំងឆត្រពាក់ស្បែកជើង ដើរលើលានចេតិយ, បណ្ឌិតគប្បីជ្រាបថា សេចក្តីគោរពក្នុងព្រះពុទ្ធរបស់បុគ្គលនោះ មិនមានបន្តិចទាល់តែសោះ ។

តាមសេចក្តីក្នុងអដ្ឋកថា លោកបញ្ជាក់នេះ សឱ្យឃើញថា ព្រះចេតិយក្តី ដើមពោធិព្រឹក្សក្តី ទុកតំណាងព្រះពុទ្ធ ស្មើនិងព្រះអង្គគង់នៅសព្វថ្ងៃ យើងគួរទៅកាន់ទីព្រះចេតិយដើមពោធិព្រឹក្ស ឱ្យបានជានិច្ចជាកាល ដើម្បីនមស្សការបូជា ថ្វាយបង្គំ កុំបីខាន។

**ពុទ្ធេ គារវំ ករោតិ　យោ ចេតិយំ វា ពោធឹ វា**
**សោ សព្វកាលេ វន្ទេយ្យ　ឯតស្ស សុវត្ថិ ហោតិ ។**

www.elibraryofcambodia.org

បុគ្គលណាធ្វើនូវសេចក្តីគោរពក្នុងព្រះពុទ្ធ បុគ្គលនោះគប្បីថ្វាយបង្គំនូវព្រះចេតិយ និង ដើមពោធិព្រឹក្សឱ្យបានសព្វ ៗ កាល សិរីសួស្តីនឹងមានដល់បុគ្គល (អ្នកថ្វាយបង្គំព្រះចេតិយជាដើម) នោះ ជានិច្ចជាកាលដែរ ។

## បុគ្គលអ្នកទំលាយចេតិយ មានទោសស្មើអនន្តរិយកម្ម

នៅក្នុងគម្ពីរ មនោរថបូរណី (អំ.អដ្ឋ.២/១៩១) និងគម្ពីរបបញ្ចសូទនី (ម.អដ្ឋ.៣/៧៧) និងគម្ពីរសម្មោហវិនោទនី (អដ្ឋកថាវិភង្គ ១/៤៥៧) បានសំដែងទោសនៃបុគ្គលបៀតបៀនព្រះសារីរិកធាតុ ព្រះចេតិយ និងដើមពោធិព្រឹក្ស មានបាលីថា ៖

**អថ យេ ច បរិនិព្វុតេ តថាគតេ ចេតិយំ ភិន្ទន្តិ. ពោធឹ ឆិន្ទន្តិ. ធាតុម្ហិ ឧបក្កមន្តិ. តេសំ កឹ ហោតីតិ ។ ភារិយំ កម្មំ ហោតិ អនន្តរិយសទិសំ ។**

សួរថា តមកកាលព្រះតថាគត ទ្រង់បរិនិព្វានទៅហើយ បុគ្គលណា ទំលាយព្រះចេតិយ ទំលាយដើមពោធិព្រឹក្ស ប្រទូស្តរាយ

www.elibraryofcambodia.org

នឹងព្រះបរមសារីរិកធាតុ តើកម្មអ្វីតែងមានដល់បុគ្គលនោះ?

ឆ្លើយថា (កាលបុគ្គលនោះធ្វើ ដូច្នោះ) ជាកម្មធ្ងន់ស្មើដោយអនន្តរិយកម្ម ។

**សធាតុកំ បន ថូបំ វា បដិមំ វា ពាធមានំ ពោធិសាខំ ឆិន្ទិតុំ វដ្ដតិ ។ សចេបិ តត្ថ និលីនា សកុណា ចេតិយេ វច្ចំ បាតេន្តិ, ឆិន្ទិតុំ វដ្ដតិយេវ ។ បរិភោគចេតិយតោ ហិ សរីរចេតិយំ មហន្តតរំ ។** តែបើកាត់នូវមែកដើមពោធិព្រឹក្សដែលបៀតបៀននូវស្តូប ដែលតម្កល់នូវព្រះសារីរិកធាតុក្តី ព្រះពុទ្ធបដិមាក្តី ក៏គួរ ។ ប្រសិនបើសត្វស្លាប(មានចាបជាដើម)ដែលនៅលើដើមពោធិព្រឹក្សនោះ ជុះអាចម៍ដាក់ព្រះចេតិយ កាត់ដើមពោធិព្រឹក្សនោះចេញក៏គួរ ។ ព្រោះសារីរិកចេតិយ គឺ ព្រះបរម-សារីរិកធាតុ សំខាន់ជាងបរិភោគចេតិយ (ដើមពោធិព្រឹក្ស) ។

**ចេតិយវត្ថុំ ភិន្ទិត្វា គច្ឆន្តំ ពោធិមូលម្បិ ឆិន្ទិត្វា ហរិតុំ វដ្ដតិ ។ យា បន ពោធិសាខា ពោធិឃរំ ពាធតិ, តំ**

www.elibraryofcambodia.org

**គេហរបូនត្ថំ ឆិន្ទិតុំ ន លព្ភតិ . ពោធិអត្ថំ ហិ គេហំ, ន គេហត្ថំ ពោធិ ។** សូម្បីកាត់នូវឫសដើមពោធិព្រឹក្ស ដែលដុះចាក់ទំលាយព្រះចេតិយ ក៏គួរ ។ ចំណែកមែកដើមពោធិព្រឹក្សណា បៀតបៀននូវផ្ទះនៃដើមពោធិព្រឹក្ស នឹងកាត់នូវមែកពោធិព្រឹក្សនោះចេញ ដើម្បីរក្សាផ្ទះមិនគួរ . ព្រោះថាផ្ទះធ្វើដើម្បីប្រយោជន៍ដល់ដើមពោធិព្រឹក្ស មិនមែនដើមពោធិព្រឹក្សនោះ ប្រយោជន៍ដល់ផ្ទះទេ ។

**អាសនឃរេបិ ឯសេវ នយោ ។ យស្មឹ បន អាសយនឃរេ ធាតុ និទហិតា ហោតិ , តស្ស រក្ខនត្ថាយ ពោធិសាខំ ឆិន្ទិតុំ វដ្ដតិ ។ ពោធិជគ្គនត្ថំ និតរណសាខំ វា បតិដ្ឋានំ វា ឆិន្ទិតុំ វដ្ដតិយេវ ។** សូម្បីក្នុងផ្ទះអាសនៈក៏មានន័យដូចគ្នា ។ ក៏ព្រះបរមសារីរិកធាតុ តម្កល់ក្នុងផ្ទះអាសនៈណា នឹងកាត់មែកដើមពោធិព្រឹក្ស ដើម្បីរក្សានូវផ្ទះអាសនៈនោះគួរ ។ នឹងកាត់ចេញនូវមែក ដែលឱនចុះក្តី ដែលស្អុយក្តី ដើម្បីទំនុក

www.elibraryofcambodia.org

បំរុងនូវដើមពោធិព្រឹក្ស គួរមែនពិត ។

**ភគវតោ សរីរប្បដិជគ្គនេ វិយ បុញ្ញម្បិ ហោតិ ។**

(ការរក្សាដើមពោធិព្រឹក្សនេះ) បុណ្យក៏បានដូចការបដិបត្តិព្រះសរីរៈនៃព្រះដ៏មានព្រះភាគ ។

នៅក្នុងគម្ពីរ ឧបរិបណ្ណាសដីកា ឈ្មោះ លីនត្ថប្បកាសិនី (៣/៣៥១) ខែពន្យល់ថា ៖

**សរីរប្បដិជគ្គនេ វិយាតិ សត្ថុរូបកាយប្បដិជគ្គនេ វិយ**

បទថា **សរីរប្បដិជគ្គនេ វិយ** សេចក្តីថា បុគ្គលកាលរក្សានូវដើមពោធិព្រឹក្ស រមែងបានបុណ្យដូចការបដិបត្តិរូបកាយនៃព្រះសាស្តា ។

នៅក្នុងគម្ពីរខុទ្ទកនិកាយ ខុទ្ទកបាឋៈ(៥២/១៦) ព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់បង្ហាញ ការកប់កំណប់ទ្រព្យដ៏ប្រសើរថា ៖

**យស្ស ទានេន សីលេន    សញ្ញមេន ទមេន ច**

**និធិ សុនិហិតោ ហោតិ    ឥត្ថិយា បុរិសស្ស វា**

www.elibraryofcambodia.org

**ចេតិយម្ហិ ច សង្ឃេ វា  បុគ្គលេ អតិថីសុ វា**
**មាតរិ បិតរិ វាបិ  អថោ ជេដ្ឋម្ហិ ភាតរិ**
**ឯសោ និធិ សុនិហិតោ  អជេយ្យោ អនុគាមិកោ**
**បហាយ គមនីយេសុ  ឯតំ អាទាយ គច្ឆតិ**
**អសាធារណមញ្ញេសំ  អចោរហរណោ និធិ**

កំណប់ទ្រព្យដែលស្ត្រីឬបុរសណា បានកប់ទុក
ល្អហើយ ដោយទាន សីល ដោយការសង្រួម
និងដោយការទូន្មានខ្លួនក្នុងចេតិយឬក្នុងសង្ឃ
ឬក្នុងបុគ្គល ឬក្នុងភ្ញៀវ ឬមួយក្នុងមាតា ក្នុង
បិតា ឬថា ក្នុងបងប្រុស-ស្រីដែលជាចម្បង
កំណប់ទ្រព្យនុ៎ះ ចាត់ជាកំណប់ទ្រព្យ ដែល
កប់ទុកប្រពៃហើយ នរណាៗ មិនគប្បីផ្ចាញ់
បាន ជាកំណប់ទ្រព្យ ដែលជាប់តាមខ្លួនទៅ
កាលភោគៈទាំងឡាយ ដែលខ្លួនត្រូវលះបង់

www.elibraryofcambodia.org

ហើយទៅ ខ្លួនរមែងកាន់យកនូវកំណប់ គឺ
បុណ្យធ្ងន់ទៅ កំណប់ទ្រព្យគឺ បុណ្យមិនទូទៅ
ដល់ពួកជនដទៃ ជារបស់ដែលចោរលួចទៅ
មិនបាន ។

កយិរាថ ធីរោ បុញ្ញានិ     យោ និធិ អនុគាមិកោ
ឯស ទេវមនុស្សានំ     សព្វកាមទទោ និធិ
យំ យំ ទេវាភិបត្ថេន្តិ     សព្វមេតេន លព្ភតិ ។

កំណប់ទ្រព្យ គឺ បុណ្យណា ជាប់តាមខ្លួនទៅបាន
អ្នកប្រាជ្ញ គួរធ្វើនូវកំណប់ទ្រព្យ គឺបុណ្យធ្ងន់ ឱ្យ
នូវសេចក្តីប្រាថ្នាគ្រប់យ៉ាងដល់ទេវតានិងមនុស្ស
ទាំងឡាយ ពួកទេវតានិងមនុស្សទាំងឡាយ
ប្រាថ្នាណាស់ នូវផលណា ៗ ផលទាំងពួងនោះ ៗ
រមែងបានដោយកំណប់ទ្រព្យ គឺបុណ្យធ្ងន់ ។

សុវណ្ណតា សុសរតា     សុសណ្ឋានំ សុរូបតា

www.elibraryofcambodia.org

**អធិបច្ចំ បរិវារោ សព្វមេតេន លព្ភតិ**

**ភាពជាអ្នកមានសម្បុរផូរផង់ មានសំលេងពីរោះ ទ្រង់ទ្រាយល្អ រូបល្អ ជាអធិបតី មានយសបរិវារ ផលទាំងអស់ រមែងបានដោយកំណប់ទ្រព្យ គឺ បុណ្យនុ៎ះឯង ។**

**ចប់ព្រះធម៌ដោយសង្ខេប**

www.elibraryofcambodia.org

# ពិធីពុទ្ធាភិសេក

ពុទ្ធាភិសេកនេះ ជាការនិយមរាប់អានរបស់ជនជាតិខ្មែរយើងគ្រប់កន្លែង ដែលមានកម្មពិធីបុណ្យព្រះពុទ្ធរូប ឬ ឆ្លងព្រះចេតិយ មិនអាចលះបង់បាន ដោយយល់ឃើញថា ព្រះពុទ្ធរូបដែលបានសាងឡើងហើយ បើមិនធ្វើពុទ្ធាភិសេកទេ មិនឡើងជាព្រះពុទ្ធឡើយ មិនគួរនឹងនមស្សការថ្វាយបង្គំឡើយ។ តាមពិតទៅព្រះពុទ្ធរូប ដែលកសាងហើយស្រេច ក៏បានឈ្មោះថា **"ឧទ្ទិស្សកចេតិយ"** តំណាងព្រះអង្គទៅហើយ ទោះបីអភិសេកក្តី មិនអភិសេកក្តី នោះមិនសំខាន់ឡើយ យើងជាពុទ្ធបរិស័ទគួរបង្អោនចិត្ត គោរពព្រះពុទ្ធរូបឱ្យដូចព្រះអង្គគង់ព្រះជន្មមាននៅ ។ ប្រពៃណី ធ្វើពុទ្ធាភិសេក មិនមែនមានតាំងពីសម័យពុទ្ធកាលទេ តែបានឧប្បត្តិឡើងរវាង ព.ស. ២១២២ ក្នុងខណៈដែលមានប្រពៃណី បូជាផ្កាយនព្វគ្រោះ ត្រង់ក្រុងរៀងហ្គៃ ក្នុងខណៈនោះព្រះចៅគ្រប់គ្រងនគរ និងព្រះសង្ឃបានប្រឹក្សាគ្នា ធ្វើពិធីបូជាព្រះ

www.elibraryofcambodia.org

ពុទ្ធ៩អង្គ ដើម្បីផ្លាស់ប្តូរប្រពៃណីបូជាផ្កាយនព្វគ្រោះនោះ ។

ក្នុងការបូជាផ្កាយនព្វគ្រោះ ដូចពោលមកនេះ ព្រះសង្ឃធ្វើពុទ្ធាភិសេក ដោយស្វាធ្យាយប្រពន្ធ័ចងក្រង មានពាក្យថា **អនេកជាតិសំសារំ** ជាដើម ក្រៅពីនោះ សូម្បីការកសាងព្រះចេតិយនិងព្រះពុទ្ធរូប ក៏និមន្តព្រះសង្ឃ ធ្វើពុទ្ធាភិសេកនេះដែរ រហូតជាប្រពៃណីដរាបដល់យើងសព្វថ្ងៃ ។

ប្រពៃណីធ្វើពុទ្ធាភិសេក ក្នុងស្រុកខ្មែរយើងនេះ ដោយធ្វើតៗគ្នាមកក៏ក្លាយទៅជារបៀបព្រហ្មញ្ញសាសនាខ្លះ ក្លាយទៅជាសេពអាគមន៍គាថាយន្តខ្លះក៏មាន ធ្វើឱ្យច្របូកច្របល់គ្នា រករឿងត្រូវមិនឃើញទៅហើយ កន្លែងខ្លះ យកខ្សែអំបោះទាក់មកពីព្រះពុទ្ធរូបចាស់មកតភ្ជាប់កព្រះពុទ្ធថ្មី ដែលអាចារ្យរុំអំបោះជុំវិញព្រះពុទ្ធរូប កាន់សេពអាគមន៍អូមអាមផ្សេងៗ ទៅតាមទំនៀមទំលាប់តៗគ្នាមានធ្វើពិធីសូត្រយ៉ោក[១] ជាដើម ។ ការដែលខ្ញុំឃើញរឿងច្របូកច្របល់យ៉ាងនេះ ក៏កើតសេចក្តីសង្វេគណាស់ ដោយធ្វើ

១. មកពីក្លាយពីពាក្យ យោគ

www.elibraryofcambodia.org

សេចក្ដីគោរពក្នុងព្រះសម្មាសម្ពុទ្ធ ខ្ញុំក៏បានចាប់ផ្ដើមសរសេរអំពីពិធីពុទ្ធាភិសេកដែលត្រឹមត្រូវតាមព្រះពុទ្ធសាសនាដោយអាស្រ័យតាមច្បាប់បោរាណាចារ្យពោលទុកមក ។

## ពុទ្ធាភិសេក

- មុនដំបូងពុទ្ធបរិសទ័ គប្បីតាំង **នមោ** ៣ ដង ព្រមជាមួយព្រះសង្ឃថា ៖

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។**

## សូត្រពុទ្ធការកធម៌

**- ឥតិបិ ទានបារមីសម្បន្នោ សោ ភគវា**

**ឥតិបិ ទានឧបបារមីសម្បន្នោ សោ ភគវា**

**ឥតិបិ ទានបរមត្ថបារមីសម្បន្នោ សោ ភគវា ។**

**ឥតិបិ សីលបារមីសម្បន្នោ សោ ភគវា**

**ឥតិបិ សីលឧបបារមីសម្បន្នោ សោ ភគវា**

www.elibraryofcambodia.org

ឥតិបិ សីលបរមត្ថបារមីសម្បន្នោ សោ ភគវា ។

ឥតិបិ នេក្ខម្មបារមីសម្បន្នោ សោ ភគវា

ឥតិបិ នេក្ខម្មឧបបារមីសម្បន្នោ សោ ភគវា

ឥតិបិ នេក្ខម្មបរមត្ថបារមីសម្បន្នោ សោ ភគវា ។

